00796557

E1/58.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Apr-2012, 16:00
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០៧ នាទី**

**សវនាការលើកទី៤៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ដាវ អានសាន

លោក ឌុច ផារី

លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក ប៉ាក ច័ន្ទលីណូ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

កញ្ញា លី ម៉ាញៀន *(Ms.Lyma NGUYEN)*

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ជេត វណ្ណលី

លោក វ៉ែន ពៅ

លោក បាណាបេ ណេគុី*(Mr. Barnabé NEKUIE)*

លោកស្រី ម៉ារី ហ្គីរ៉ូដ *(Ms. Marie GUIRAUD)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា លី ម៉ាញឿន | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក កាំង ហ្គេកអ៊ាវ | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច**


សួរបន្តដោយកញ្ញា លី ម៉ាញៀន ផ្តើមពី ........................................ទំព័រ ០១

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន ផ្តើមពី ........................................ទំព័រ ២៧

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ទំព័រ ៤៧

សួរដោយលោក ម៉ៃខល ផេសមិន ផ្តើមពី ........................................ទំព័រ ៥៣

# កិច្ចដំណើរការនីតិវិធី

[០៩:០៧:១៨]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការសម្រាប់ថ្ងៃនេះ តាមកាលវិភាគ និងការសម្រេចកាលពីម្សិលមិញ គឺក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី នឹងមានពេលវេលាមួយម៉ោងបន្ថែមនៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។ ដូច្នេះអង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅមេធាវីទទួលសិទ្ធិ នៃមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

[០៩:០៨:៤៧]

**កញ្ញា លី ម៉ាញឿន៖**

សូមអរគុណច្រើនលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរបន្តដោយកញ្ញា លី ម៉ាញឿន៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ កាលពីម្សិលមិញ យើងទុកចោលចំណុចដែលលោកផ្ដល់ចម្លើយអំពីការសួរចម្លើយទៅអ្នកទោសបរទេស។ លោកបានលើកឡើងថា លោកបានជួបជាមួយនឹងអ្នកបកប្រែ ដែលអ្នកបកប្រែនោះចូលរួមនៅក្នុងពេលសួរចម្លើយ ដើម្បីជួយទៅដល់ការសួរចម្លើយ។ លោកក៏បានទៅមើលផងដែរ ថាតើអ្នកបកប្រែនោះមានសមត្ថភាពភាសាអាចបកប្រែបានដែរឬទេ? ដូច្នេះលោកឯកភាពនឹងអ្វីដែលបានលើកឡើងដូច្នេះកាលពីម្សិលមិញដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំមិនគ្រាន់តែឯកភាពនឹងសម្ដីខ្ញុំទេ សភាព

ការណ៍នេះខ្ញុំនៅចាំច្បាស់។ ចាំច្បាស់អត់ស្រពេចស្រពិលទេ គឺអ៊ីចឹង។

[០៩:០៩:៥៥]

**ស៖** លោកក៏បានលើកឡើងផងដែរថា លោកបានអាន ទទួលបាន និងចាំចម្លើយសារភាពអ្នកទោសបរទេសបួនរូបដែលចូលស-២១ គឺឯកសាររបស់ ចន ឌូហឺស និង ឃែរី ហាមីល, ម៉ៃខល ឌីស, គ្រីស្តូហ្វ័រ ឡូវ៉ង់ ដែលបាន-- អ្នកទាំងបួននេះចាប់បានតាមរយៈនៅលើទូក។ តើលោកបញ្ជាក់-- អាចបញ្ជាក់លើចំណុចនេះបានដែរឬទេ?

**ឆ៖** អរគុណ។ ឯកសារនេះបើនិយាយពីអាន ខ្ញុំមិនបានជាយកចិត្តទុកដាក់ប៉ុន្មានទេ។ នេះជាទីមួយ។ ព្រោះអី? ព្រោះក្នុងពេលសួរចម្លើយនោះ មិត្តប៉ុន គាត់តែងតែមករាយការណ៍ឱ្យខ្ញុំ ដល់ត្រឹមនេះហើយ សភាពការណ៍វាទៅអ៊ីចេះ។ សរុបមក ឥឡូវនេះខ្ញុំវង្វេងអស់ នៅចាំតែវិធីម្យ៉ាង ដែលវិធីដើរក្នុងព្រៃទៅ ពិនិត្យមើលផ្លែឈើ តើផ្លែឈើអ្វីដែលអាចហូបកើត ផ្លែឈើអ្វីដែលអាចពុល។ នៅចាំបញ្ហាហ្នឹងមួយ។ ដូច្នេះនិយាយមួយម៉ាត់ ខ្ញុំនៅតែថែរក្សាអំណះអំណាងរបស់ខ្ញុំពីម្សិលមិញថា ចម្លើយទាំងអស់នេះ ខ្ញុំមិនបដិសេធទាំងស្រុងទេ ហើយក៏មិនយល់ព្រមថាពិតទាំងស្រុងដែរ។ ធម្មតាទេ យើងជាអ្នកសួរ យើងជាអ្នកវិភាគ មិនដែលទទួលស្គាល់អីដែលមកថ្មីភ្លាមថាពិតទាំងស្រុង ឬក៏មិនពិតទាំងស្រុងទេ។ នេះជារឿងដែលខ្ញុំនៅថែរក្សា។ ឯចម្លើយទាំងបួននេះខ្ញុំវង្វេងអស់ហើយ។ នៅចាំបានតែម្យ៉ាង គឺអារបៀបពិសោធផ្លែឈើនៅក្នុងព្រៃដែលយើងមិនស្គាល់ មិនធ្លាប់ហូប។ ហ្នឹងខ្ញុំសូមបញ្ចប់បញ្ហាប៉ុណ្ណេះ។

[០៩:១២:១៦]

**ស៖** លោក កាំង ហ្កេកអ៊ាវ តាមដែលលោកចាំចម្លើយសារភាព សេ.អ៊ី.អា របស់អ្នកទោសបរទេស តើលោកអាចជម្រាបចំណុចលម្អិតមួយចំនួន ដែលជនរងគ្រោះជាអ្នកទោសបរទេសលើកឡើងថាខ្លួនជាបណ្តាញ សេ.អ៊ី.អា ដែរឬទេ? លោកលើកឡើងថា ចម្លើយសារភាពនោះ គឺវាវែង ក៏ប៉ុន្តែតើជនរងគ្រោះបរទេសនៅពេលនោះនោះ តើគាត់បានសារភាពទៅលើចំណុចសកម្មភាពអ្វីខ្លះ? សូមឱ្យលោកបញ្ជាក់ដោយសង្ខេប។

**ឆ៖** អរគុណ។ ខ្ញុំជម្រាបដោយត្រង់ ថារំឭកមិនឃើញទេ។ ជារួម ខ្ញុំដូចជានៅចាំបានថា ពួកនេះសារភាពថាខ្លួនមកធ្វើប្រតិបត្តិការយកការណ៍។ និយាយមួយម៉ាត់ ដែលគេហៅថាចារកម្ម។ នេះខ្ញុំនៅចាំដូចជាពួកទាំងបួននាក់ហ្នឹងសារភាពអ៊ីចឹង។ ក៏ប៉ុន្តែឱ្យច្បាស់ វង្វេងអស់ហើយ ភ្លេចអស់ហើយ។

**ស៖** តើអ្នកទោសជនរងគ្រោះទាំងអស់នោះ និយាយអំពីការបរទេសនៅក្នុងតំបន់របស់ពួកគេ ហើយថាតើពួកគេបានរៀបរាប់អំពីគោលបំណងរបស់ សេ.អ៊ី.អា ដែលត្រូវបានចោទប្រកាន់ទៅលើពួកគេថា ដំណើរការយ៉ាងម៉េចនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះដែរឬទេ?

[០៩:១៥:០៦]

**ឆ៖** អរគុណ។ ខ្ញុំមិនចាំ វង្វេងអស់ហើយ ភ្លេច។

**ស៖** តើជនរងគ្រោះទាំងអស់នោះ និយាយអំពីរចនាសម្ព័ន្ធឃោធារបស់ សេ.អ៊ី.អា ខ្សែចង្វាក់បញ្ជាដែលពួកគេអនុវត្តតាម ប្រាក់ខែ និងកន្លែងដែលគេទទួលប្រាក់ខែ រចនាសម្ព័ន្ធឃោធា និងព័ត៌មានលម្អិតអំពីកម្មវិធីបណ្តុះបណ្តាល សេ.អ៊ី.អា របស់ពួកគេដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំនៅតែឆ្លើយដដែលទេ វាយូរឆ្នាំហើយ ហើយអង្គាល់នោះមិនយកចិត្តទុកដាក់ផង។ បញ្ហានេះ ពីព្រោះអី? ពីព្រោះចារកម្មដែលចូលមកស្រុកខ្មែរម្តងពីរៗបែបនេះ វាគ្មានខ្សែចង្វាក់អីនៅស្រុកខ្មែរ ម្តងពីរៗបែបនេះ វាគ្មានខ្សែចង្វាក់អីនៅស្រុកខ្មែរល្មមឱ្យចាប់តទៅទៀតទេ។ នេះជាមូលហេតុដែលខ្ញុំមិនសូវយកចិត្តទុកដាក់ ហើយដូចជាខ្ញុំជម្រាបអ៊ីចឹង ចម្លើយនេះ ខ្ញុំមិនទទួលស្គាល់ថាពិតទាំងស្រុង ហើយក៏មិនទទួលស្គាល់ថា មិនពិតទាំងស្រុងដែរ។ ទុកឱ្យខាងលើគេវិភាគចុះ គេសម្រេចចុះ។ ដូច្នេះវាមិនមែនជាបញ្ហា ទោះបីវាមានខ្សែបណ្តាញយ៉ាងម៉េចក៏ដោយ វាមិនមែនបញ្ហាដែលកើតនៅក្នុងស្រុកខ្មែរដែរ។ វាជាចារបុរសដែលបញ្ជូនមកពីចម្ងាយ។ នេះបើសិនជាបញ្ហាហ្នឹងវាពិត ដូច្នេះខ្ញុំភ្លេចអស់។ ខ្ញុំនៅចាំបានតែម្យ៉ាងដូចខ្ញុំបានជម្រាបរួចមកហើយ គឺរបៀបពិសោធផ្លែឈើដែលយើងដើរក្នុងព្រៃទៅ គេឃើញផ្លែអីទៅ យកមកពិសោធយ៉ាងម៉េច ដើម្បីហូបកើត កុំឱ្យវាពុល។ នេះនៅចាំច្បាស់។

[០៩:១៦:១០]

**ស៖** លោក កាំង ហ្កេកអ៊ាវ ខ្ញុំសួរម្តងទៀត។ តើជនរងគ្រោះទាំងអស់នោះសរសេរនៅក្នុងចម្លើយសារភាពរបស់ពួកគេ បាននិយាយអំពីគោលនយោបាយការបរទេស បញ្ហាតំបន់ បេសកកម្ម សេ.អ៊ី.អា នៅក្នុងតំបន់ ទំនាក់ទំនងអន្តរជាតិ ឧទាហរណ៍ទំនាក់ទំនងជាមួយនឹងសហភាពសូវៀត។ ខ្ញុំគិតថា លោក លោកស្រីចៅក្រមប្រហែលជាមានបញ្ហានៅលើមីក្រូហ្វូនរបស់ខ្ញុំ ឬយ៉ាងម៉េច? ស្តាប់អត់ឮ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តី លោកប្រធាន លោក លោកស្រីចៅក្រម អស់លោកស្រី ភាគីទាំងអស់នៅក្នុងបន្ទប់សវនាការ និងជុំវិញបន្ទប់សវនាការ។ ខ្ញុំគិតថា វាហាក់ដូចជាមានស្ថានភាពធ្ងន់ធ្ងរនៅពេលដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ព្យាយាមយកខ្លឹមសារនៅក្នុងចម្លើយសារភាពមកបង្ហាញសាក្សី ឱ្យសាក្សីបញ្ជាក់ថាតើ ចាំដែរឬទេ។ អង្គជំនុំជម្រះ ហាក់ដូចជាអនុញ្ញាតឱ្យមេធាវីប្រើប្រាស់ខ្លឹមសារនៃចម្លើយសារភាព ទោះបីចម្លើយសារភាពនោះធ្វើឡើងដោយទារុណកម្មក៏ដោយ។ ប្រសិនបើអ៊ីចឹងមែនមេធាវីគួរតែមិនត្រូវប្រើប្រាស់ខ្លឹមសារដែលត្រូវបានយកប្រើប្រាស់ជាភស្តុតាងនោះទេ។ ដូច្នេះ យើងដឹងហើយថា យើងមិនអាចយកព័ត៌មានដែលផ្តល់ព័ត៌មាន យើងមិនអាចយកព័ត៌មានដែលផ្តល់ដោយជនរងគ្រោះដែលត្រូវបានធ្វើទារុណកម្មដោយលោកសាក្សី រួមទាំងបុគ្គលិករបស់គាត់នោះទេ ហើយយើងមិនអាចយកខ្លឹមសារនៃចម្លើយសារភាពនោះ មកដាក់បង្ហាញដើម្បីឱ្យសាក្សីរូបនេះបញ្ជាក់ចងចាំឡើងវិញនោះទេ។ យើងដឹងហើយគាត់-- មេធាវីសួរថាតើចាំទេ? ចម្លើយសារភាព ខ្លឹមសារនេះចេញពីចម្លើយសារភាព។ លោកសាក្សីបញ្ជាក់ហើយថាគាត់មិនបានចាំទេ ហើយគាត់ក៏បានបញ្ជាក់ដែរ លោកសាក្សីថា មិនចាំទេ ទៅលើចម្លើយទាំងអស់នេះ។ ដូច្នេះយើងមិនគួរឱ្យមេធាវីសួរទៀតទេ ដើម្បីឱ្យគាត់ហ្នឹងអាចដឹងថាតើសាក្សីរូបនេះគាត់ចាំឬមិនចាំ។ យើងមិនគួរធ្វើដូច្នេះទេ ដើម្បីឱ្យនីតិវិធីរបស់យើងលឿនជាងនេះទេមុខ។

[០៩:១៩:០៥]

**ប្រធានអង្គជំនុំ៖**

បាទជំទាស់របស់មេធាវីអន្តរជាតិការពារលោក អៀង សារី មានប្រសិទ្ធភាព។

មេធាវីមិនត្រូវដកស្រង់នូវខ្លឹមសារនៃចម្លើយសារភាព ដែលបានមកពីការធ្វើទារុណកម្មយកមកធ្វើជាមូលដ្ឋានក្នុងការដេញដោលចំពោះសាក្សីនេះទេ។ បញ្ហាទីពីរ សាក្សីបានឆ្លើយបញ្ជាក់ហើយថាខ្លួនមិនចងចាំអ្វីទាំងអស់ទៅលើខ្លឹមសារនៃចម្លើយសារភាពរបស់ជនរងគ្រោះចំនួនបួននាក់ ជាជនបរទេសនៅក្នុងមន្ទីរស-២១ កន្លងមកនេះ។ លើកលែងតែវិធីមួយគត់ ដែលរបៀបនៅក្នុងការចំណាំផ្លែឈើណាដែលអាចហូបបាន ហើយផ្លែឈើណាដែលពុលមិនអាចហូបបានប៉ុណ្ណោះ។ ចម្លើយរបស់សាក្សី គឺបាន

បញ្ជាក់ច្បាស់ហើយ ថាព័ត៌មាននៅក្នុងចម្លើយសារភាពទាំងនោះ ខ្លួនមិនចាំអ្វីទាំងអស់។ ដូច្នេះពេលវេលា ដូចជាកាន់តែទៅមុខហើយ ហើយបើអត់អស់សំណួរ យើងនឹងប្រគល់ឲ្យទៅភាគីដទៃទៀត ដើម្បីតាំងសំណួរបន្តទៅទៀត ដើម្បីសន្សំពេលវេលា។

[០៩:២០:៥៤]

**កញ្ញា លី ម៉ាញឿន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដូចជាមិនសូវច្បាស់ថា តើការពិសោធផ្ដៃឈើនេះ គឺយ៉ាងម៉េចទេ ខ្ញុំស្ដាប់ដូចជាមិនច្បាស់សោះ។ ដូច្នេះដោយសារតែពេលវេលា ខ្ញុំសូមបន្តទៀត។

**សួរដោយកញ្ញា លី ម៉ាញឿន៖**

**ស៖** លោក កាំង ហ្គេកអ៊ាវ ខ្ញុំចង់ចូលទៅដល់ការសួរចម្លើយដែលមានអ្នកបកប្រែចូលរួម។ នៅពេលមានអ្នកបកប្រែចូលរួមក្នុងពេលសួរចម្លើយ គឺយើងដឹងហើយថាចម្លើយសារភាពនោះជាភាសាអង់គ្លេស ត្រូវបានសរសេរ ហើយលោកបានទទួលដែរ មែនដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ចម្លើយជាភាសាអង់គ្លេស ខ្ញុំបានទទួលហើយបញ្ជូនទៅលើ។

**ស៖** ខ្ញុំចង់សួរថា តើអ្នកបកប្រែដែលចូលរួមនៅក្នុងពេលសួរចម្លើយនោះ គឺជាបុគ្គលតែមួយដែលបានសរសេរចម្លើយសារភាពទាំងអស់នោះ ឬក៏យ៉ាងម៉េច? តើអ្នកបកប្រែនោះ ជាអ្នកសរសេរអត្ថបទចម្លើយសារភាពជាភាសាខ្មែរទាំងអស់ ដែលគាត់បានបកប្រែមែនដែរឬទេ?

**ឆ៖** អរគុណ។ បើតាមខ្ញុំចាំ អ្នកដែលបកប្រែនេះតែមនុស្សម្នាក់ទេ តាំងពីដើមដល់ចប់ ឯចំណែកអក្សរអង់គ្លេសនោះជារបស់ជនរងគ្រោះ ដែលត្រូវតែសរសេរសេចក្ដីសារភាពនេះ ដែលពេលនោះគេហៅថា អ្នកទោស។ ឯចំណែកជាអក្សរខ្មែរ គឺជាអក្សររបស់អ្នកសួរចម្លើយ គេសរសេរ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

[០៩:២៣:១៣]

**ស៖** លោកសាក្សី តើលោកអាចនិយាយ និងយល់ភាសាអង់គ្លេសដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំចំណេះវិជ្ជាអង់គ្លេសតិចណាស់ ក៏ប៉ុន្តែក្នុងឋានៈខ្ញុំជាប្រធានស-២១ ខ្ញុំយល់បញ្ហាដែលត្រូវធ្វើ។ នៅពេលដែលចាត់តាំង ចាប់ផ្ដើមសួរចម្លើយ ខ្ញុំទៅ

ស្តាប់គេសួរដំបូង មួយឃ្លាពីរ។ ដល់រួចហើយ ខ្ញុំសង្កេតឃើញថា គេនិយាយពិភាក្សាអង់គ្លេស វាហាក់ដូចរលូនទៅរបស់គេ។ ហើយខ្ញុំសួរ តើហ្អែងឈ្មោះអីហ៎ា? សូមទោសណ៎ា! អង្កាល់ណោះ ខ្ញុំហៅ អ្អែង! ចំពោះអ្នកទោស ខ្ញុំហៅ អ្អែង។ អ្អែង! ឈ្មោះអីហ៎ា? វាប្រាប់ អ្អែង! កូនអ្នកណា? វាប្រាប់ថាខ្ញុំកូន សារិន ឆាក។ ខ្ញុំថា អ៎! សូមបញ្ជាក់ជូនអង្គប្រជុំថា សារិន ឆាក នេះជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់ សីហនុ។ មិនស្មើរទេ ដូច្នេះ គេទៅរៀននៅអង់គ្លេសប៉ុន្មានឆ្នាំ ខ្ញុំសួរ តែខ្ញុំភ្លេចទៅហើយ។

[០៩:២៤:៣០]

រួចខ្ញុំចង់ដឹងថា តើវាចេះខ្មែរមែន ឬមិនមែន? អ៊ូ! វាចេះអង់គ្លេសច្បាស់មែន ឬមិនមែន? ខ្ញុំសួរ សូមទោសចុះ! ខ្ញុំនិយាយឲ្យត្រង់ ពាក្យហ្នឹងវាចម្អែះចំអាសបន្តិច ខ្ញុំថា ឥឡូវពាក្យអង់គ្លេសគេជេរថា "កូនមីចោរកញ្ជុយ" ជេរថាម៉េច? ដល់ទៅអានោះឆ្លើយ *"សាន់អូហ្វប៊ីតឆ៍"*។ ខ្ញុំថាអ៎ា! វាចេះច្បាស់ទាំងអាពាក្យកន្តុកកន្ទ្រៀត ជេរប្រទេចផ្តាសាហ្នឹង ក៏ចេះដែរ ខ្ញុំថា អ៊ូ! គេចេះមែន។ ថាអី! ឯងចេះមែន ជួយអញទៅ ប្រែឲ្យស្រួល។ ដូច្នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

**ស៖** លោកសាក្សី តើលោកមានកម្រិតភាសាអង់គ្លេស អាចយល់ជនជាតិអាមេរិក ឬក៏អ្នកទោសបរទេសនោះនិយាយអ្វី ដែលគាត់លើកឡើងដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់នៅសួរទេ ខ្ញុំទៅនេះគ្រាន់តែដឹងសមត្ថភាពអ្នកបកប្រែប៉ុណ្ណោះ។ ឯចំណែកការសួរតទៅទៀត អ្នកសួរគេម្ចាស់ការ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

[០៩:២៦:១៦]

**ស៖** តើលោកចាំទេ កាលម្សិលមិញលោកឆ្លើយថា ភារកិច្ចរបស់ស-២១នោះគឺ ស៊ើបការណ៍។ ដូច្នេះហើយទើបស្វែងរកពួកគិញយួន សេ.អ៊ី.អា, កា.ហ្សេ.បេ នៅក្នុងទឹកដីដែនដីរបស់កម្ពុជាប្រជាធិបតេយ្យ។ នេះជាអ្វីដែលលោកបានលើកឡើងដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ម្សិលមិញ ខ្ញុំនិយាយពីភារកិច្ចរបស់មន្ទីរស-២១។ មន្ទីរស-២១ នេះជាអង្គការភាពប្រតិចារកម្ម។ ប្រតិចារកម្មនេះ បើជាភាសាបារាំង គេហៅថា *កុងត្រឹសអេញ្ជូណាស* ភាសាអង់គ្លេស មិនដឹងគេហៅអីទេ។ ដូច្នេះមិនមែនភារកិច្ចស៊ើបការណ៍ទេ ភារកិច្ចតាមដានវែកមុខពួកចារកម្ម។

[០៩:២៧:១៧]

**ស៖** តើលោកចាំឆ្លើយនៅក្នុងពេលដែលសហព្រះរាជអាជ្ញាសួរ គោលបំណងនោះគឺថា រៀបចំចម្លើយសារភាពពីអ្នកទោស ហើយទាញយកចម្លើយសារភាពទាំងអស់នោះ ថាតើពួកគេនោះមានធ្វើសកម្មភាពពាក់ព័ន្ធទៅនឹងសកម្មភាពមុនដែរឬទេ? ហើយភាពត្រឹមត្រូវទៅលើសកម្មភាពដែលបានរៀបរាប់នោះ គឺវាអាស្រ័យទៅលើថ្នាក់លើជាអ្នកសម្រេច។ តើលោកចាំថាបាននិយាយដូច្នេះដែរឬទេ?

[០៩:២៧:៥៥]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ភារកិច្ចនេះ ខ្ញុំសូមទទួលស្គាល់ ទោះបីការប្រែចុះប្រែឡើងជាភាសាវាល្អៀងបន្តិចបន្តួចក៏ដោយ ក៏ខ្ញុំនៅតម្កល់ថា វាមានលក្ខណៈពិតហើយថាខ្ញុំនិយាយអ៊ីចឹងមែន។ ហើយគ្រាន់តែបញ្ជាក់ថា ការប្រែភាសាចុះឡើងៗមកដល់មេធាវីគាត់បកប្រែនេះវាល្អៀងពីន័យដើមបន្តិច។ សូមទុកបញ្ហានេះទៅ មើលអាខ្ញុំនិយាយដំបូងជាមួយនឹងព្រះរាជអាជ្ញាជាភាសាខ្មែរ។

**ស៖** សូមអរគុណ។ តើខ្ញុំលើកឡើងត្រឹមត្រូវដែរឬទេ ថាវាមិនជាបញ្ហាថាអ្នកទោសនិយាយអ្វីនោះទេ ហើយការពិតនៃប្រវត្តិសាវតាររបស់គេយ៉ាងម៉េចនោះទេ។ ការពិតនោះគឺថា លោកចង់ឲ្យគេទទួលបាន-- ចង់យកចម្លើយសារភាព ហើយទទួលព័ត៌មានទាំងអស់នៅស-២១ ដោយចង់ឲ្យព័ត៌មានទាំងអស់ដែលជាចម្លើយសារភាពនោះថា ជនរងគ្រោះ អ្នកទោសនោះបានធ្វើនូវសកម្មភាពចារកម្មមួយចំនួន ក្នុងនាមជាកងកម្លាំងរបស់ជនបរទេស។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សំណួរនេះមានសភាពការណ៍ថ្មីបន្តិច។ ចូលទៅលក្ខណៈ នៃការកសាងសំណុំរឿងនៅស-២១។ ខ្ញុំសូមបញ្ជាក់ថា ចិត្តថ្លើមរបស់កម្មាភិបាលសួរចម្លើយ ដូចខ្ញុំបញ្ជាក់រួចមកហើយ កូនចៅខ្ញុំទាំងអស់ សុទ្ធតែមិនដែលទទួលស្គាល់ស្អីថាពិតទាំងស្រុង ហើយស្អីក៏មិនទទួលស្គាល់ថាមិនពិតទាំងស្រុងដែរ។ ចម្លើយ កុយ ធួន ជាឧទាហរណ៍ ឆ្លើយហូរឆ្លើយហែ ខ្ញុំមិនទទួលស្គាល់ថា ពិតទាំងស្រុង ហើយក៏មិនទទួលស្គាល់ថាមិនពិតទាំងស្រុងដែរ។ ខ្ញុំរុញទៅឲ្យខាងលើ ដែលគេបានយល់ដឹងទូលំទូលាយនេះមួយ។ គេជាអ្នកមានសមត្ថកិច្ចពេញលេញ ពេញបរិបូរនិងវិភាគ និងសម្រេច ទុកឲ្យគេសម្រេច។

ដូច្នេះ យុទ្ធវិធីសួរចម្លើយរបស់អ្នកស-២១ គឺខំធ្វើម៉េចដើម្បីឲ្យបានចម្លើយមួយ ដែលខ្លួនបានត្រិះរិះពិចារណា។ ដូចខ្ញុំបានជម្រាបមេធាវីម្សិលមិញហើយ ពេលណាត្រូវសួរ សួរយ៉ាងម៉េច? ពេល

ណាត្រូវដកថយមកគិត គិតសិនយ៉ាងម៉េច? តើពេលណាប្រើវិធានការស្អីទៀត? ដូច្នេះគេមានទិសដៅរបស់គេ ចង់បានចម្លើយសារភាពមួយ ដែលគេខំពុះពារធ្វើការឲ្យបានត្រឹមត្រូវមួយកម្រិតណា? នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

[០៩:៣១:៣៦]

**ស៖** នៅពេលដែលយកៗចម្លើយពីអ្នកទោសដូចជា អ្នកទោសជាជនបរទេស តើថ្នាក់លើណាដែលលោកបញ្ជូនចម្លើយសារភាពនោះទៅឲ្យនោះ?

**ឆ៖** អរគុណ។ អ្នកទោសមកជាពីរដំណាក់។ មួយដំណាក់បញ្ជូនមកឲ្យខ្ញុំគឺ បង សុន សេន ពេលដែលសួរចម្លើយបានប្រហែលជាគាត់នៅជាមួយនឹងខ្ញុំនៅឡើយទេ។ ប្រហែលជាមុនថ្ងៃ១៥ ខែសីហា ១៩៧៧ នេះខ្ញុំគ្រាន់តែប្រហែលទេ មិនច្បាស់ទេ។ ប្រសិនបើចម្លើយយកបានក្រោយនុ៎ង គឺខ្ញុំត្រូវបញ្ជូនទៅបង នួន គឺ នួន ជា នេះ។ ដោយឡែក ពួកពីរនាក់ដែលមកក្រោយនេះ គឺខ្ញុំបញ្ជូនទៅបង នួន ជា។

[០៩:៣២:៤៤]

**ស៖** តើ សុន សេន និង នួន ជា គាត់ចាត់ការជាមួយនឹងចម្លើយសារភាពរបៀបណានៅពេលគាត់បានទទួលចម្លើយសារភាពនេះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អចិន្ត្រៃយ៍មជ្ឈិមបក្សដែលក្នុងនោះមានបង នួន ជា ហើយនិងបង សុន សេន ចាត់ការយ៉ាងណាលើចម្លើយសារភាពនេះ តាមសមត្ថកិច្ចរបស់ខ្ញុំ ខ្ញុំអត់ដឹងទេ-- អឺ! តាមសមត្ថកិច្ចរបស់អចិន្ត្រៃយ៍ខ្ញុំអត់ដឹងទេ។ ខ្ពស់ផុតការយល់ដឹងរបស់ខ្ញុំ។ ខ្ញុំដឹងតែមួយយ៉ាង គឺបានចម្លើយសារភាពជូនគាត់ គាត់សម្រេចឲ្យខ្ញុំកម្ទេច។ នេះប៉ុននុ៎ង។

[០៩:៣៣:៥៣]

**ស៖** តើការបញ្ជាឲ្យដុតជនបរទេសទាំងរស់នេះ គឺជាគោលនយោបាយតែមួយ ឬក៏ជាការសម្រេចទៅតាមករណីនីមួយៗនៅពេលដែលជនរងគ្រោះមកដល់កន្លែងលោកនោះ?

**ឆ៖** អរគុណ។ ការសម្រេចជាទូទៅចំពោះគ្រប់ករណីជនរងគ្រោះដែលយកទៅពិឃាដទោះបីនៅជើងឯកក៏ដោយ ទោះបីនៅក្បែរស-២១ ហ្នឹងក៏ដោយ ធ្វើម៉េចធានាឲ្យច្បាស់ថាបានសម្លាប់ហើយមិនមែនដោះលែងទេ។ ដូច្នេះហើយបានជាមានអ្នកទោសខ្លះបងនួន នេះបញ្ជាឲ្យខ្ញុំថតនៅពេលដែលក្រោយសម្លាប់ហើយ។ ដោយឡែកជនបរទេសទាំងបួនរូបនេះ ខ្ញុំចាំច្បាស់បំផុតគឺពីរនាក់ ក៏ប៉ុន្តែខាងពីរ

នាក់មុនក៏ប្រហែលជាត្រូវបង នួន ជា ឲ្យដុតទាំងរស់-- ន៎ែ ឲ្យដុតឲ្យស្មុះ ឲ្យអស់ដែរ។ នេះវាមានលក្ខណៈប្លែកគ្នាអ៊ីចឹង។

**ស៖** ចាតើចម្លើយសារភាពរបស់អ្នកទោសពិសេសៗ ដូចជាអ្នកទោសជាជនជាតិពួកអឺរ៉ុបនេះ នៅពេលដែលផ្ញើទៅថ្នាក់លើដូចជា អៀង សារី តើចាត់ការរបៀបណា?

[០៩:៣៥:៤៥]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមមិនឆ្លើយនឹងសំណួរនេះទេ។

**ស៖** តើចម្លើយសារភាពរបស់អ្នកទោសពិសេសៗដែលបានទទួលហ្នឹង ហើយក្រោយមកធ្វើការវិភាគ ហើយក្រោយមកត្រូវបានយកទៅប្រើក្នុងការឃោសនាសម្រាប់បក្សឬក៏យ៉ាងណាដែរ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាមានចលនាមួយយកចម្លើយរបស់អ្នកទោសខ្លះយកទៅអានឲ្យមហាជននៅក្នុងអង្គភាពយោធាស្តាប់។ អ្នកដែលអាន គឺបង សុន សេន តែម្តង គាត់យកទៅអាន។ បើតាមខ្ញុំចាំយកចម្លើយរបស់ ពេជ ឆន ហៅ សោម យកចម្លើយរបស់ ប៉ាង ប្រធានមន្ទីរពេទ្យ៩៨ គឺមន្ទីរពេទ្យសេនាធិការ ហើយយកចម្លើយ យ៉ា, ម៉ែន សាន ហៅ យ៉ា យកទៅអាន។ ហើយដូចជាមានចម្លើយ កុយ ធួន ហៅ ធុច ខ្លះ យកទៅអាន។

[០៩:៣៧:៤២]

ដោយឡែកបង ប៉ុល និយាយអំពីចម្លើយ កុយ ធួន ម្តងនៅក្នុង-- ដូចជាក្នុងពិធីបុណ្យ១៧ មេសា ១៩៧៧។ អង្កាល់នុ៎ង កុយ ធួន គាត់សរសេរថា គាត់នៅក្នុងសមាជិកមជ្ឈិមបក្ស គាត់ជាបុគ្គលទីប្រាំបួន យ៉ា ជាបុគ្គលទី១០។ ក៏ប៉ុន្តែចម្លើយសារភាព យ៉ា គាត់សរសេរ-- អ៎ន៎ែ! កុយ ធួន គាត់សរសេរថា យ៉ា បញ្ជាគាត់យ៉ាងនេះ បញ្ជាគាត់នោះ។ នៅពេលហ្នឹងហើយខ្ញុំចាំច្បាស់ថាបង ប៉ុល មានប្រសាសន៍ថា ក្រោមទង់បក្ស អាធុច វានៅពីលើ អាយ៉ា ក៏ប៉ុន្តែក្រោមទង់ សេ.អ៊ី.អា អាយ៉ា វានៅពីលើ អាធុច។ នេះគាត់និយាយនៅក្នុងពិធីបុណ្យហ្នឹងតែម្តង។

ដូច្នេះសរុបមកវិញ នេះវាចូលក្នុងៗការដែលអធិប្បាយហើយ។ សរុបមកវិញតែមួយម៉ាត់ទេ គឺបក្សកុម្មុយនីស្តកម្ពុជានៅមានពេលខ្លះ យកចម្លើយសារភាពរបស់អ្នកទោសទៅឃោសនា។ អ្នកដែលយកទៅឃោសនាហ្នឹងមាន បងប៉ុល និងបង សុន សេន។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

[០៩:៣៩:២៣]

**កញ្ញា លី ម៉ាញៀន៖**

នៅក្នុងដំណាក់កាលនេះ ខ្ញុំចង់បង្ហាញឯកសារមួយជូនទៅសាក្សី គឺឯកសារ D229.1, ERN ជាភាសាអង់គ្លេស គឺ00669031 ជាភាសាខ្មែរ 00285361 ជាភាសាបារាំង 00314947។ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះឲ្យមន្ត្រីតុលាការយកឯកសារជូនទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការយកឯកសារពីមេធាវី យកទៅជូនសាក្សីពិនិត្យ!

**កញ្ញា លី ម៉ាញឿន៖**

ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញឯកសារលើអេក្រង់ផងបានទេ?

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត! ប៉ុន្តែគប្បីលើកក្រោយគឺសម្រេចស្នើសុំទាំងពីរម្តងទៅ វាស្រួលដល់អង្គជំនុំជម្រះសម្រេច។ វាចៀសវាងការបញ្ចាំងឯកសារនៅលើអេក្រង់ទូរទស្សន៍រួចទើបតែស្នើសុំជាក្រោយ។

**កញ្ញា លី ម៉ាញឿន៖**

សូមអរគុណលោកប្រធាន។

[០៩:៤០:៥១]

**សួរដោយ កញ្ញា លី ម៉ាញឿន៖**

**ស៖** សាក្សីតើលោកធ្លាប់បានឃើញឯកសារនេះពីមុនមកទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះពិតជាឯកសារ ស-២១ អក្សរដែលសរសេរនេះគឺអក្សរ មិត្តប៉ុន។ ក៏ប៉ុន្តែឯកសារនេះជាក់ស្តែង ខ្ញុំឃើញនៅពេល ក្នុងសវនាការសំណុំរឿងលេខ០០១។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

**ស៖** តើនៅពេលដែលលោកជាប្រធាន ស-២១ ហ្នឹង លោកបានឃើញឯកសារហ្នឹងដែរឬទេពេលនោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ពេលដែលខ្ញុំនៅធ្វើប្រធាន ស-២១ ខ្ញុំមិនបានអានឯកសារនេះទេ។

**ស៖** តើលោកអាចបញ្ជាក់ជូនតុលាការបានទេ អំពីចំណងជើងនៃឯកសារ និងកាលបរិច្ឆេទរបស់ឯកសារនេះ?

[០៩:៤២:៣២]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ចំណងជើងរបស់ឯកសារនេះ គេដាក់ថែមឲ្យក្រោយទេ របាយការណ៍សរុបរបស់មន្ទីរ ស-២១។ ឯចំណែក មិត្តប៉ុន គាត់សរសេរនេះ គាត់សរសេរនែ៎ ពីជំពូកទីមួយទៅរបស់គាត់។ ឯចំណែក កាលបរិច្ឆេទចុងក្រោយនេះ មិនមែនមិត្តប៉ុនទេសរសេរ គឺមិត្តហ៊ី អនុលេខារបស់ខ្ញុំសរសេរ។ ចប់ ស-២១ ១២-៧-៧៨។ ដូច្នេះ មិត្តហ៊ី គាត់បានអាន មិត្តប៉ុន ឲ្យអាន ហើយមិត្តហ៊ី គាត់សរសេរអ៊ីចឹងទៅ។

**ស៖** តើលោកដឹងថាឯកសារនេះជាឯកសារអ្វីដែរ? ម៉េចបានជាមានចំណងជើងថា "អំពីផែនការរួចចុងក្រោយ"?

[០៩:៤៣:៥៦]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នៅពេលថ្ងៃមួយនោះ ក្នុងវគ្គសិក្សាឆ្នាំ១៩៧៧ បង សុន សេន ហៅខ្ញុំទៅប្រាប់ថា មិត្តសរុបមើល៍ខ្សែខ្មាំងដែលចាប់មកនៅ ស-២១ យកមកឲ្យខ្ញុំ ដើម្បីឲ្យខ្ញុំសរុបទូទាំងប្រទេស។ មកដល់ផ្ទះវិញ មកដល់កន្លែងវិញ ខ្ញុំហៅ មិត្តប៉ុន មកប្រាប់ថាមិត្តសរុបទៅខ្ញុំក៏ធ្វើមួយដែរ។ ប៉ុន្តែដោយក្រោយមកការងាររវល់ពេកនៅ ស-២១ ហើយមេខ្ញុំ បង សុន សេន ហ្នឹងក៏បែកទៅអ្នកលឿងបាត់តាំងពីថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៧ ទៅ គ្មានអ្នកណាបាននឹកនាដល់ឯកសារនេះទេ។ ខ្ញុំសរសេរមិនចប់ទេ របស់ខ្ញុំសរសេរមិនចប់ទេ សរសេរបានតែពីរបីទំព័រប៉ុននុ៎ង។ ដូច្នេះ មិត្តប៉ុន គាត់សរសេរបានប៉ុណ្ណឹងរបស់គាត់។ រួចគាត់ឲ្យ មិត្តហ៊ី អាន។ ដូច្នេះ មូលហេតុដែលនាំឲ្យមានការសរសេរឯកសារនេះ វាមានមូលហេតុរបស់វាច្បាស់លាស់ គឺបង សុន សេន បញ្ជាឲ្យស-២១ សរសេរសរុបខ្សែខ្មាំងនៅក្នុងមន្ទីរស-២១។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

**ស៖** សាក្សីខ្ញុំសូមឲ្យលោកផ្ដល់ការយកចិត្តទុកដាក់ផ្នែក(ខ) នៃឯកសារនេះ។ មានន័យថាខ្លឹមសារសរុប។ ខ្ញុំសូមអានដូចតទៅ៖ "សូវៀត ជាក្បាលម៉ាស៊ីននៃផែនការក្បត់នៅកម្ពុជា វាយកយួនជាអ្នកអនុវត្តផ្ទាល់។ ចក្រពត្តិអាមេរិកវាស៊ុមគ្រលុំជាមួយសូវៀត ដោយជំរុញសៀមឲ្យផ្គត់ផ្គង់សព្វគ្រប់ដល់ពួកខ្មែរសេរីនៅប្រទេសថៃ។ ក្នុងប្រទេស ពួកភ្នាក់ងារ សេ.អ៊ី.អា និងជាពិសេសយួនលេបទឹកដី វាសហការអនុវត្តផែនការតែមួយ ដែលវាជាប់ទាក់ទងជាមួយខាងក្រៅប្រទេស"។ តើលោកបានឃើញឃ្លាទាំងនេះទេ?

[០៩:៤៦:២៩]

**ឆ៖** អរគុណ។ ខ្ញុំបានឃើញឃ្លាទាំងនេះ។

**ស៖** តើចំណងជើង ឬក៏ខ្លឹមសារនៃឯកសារនេះបានមកពីណាដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរ! ស្តាប់ការជំទាស់របស់មេធាវីការពារក្តីជាមុនសិន។ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ។ ខ្ញុំសូមអធ្យាស្រ័យចំពោះការបង្អាក់នេះ ការឡើងជំទាស់តវ៉ានេះ។ តាមដែលខ្ញុំចាំ គឺសាក្សីបានបញ្ជាក់ពីខាងថា គាត់មិនបានឃើញឯកសារនេះទេ។ សំណួរខ្លះបានសួរហើយ ខ្ញុំមិនជំទាស់ទេ។ ឥឡូវនេះគឺថាបានស្នើសុំឲ្យសាក្សីធ្វើការប៉ាន់ស្មានទៅលើឯកសារនេះ-- ស្មានៗទៅលើឯកសារនេះ។ ហើយការធ្វើបែបនេះមិនមែនតែម្តងទេ។ ដូច្នេះ ខ្ញុំសូមជំទាស់ការសួរឲ្យសាក្សីឆ្លើយយ៉ាងនេះ គឺថាជាការៗអនុញ្ញាតឲ្យសាក្សីនេះ គឺឆ្លើយស្មានៗតែប៉ុណ្ណោះ។

[០៩:៤៧:៥១]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៨:០៦]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី តើឯកសារនេះមានជាភាសាអង់គ្លេស ហើយនិងជាភាសាបារាំងដែរទេ?

**កញ្ញា លី ម៉ាញៀន៖**

មាន លោកប្រធាន។ បើសិនជាចង់បានខ្ញុំផ្តល់ជូនលេខ ERN បាន។ ERN ជាភាសាអង់គ្លេសគឺ 00069031 ហើយជាភាសាបារាំង 00314947។ ហើយឯកសារនេះ ជាឯកសារលេខ D229.1 ឬក៏ហៅថា D288/65/2.29។

[០៩:៤៩:០១]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥០:១៨]

**ប្រធានអង្គជំនុំ៖**

បុគ្គលិកជំនួយការអាចបង្ហាញឯកសារជាភាសាអង់គ្លេសនៅលើអេក្រង់ទូរទស្សន៍បានដែរទេ?

ឯកសារនេះ?

**កញ្ញា លី ម៉ាញឿន៖**

លោកប្រធានតើ--

[០៩:៥១:៥៧]

**ប្រធានអង្គជំនុំ៖**

លោក កាំង ហ្គេកអ៊ាវ ឯកសារដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិបានបង្ហាញលោកអម្បាញ់មិញនេះ តើលោកធ្លាប់បានឃើញពីមុនមកដែរឬទេ? ពាក្យថាពីមុននេះ មុនពេលដែលសាក្សីផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ មានការឃើញនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និង/ឬ មានការឃើញក្រោយមកទៀត។ ប៉ុន្តែគឺមុនពេលអំឡុងពេលនៃការកោះហៅសាក្សីមកដេញដោលចំពោះមុខអង្គជំនុំជម្រះ។ តើលោកដែលឃើញ និងបានអានឯកសារហ្នឹងដែរទេ កន្លងមក?

[០៩:៥២:៥២]

**លោក កាំង ហ្គេកអ៊ាវ៖**

អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះខ្ញុំឃើញជាលើកទីមួយ គឺនៅក្នុងសវនាការក្នុងសំណុំរឿងលេខ០០១ ការិយាល័យសហព្រះរាជអាជ្ញា បញ្ជូន-- ប្រគល់ឲ្យខ្ញុំឆ្លើយ។ តើជាអក្សរអ្នកណា? ខ្ញុំជម្រាបការិយាល័យសហព្រះរាជអាជ្ញាថា អក្សរ មិត្តប៊ុន ក៏ការិយាល័យសហព្រះរាជអាជ្ញាទុកទៅ មិនសួរនាំអីទៀតទេ។ ឯចំណែកខ្ញុំ ៗបានសំណៅមួយច្បាប់យកទៅទុកនៅផ្ទះពេលខ្លះខ្ញុំបានមើលដែរ ហើយជាពិសេសនៅពេល ការិយាល័យសហព្រះរាជអាជ្ញាប្រគល់មកឲ្យ ខ្ញុំៗបានអានមុន។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចជំទាស់លើការជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក អៀង សារី ដែលបានជំទាស់ទៅនឹងការដេញដោលឯកសារនេះ ដោយមេធាវីការពារក្តីហ្នឹងគ្មានប្រសិទ្ធភាពទេ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចបន្តការតាំងសំណួរដេញដោលចំពោះសាក្សីលើបញ្ហាទាំងឡាយ ដែលខ្លួនយល់ថាមានប្រយោជន៍ពាក់ព័ន្ធនឹងឯកសារនេះបាន។

[០៩:៥៤:១០]

**សួរដោយកញ្ញា លី ម៉ាញឿន៖**

**ស៖** សាក្សី តាមការដែលលោកដឹងអំពីខ្លឹមសារនៃឯកសារ នៅពេលដែលលោកមានឱកាសបានអានហើយនោះ តើលោកយល់ស្របទេថា ខ្លឹមសារនេះសូម្បីតែពីផ្នែកសង្ខេបចំណងជើងខ ក៏ដោយ។ តើ--

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមបញ្ជាក់ថា ខ្លឹមសារនេះវាស្របទៅតាមលោកទស្សនៈនៃបក្សកំណត់ថាអ្នកណាខ្លះជាខ្មាំង។ ខ្មាំងមានចែកជាបីប្រភេទអ៊ីចឹង ក៏ប៉ុន្តែឧទាហរណ៍នេះ ឧទាហរណ៍ដូចថា ឈូក ទាក់ទងបីម៉ាត់។ ហ្នឹងជាការដែល មិត្តប៊ុន សរុបទៅតាមចម្លើយសារភាពដែលខ្លួនយកបាន ដោយមានទារុណកម្មផង។ ពួក ឃួន ទាក់ទងឃួនទៅឃួនផង ជាពិសេសទៅតាមថៃតាមរយៈ សុត លេខាតំបន់១០៦ ពួក សាយ នៅពាយ័ព្យ។ ទាំងអស់នេះសុទ្ធតែការដែល មិត្តប៊ុន ផ្អែកទៅលើចម្លើយសារភាព។ ហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

[០៩:៥៥:៥៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! មានការអីទៀតទេ?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំមិនបានឮចម្លើយទេ គឺថាមានបញ្ហាខាងផ្នែកឧបករណ៍ហើយលោកប្រធាន។

តើលោក-- យើងអាចបញ្ឈប់ពេលវេលាខ្លះទេ ដើម្បីឲ្យយើងផ្លាស់ប្តូរឧបករណ៍ស្តាប់សំឡេងរបស់ខ្ញុំនេះ?

**ប្រធានអង្គជំនុំ៖**

អត់ទេ ទៅមុខជានិច្ច។

តទៅទៀត! តាំងសំណួរតទៅទៀត នៅសល់ដប់នាទី-- សល់ដប់ប្រាំនាទីទៀត ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិ។

**កញ្ញា លី ម៉ាញឿន៖**

លោក លោកស្រីចៅក្រម ឥឡូវនេះគឺថាយើងបានទទួលប្រយោជន៍ដោយសារយើងនៅមានពេលខ្លះទៀតដែរ។ យើងខ្ញុំបានគិតថា យើងត្រូវសាកសួរទៅលើអ្នកដែលមានបទពិសោធន៍អ៊ីចឹង ដោយ

យើងមានក្រុមជនរងគ្រោះ ដែលទទួលរងព្យសនកម្មដោយសារតែការប្រកាន់រើសអើងនឹងអំពើប្រល័យពូជសាសន៍។ ជនរងគ្រោះទាំងអស់ចង់ដឹងការពិតលើសពីអ្វីៗទាំងអស់។ ការពិតគឺជាចំណុចសំខាន់បំផុត ដើម្បីឲ្យពួកគាត់ទទួលបាននូវយុត្តិធម៌ និងការទទួលខុសត្រូវ ហើយដូច្នេះ យើងខ្ញុំអរគុណចំពោះការផ្តល់ពេលវេលា ដើម្បីឲ្យយើងខ្ញុំសាកសួរបន្តទៅទៀតក្នុងនាមឲ្យកូនក្តីរបស់យើងខ្ញុំ ដើម្បីឆ្លើយតបទៅនឹងបទពិសោធន៍ជូរចត់ ក៏ដូចជាការចង់ដឹង ចង់ឮរបស់គាត់នៅពេលនោះ។

[០៩:៥៧:៤៨]

**ប្រធានអង្គជំនុំ៖**

លោកស្រីមានពេលវេលាដប់ពីរ *មីនុត*ទៀត។

**សួរដោយកញ្ញា លី ម៉ាញៀន៖**

**ស៖** លោកសាក្សីដោយសារតែខ្ញុំមិនមានពេលច្រើន ខ្ញុំសូមចូលប្រធានបទផ្សេងទៀត។ លោកបាននិយាយអំពីភស្តុតាងដែលថា នួន ជា បានស្នើសុំឲ្យស-២១ កត់ត្រាឈ្លើយសឹកជនជាតិវៀតណាមពីរនាក់ ដើម្បីធ្វើការផ្សព្វផ្សាយ។ តើលោកចាំរឿងនេះទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន រឿងពិត គឺថ្ងៃ៨ មករា ១៩៧៨ បងនួននេះហៅខ្ញុំទៅធ្វើការ។ បានន័យថា ក្រោយមីទ្ទិងរំឭកមហាជ័យជម្នះរបស់កងទ័ពបដិវត្តន៍កម្ពុជាទៅលើកងទ័ពវៀតណាមទេ។ បងនួន ហៅខ្ញុំទៅធ្វើការថា ឥឡូវមិត្តសួរចម្លើយឈ្លើយសឹកវៀតណាម ហើយថតសំឡេងមួយអាទិត្យឲ្យបានពីរនាក់ ទុកយកទៅផ្សាយតាមវិទ្យុ។ នេះជាបទបញ្ជាមួយ។ ដល់ទៅខ្ញុំក៏ចាប់ផ្តើមធ្វើ។ ខ្ញុំនៅចងចាំបានថា អ្នកទោសវៀតណាមដែលយកទៅសួរចម្លើយ ហើយថតដាក់ខ្សែអាត់ដំបូងគេនោះ ឈ្មោះ វ៉ូ ឌិញង៉ោ ៗ មកដល់ស-២១ ថ្ងៃ៦ មករា ១៩៧៨។ នេះក៏ចាប់ផ្តើមដំណើរការងាររហូតមក មួយអាទិត្យឲ្យបានពីរនាក់ជូនគាត់។ ហ្នឹង គឺខ្ញុំសូមបញ្ចប់ប៉ុណ្ណឹង។

[០៩:៥៩:៤៨]

**ស៖** តើលោកដឹងអំពីការផ្សព្វផ្សាយតាមវិទ្យុ ដែលមេដឹកនាំបានប្រើប្រាស់ដើម្បីប្រឆាំងទៅនឹងជនជាតិភាគតិចវៀតណាម ដែលជាជនជាតិស៊ីវិលរស់នៅក្នុងប្រទេសកម្ពុជា លោកបានដឹងទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ការរើសអើងៗចំពោះអាណិកជនវៀតណាមនៅកម្ពុជា វាត្រូវចាប់ផ្តើមឡើងក្រោយ ១៧ មេសា បន្តិចដោយ លន់ នល់ ដេញចេញទៅ តាមរយៈ មិន

ដឹងជាអង្គការស្អីទេ កាកបាតក្រហមក៏មិនដឹង អង្គការជនភៀសខ្លួនក៏មិនដឹង គាត់ដេញចេញ គាត់ចាប់ប្រមូលវៀតណាមដេញចេញទៅ។ ឯចំណែកនៅក្នុងតំបន់រំដោះ ឆ្នាំ១៩៧៨ (សូមទោស) ឆ្នាំ១៩៧៣ ឆក់ឱកាសដែល ឡុន ណុល យន់ គាត់ស្នើសុំអាណិកជនវៀតណាមយកទៅបោះឆ្នោត ប៉ុល ពត ដេញបណ្ដោយមិនដេញត្រឹមតែអាណិកជនវៀតណាមទេ វាដេញទាំងពួកកងទ័ពវៀតណាម ដែលស្នាក់អាស្រ័យនៅកម្ពុជា ហើយនិងពួកមន្ទីរវៀតណាមផង។ ដូច្នេះ ១៩៧៣ ហ្នឹងអស់ ការដេញអាណិកជនវៀតណាមទាំងខាង ប៉ុល ពត ទាំងខាង លន់ នល់ នេះ គ្មានផ្សព្វផ្សាយតាមទូរទស្សន៍-- អ៎! វិទ្យុអីទេ។

[១០:០១:៣៣]

**ស៖** នៅពេលដែលលោកផ្ដល់ភស្ដុតាងពីខាងដើមគឺថា ប៉ុល ពត បានបញ្ជាឲ្យមានការបំបាត់ជនជាតិវៀតណាមចេញពីប្រទេសកម្ពុជា ឬក៏បណ្ដេញចេញពីប្រទេសកម្ពុជា តាមដែលលោកដឹង និងការកត់សម្គាល់របស់លោក តើលោកស្មានថា គេបញ្ជូនប្រជាជនវៀតណាមចេញទៅវិញនោះ ប្រហែលជាប៉ុន្មាននាក់ដែរ?

**ឆ៖** សូមបញ្ជាក់-- សូមទោស។ សូមអរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឲ្យតែសំណួរចូលអំពីចំនួន ខ្ញុំអត់ឆ្លើយរួចទេ ព្រោះខ្ញុំមិនមែនជាអ្នកអនុវត្តជាក់ស្ដែង ពេលនោះខ្ញុំនៅមន្ទីរ១៣ ដល់ក្រោយមកប្រហែលជាក្នុងឆ្នាំ១៩៧៧ ឬអីទេ ទើប ប៉ុល ពត គាត់បើកវគ្គ-- គាត់និយាយក្នុងវគ្គឧទ្ទេសនាមមួយ និយាយឲ្យចំ គឺ សុន សេន គាត់និយាយក្នុងវគ្គឧទ្ទេសនាមមួយ ថា តាំងពីជាតិណាមកយើងមិនដែលបានបញ្ចេញអាណិកជនវៀតណាមឲ្យចេញពីកម្ពុជាដូច្នេះទេ។ នេះជារឿងពិត ដែលខ្ញុំដឹង ដឹងមកក្រោយនោះទេ ដូច្នេះឲ្យតែនិយាយពីរឿងចំនួន រឿងអីក៏ដោយ ខ្ញុំមិនដែលបានដឹងច្បាស់លាស់មិនអាចប៉ាន់ប្រមាណបានទេ។ ខ្ញុំសូមចប់។

[១០:០៣:០៦]

**ស៖** តាមបទពិសោធន៍របស់លោកនៅពេលនោះ តើលោកនៅចាំគោលនយោបាយណាមួយដែលចេញដោលបក្សកុម្មុយនីស្ដកម្ពុជា ដើម្បីកម្ចាត់ និងបំបាត់ជនជាតិវៀតណាម ភាគតិចវៀតណាមនៅក្នុងប្រទេសកម្ពុជាដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នៅក្នុងបក្សកុម្មុយនីស្ដកម្ពុជា មិនដែលចាត់ទុកជនជាតិវៀត-- អាណិកជនវៀតណាមថា ជាជនជាតិភាគតិចទេ។ បើចាមមែន បក្សកុម្មុយនីស្ដកម្ពុជាចាត់ទុកជាជនជាតិភាគតិច។ ដូច្នេះ ខ្ញុំសូមបញ្ជាក់តែប៉ុណ្ណឹងទេបន្ថែម ហើយសំណួររបស់មេធាវី

ខ្ញុំវង្វេងហើយ បើចង់ដឹង សូមសួរបញ្ជាក់ថែមទៀតមក។

[១០:០៤:១៧]

**កញ្ញា លី ម៉ាញៀន៖**

ខ្ញុំសូមអធ្យាស្រ័យលោកប្រធាន ដោយសារតែ*អៀហួន* របស់ខ្ញុំហ្នឹងគឺថា វាអស់ថ្មអីចឹង ខ្ញុំសូមសួរម្តងទៀត។

**សួរដោយកញ្ញា លី ម៉ាញៀន៖**

**ស៖** ខ្ញុំសូមឱ្យលោកនិយាយឡើងវិញ ជាសង្ខេបបានទេ នូវអ្វីដែលលោកទើបនិយាយអម្បាញ់មិញនេះ។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន រឿងដែលខ្ញុំនិយាយអម្បាញ់មិញនេះ គឺបក្សកុម្មុយនីស្តកម្ពុជា មិនដែលទុកយួន ដែលរស់នៅក្នុងទឹកដីខ្មែរថាជា ជនជាតិភាគតិចទេ គឺចាត់ទុកជាអាណិកជន គេហៅថា អាណិកជនយួន អាណិកជនចិន អាណិកជនវៀតណាម អាណិកជនចិន។ ដោយឡែកបើនិយាយពីចាមវិញ មែន គេចាត់ទុកជាជនជាតិភាគតិច។ ក៏ប៉ុន្តែសំណួររបស់មេធាវីសួរខ្ញុំតទៅទៀតជុំវិញបញ្ហានេះ ខ្ញុំវង្វេងហើយសូមមេត្តាសួរម្តងទៀតចុះ!

**ស៖** លោកទើបលើកឡើងថា ជនបក្សកុម្មុយនីស្តកម្ពុជាគឺបានចាត់ទុកជនជាតិចាមជាជនជាតិភាគតិច តើទាក់ទងទៅនឹងចាមនេះ គេមានកំណត់អំពីចាមដែលមានសញ្ជាតិខ្មែរ ឬក៏ចាមមិនមានសញ្ជាតិខ្មែរទេ ឬក៏ពាក់ព័ន្ធទៅនឹបញ្ហាជាតិពន្ធុ ឬក៏អ្វីមួយនោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ចាមជាទូទៅខ្មែរយើងចាត់ទុកជាជនជាតិភាគតិច។ ជំនាន់សីហនុ គាត់ហៅខ្មែរអ៊ីស្លាម ឯចំណែកជំនាន់ ប៉ុល ពត នេះខ្ញុំឃើញថា គេហៅប្រជាជនអ៊ីស្លាម។ នៅតែអ៊ីស្លាមដូចគ្នា នៅចាត់ទុកជាជនជាតិភាគតិចដូចគ្នាហ្នឹង។

[១០:០៦:២៦]

**ស៖** តាមចំណេះដឹង បទពិសោធន៍ និងការកត់សម្គាល់របស់លោកនោះ ក្នុងនាមលោកផ្ទាល់នៅក្នុងបក្សនោះ តើលោកអាចនិយាយបានថាគេប្រព្រឹត្តមកលើចាម ដោយមានការរើសអើង ឬក៏ថាគេអ្នកទាំងនោះត្រូវគេធ្វើទុក្ខមុកម្នេញ ឬក៏ប្រព្រឹត្តខុសពីអ្នកដទៃទៀតដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ពីឆ្នាំ១៩៤៥ ដល់១៩៥៤ បក្សប្រជាជនបដិវត្តន៍កម្ពុជា មានគោលនយោបាយមួយប្រមូលកម្លាំងចាមឱ្យចូលរួមការបដិវត្ត។ វីរជនចាមដែល

លេចឈ្មោះជំនាន់នោះមានពីរនាក់គឺ ម៉ាត់ លី និងតាម៉ាន។ តាម៉ានហ្នឹងឪពុកបង ម៉ាត់ លី។ ក្រោយឆ្នាំ ១៩៥៤ បក្សកុម្មុយនីស្តកម្ពុជាទុកចាមចោល អត់មានគោលនយោបាយប្រមូលកម្លាំងចាមទេ។ ទុកចោលមួយដោយឡែកទៅ។ ពីឆ្នាំ១៩៧០ ដល់១៩៧៥ បក្សកុម្មុយនីស្តកម្ពុជានៅតែទុកចាមដោយឡែកដដែលទេ។

[១០:០៧:៤៩]

ដូច្នេះចាមបែក នៅពេលរដ្ឋប្រហារហ្នឹងចាមបែកខ្ញែក មួយចំនួនចាមទៅធ្វើទាហានឲ្យ លន់ នល់។ ជាក់ស្តែង សុះ ម៉ាត់ គាត់ពាក់ស័ក្តិបីបញ្ជាការអនុសេនាធំស្រះស្រង់ ប្រតិបត្តិការការពារផ្លូវលេខ៥ ចន្លោះពីឧដុង្គទៅលង្វែក។ ដោយឡែកនៅតំបន់២៥ មានយុវជនចាមមួយចំនួនដែលស្នេហាបដិវត្តន៍ចូលធ្វើកងទ័ព។ ដល់ក្រោយមក ក្រោយ ១៧ មេសា ១៩៧៥ ទើបឃើញនយោបាយមួយជម្លៀសពួកម៉ូស្លីមទាំងអស់ ចាមក៏ដោយ មិនចាមក៏ដោយចេញពីដងទន្លេ និងពីតាមបណ្តោយព្រំដែនខ្មែរវៀត យកទៅឧត្តរ និងយកទៅពាយ័ព្យ។ ដូច្នេះការបំបែកបែបនេះ ក្នុងវត្ថុបំណងតែមួយទេ គឺយកចាម យកពួកម៉ូស្លីមទៅលត់ដំក្នុងពលកម្ម ហើយឲ្យម៉ូស្លីម រសាយអំពីអ៊ីស្លាម។ បដិសេធអ៊ីស្លាម ឬក៏មិនប្រតិបត្តិអ៊ីស្លាម មិនប្រតិបត្តិជំនឿសាសនា។ នេះខ្ញុំសូមសរុបប៉ុណ្ណឹង។

[១០:០៩:២២]

**ស៖** ក្នុងរដ្ឋធម្មនុញ្ញមានផ្នែកមួយពាក់ព័ន្ធទៅនឹងសាសនា ហើយនិងក៏និយាយអំពីសាសនាប្រតិកិរិយាដែរ តើសាសនាអ៊ីស្លាម និងសាសនាព្រះពុទ្ធនេះ ត្រូវបានបក្សចាត់ទុកថាជាសាសនាប្រតិកិរិយាដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សាសនាព្រះពុទ្ធ ហើយនិង អ៊ីស្លាម ក៏ដូចជាខុងជឺ និយមក៏ដោយ បក្សកុម្មុយនីស្តកម្ពុជាមិនចាត់ទុកជាសាសនាប្រតិកិរិយាទេ។ ចាត់ទុកសាសនាប្រតិកិរិយា គឺគ្រិស្តសាសនា ទាំងកាតូលិក ទាំងប្រ៊ូតេស្តង់។

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអស់ពេលហើយ។

សូមអញ្ជើញលោកតំណាងព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមគោរព លោក លោកស្រីចៅក្រម អស់លោក លោកស្រី។ សហព្រះរាជអាជ្ញានៅពេលនេះ

សូមសួរបញ្ជាក់ចំពោះនីតិវិធីក្នុងការដាក់ចម្លើយមុនៗរបស់សាក្សី។ យើងមិនមែននិយាយអំពីចម្លើយរបស់សាក្សីរូបនេះជាក់លាក់តែមួយប៉ុណ្ណោះនោះទេ។ កាលពីម្សិលមិញអង្គជំនុំជម្រះបានបញ្ជាក់ហើយថា នឹងត្រូវឲ្យយើងខ្ញុំដាក់ចម្លើយ ការស្ដាប់ចម្លើយ-- កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីទាំងឡាយនៅចំពោះមុខអង្គជំនុំជម្រះ ហើយត្រូវកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់។ ចៅក្រម ឡាវែន៍បញ្ជាក់ថាការដាក់ចម្លើយនេះគឺ ធ្វើឡើងនៅពេលដែលសាក្សីមានវត្តមាននៅចំពោះអង្គជំនុំជម្រះ។ ដូច្នេះខ្ញុំសូមសួរបញ្ជាក់ថា តើសេចក្ដីសម្រេចនេះមានអានុភាពយ៉ាងម៉េចទៅលើអនុស្សរណៈថ្ងៃទី២ គឺឯកសារ E72/5 ដែលក្នុងនោះលើកឡើងអំពីរបៀបការដាក់ឯកសារនៅចំពោះអង្គ មុខអង្គជំនុំជម្រះ។

[១០:១២:១៥]

អង្គជំនុំជម្រះបានកំណត់ប្រព័ន្ធមួយដែលថា ភាគីដាក់ឯកសារនៅក្នុងសវនាការជាក់លាក់ពិសេសណាមួយ។ សវនាការពិសេសជាក់លាក់នេះបានរៀបចំរួចមកហើយ។ម្យ៉ាងវិញទៀតពាក់ព័ន្ធទៅនឹងឯកសារ ដែលសហព្រះរាជអាជ្ញាចង់ដាក់ក្រៅពីឧបសម្ព័ន្ធ១២ និង ១៣ យើងដឹងហើយថាឧបសម្ព័ន្ធ១២ គឺជាចម្លើយ-- កំណត់ហេតុចម្លើយសាក្សី។ ឧសម្ព័ន្ធ១៣ គឺពាក្យបណ្ដឹង។ នៅក្នុងសេចក្ដីសម្រេចថ្ងៃ-- ឆ្នាំ២០១២ ខែមីនា ឧបសម្ព័ន្ធ១២ និង១៣ នឹងត្រូវចេញនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ហើយនៅដល់ដំណាក់កាលនេះមិនទាន់បានធ្វើការកំណត់ការដេញដោលផ្ទាល់មាត់នៅឡើយនោះទេ។

[១០:១៣:០៧]

នៅក្នុងសេចក្ដីសម្រេចត្រង់កថា៧ ការណែនាំនោះក៏បានលើកឡើងអំពីឯកសារដែលលើកឡើងដោយមេធាវីការពារក្ដី នួន ជា ដែលមាននៅក្នុងឧបសម្ព័ន្ធ១២ និង១៣ ដែលក្នុងនោះរួមមានចម្លើយកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី រួមទាំងសាក្សីរូបនេះផងដែរ។ ក្រោយពីការចេញសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ សេចក្ដីសម្រេចទាំងអស់នេះបានបញ្ជាក់ទៅលើចំណុចទាំងអស់នេះ។

សហព្រះរាជអាជ្ញាកំពុងតែសន្មតថា ឯកសារទាំងឡាយបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចមកហើយ ហើយអង្គជំនុំជម្រះនឹងសេចក្ដី-- នឹងចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរ។ អង្គជំនុំជម្រះបានលើកឡើងផងដែរ អំពីឧបសម្ព័ន្ធ១២ និង១៣។

[១០:១៤:០៥]

ដូច្នេះសហព្រះរាជអាជ្ញាចង់ចោទសួរថា តើសហព្រះរាជអាជ្ញា ឬក៏ភាគីរង់ចាំសេចក្ដីសម្រេច

ជាលាយលក្ខណ៍អក្សរនេះសិន ពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធ១២ ឬក៏យ៉ាងម៉េច? ឬក៏នៅក្នុងដំណាក់កាលនេះ យើងធ្វើតាមនីតិវិធីដែលថាសាក្សី ដែលមកផ្តល់ចម្លើយនៅក្នុងតុលាការត្រូវតែយើងដាក់ចម្លើយកំណត់ហេតុចម្លើយមុនៗតែម្តងនៅពេលដែលសាក្សីមានវត្តមាន?

[១០:១៤:៣៧]

ចំណុចមួយទៀតដែលខ្ញុំសូមបញ្ជាក់បំភ្លឺផងដែរនៅក្នុងកថាខណ្ឌ៤ នៃឯកសារ E72/5 ក្នុងនោះចែងថា ឯកសារកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលមកផ្តល់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញត្រូវបានកំណត់នៅក្នុងអនុស្សរណៈ E172/5។

ដូច្នេះឯកសារទាំងអស់នោះត្រូវបានចាត់ទុកថាដាក់នៅចំពោះមុខអង្គជំនុំជម្រះ លើកលែងតែមានភាគីណាមួយជំទាស់ក្នុងពេលផ្តល់សក្ខីកម្មដោយ សាក្សី អ្នកជំនាញ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ។ ដូច្នេះយោងតាមកថាខណ្ឌ៤ នេះ តើខ្ញុំសន្និដ្ឋាន-- បានន័យថានៅពេលដែលសាក្សីចូលខ្លួនក្នុងតុលាការ កំណត់ហេតុលាយលក្ខណ៍អក្សរ ស្តាប់ចម្លើយមុនៗ នឹងត្រូវបានដាក់ដោយស្វ័យប្រវត្តិនៅចំពោះមុខអង្គជំនុំជម្រះ ដរាបណាមិនមានការជំទាស់ពីភាគី ឬក៏យ៉ាងម៉េច? ប្រសិនបើដូច្នេះមែនយើងត្រូវគិតអំពីលក្ខខណ្ឌ ភាគីទាំងឡាយរួមទាំងសហព្រះរាជអាជ្ញា ត្រូវគិតអំពីលក្ខខណ្ឌដែលយើងត្រូវតែពិនិត្យរកមើលឯកសារមុនៗ ដែលជាកំណត់ហេតុសាក្សីទាំងអស់នេះមុនពេលដែលពួកគាត់មកផ្តល់ចម្លើយ។

[១០:១៦:០២]

ក៏ប៉ុន្តែប្រសិនបើមិនអ៊ីចឹងទេ ពាក់ព័ន្ធទៅនឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរ ស្តាប់ចម្លើយមុនៗនៅក្នុងឧបសម្ព័ន្ធ១២ និង១៣ សហព្រះរាជអាជ្ញាចាំបាច់ត្រូវការដាក់ចម្លើយទាំងអស់នោះនៅចំពោះមុខអង្គជំនុំជម្រះ ដែលវាមិនត្រូវបានកំណត់ទៅតាមកថាខណ្ឌ១៤។ ដូច្នេះសហព្រះរាជអាជ្ញាសូមអនុញ្ញាតធ្វើការដាក់ឯកសារកំណត់ហេតុជាចម្លើយទាំងអស់នេះនៅចំពោះមុខអង្គជំនុំជម្រះ។ ក៏ប៉ុន្តែមុនពេលដែលយើងដាក់កំណត់ហេតុសួរចម្លើយ ស្តាប់ចម្លើយទាំងអស់នោះ យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះបញ្ជាក់ឲ្យបានច្បាស់លាស់សិនថា តើយើងខ្ញុំត្រូវរង់ចាំសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើឧបសម្ព័ន្ធ១២ ជាមុនសិន ឬក៏យ៉ាងម៉េច? ឬក៏អនុស្សរណៈដែលបាន ខ្ញុំបានបញ្ជាក់នោះ វាឲ្យយើងខ្ញុំសន្និដ្ឋានដូចដែលខ្ញុំបានបញ្ជាក់ខាងដើម? ហើយបានន័យថា ចម្លើយទាំងឡាយ កំណត់ហេតុស្តាប់ចម្លើយទាំងឡាយរបស់សាក្សីត្រូវ បានចាត់ទុកថាដាក់ដោយស្វ័យប្រវត្តិ នៅពេលដែលសាក្សីនោះមក

ផ្តល់សក្ខីកម្មក្នុងតុលាការឬក៏យ៉ាងណា?

[១០:១៧:០៨]

ឯកសារ E9/31 គឺយើងឃើញបានដាក់ហើយនៅក្នុងខែមីនា ឆ្នាំ២០១២ ដូច្នេះហើយខ្ញុំសូមឱ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់បំភ្លឺទៅលើអ្វីដែលខ្ញុំបានលើកឡើង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីអន្តរជាតិការពារក្តី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើនលោកប្រធាន។ ខ្ញុំសូមគាំទ្រសំណើសុំរបស់សហព្រះរាជអាជ្ញាឱ្យបញ្ជាក់បំភ្លឺ។ យើងពិតជាត្រូវការ មានសេចក្តីសម្រេចជាក់លាក់ទៅលើចំណុចនេះថា តើយើងខ្ញុំត្រូវគិតគូរយ៉ាងណាចំពោះការដាក់កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី នៅចំពោះមុខអង្គជំនុំជម្រះ?

យើងក៏ចាប់អារម្មណ៍ទៅលើចំណុចមួយទៀត ដែលបានលើកឡើងដោយមេធាវីខាង ខៀវ សំផន-- មេធាវីអន្តរជាតិ ខៀវ សំផន កាលពីម្សិលមិញ។ ចំណុចដែលយើងខ្ញុំចាប់អារម្មណ៍មួយនេះគឺថា តម្លៃជាភស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយទាំងឡាយ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះមានតម្លៃយ៉ាងម៉េច?

[១០:១៨:១៦]

ដែលចម្លើយទាំងអស់នោះមិនត្រូវបានយកមកពិភាក្សានៅក្នុងតុលាការយើងនោះ។ ខ្ញុំសូមបញ្ជាក់ឱ្យបានច្បាស់ជាងនេះបន្តិច យើងនៅក្នុងការជំនុំជម្រះលើកដំបូង វគ្គដំបូង ហើយយើងមិនត្រូវបានអនុញ្ញាតឱ្យសាកសួរដេញដោលសាក្សីនេះលម្អិតទៅលើ-- នៅក្នុងរបៀបវារៈ ជាពិសេសលើបញ្ហា ស-២១ ទាំងមូល។

តើតម្លៃនៃកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីរូបនេះ ដែលចម្លើយទាំងអស់នោះគឺបាននិយាយអំពីប្រធានបទ ដែលមិនយកមកដេញដោលនៅក្នុងសវនាការវគ្គដំបូងនេះផងដែរនោះ។ ថាតើអង្គជំនុំជម្រះនឹងផ្អែកទៅលើចម្លើយទាំងអស់នោះដែរឬទេ នៅក្រៅវគ្គសវនាការដំបូងរបស់យើង? ហើយអង្គ-- មេធាវីរបស់យើងមិនបានធ្វើការដេញដោលទៅលើអង្គហេតុក្រៅពីវគ្គដំបូងនេះផងនោះ? យើងដឹងហើយថា សាក្សីរូបនេះបានដឹងច្រើនណាស់អំពី ស-២១ ហើយបញ្ហាមួយចំនួនមិនត្រូវបានយើងយកមកដេញដោលនោះឡើយ។ យើងមិនបានដឹងលម្អិត នៅពេលដែលយើងពិភាក្សាទៅលើ ស-២១។ យើងខ្ញុំ

សូមលើកឡើងថាសាក្សីរូបនេះត្រូវតែមកម្តងទៀតនៅពេលដែលយើងដាក់ប្រធានបទ ស-២១ ផ្នែកផ្សេងទៀតមកដេញដោល។

[១០:១៩:៥០]

ដូច្នេះ វា ខ្ញុំមិនមែនលើកឡើងថាយើងនឹងដាក់កំណត់ហេតុចម្លើយរបស់សាក្សីរូបនេះនៅចំពោះមុខអង្គជំនុំជម្រះនោះទេ ក៏ប៉ុន្តែខ្ញុំសូមសួរថាតើអង្គជំនុំជម្រះនឹងផ្អែកទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីរូបនេះផ្សេងទៀតដែរឬទេ ដែលយើងខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យដេញដោលទៅលើសាក្សីរូបនេះផងនោះត្រង់ផ្នែកទាំងអស់នុ៎ង? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកកាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ យើងក៏សូមឲ្យមានការបញ្ជាក់បំភ្លឺផងដែរ តាមអ្វីដែលខ្ញុំយល់សំណើសុំរបស់សហព្រះរាជអាជ្ញាមានលក្ខណៈខុសពីម្សិលមិញ។ កាលពីម្សិលមិញ គឺនិយាយអំពីសក្ខីកម្ម ដែលសាក្សីរូបនេះបានផ្តល់នៅក្នុងសវនាការមុនៗ ក៏ប៉ុន្តែនៅពេលនេះសហព្រះរាជអាជ្ញានិយាយអំពីកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី។ បញ្ហាដែលខ្ញុំមើលឃើញពីខាងសហព្រះរាជអាជ្ញា យើងដឹងហើយថា សហព្រះរាជអាជ្ញាប្រហែលចំណាយពេលរហូតដល់ប្រាំមួយថ្ងៃនោះ ដេញដោលទៅលើសាក្សីរូបនេះលើបញ្ហាជាច្រើន។ បន្ថែមទៅលើចំណុចនេះ សហព្រះរាជអាជ្ញាចង់យកកំណត់ហេតុស្តាប់ចម្លើយដែលសាក្សីរូបនេះផ្តល់ជាងប្រាំមួយ ប្រាំពីរឆ្នាំកន្លងមកហើយ យកមកដាក់បញ្ចូលនៅក្នុងអង្គជំនុំជម្រះនេះ។

[១០:២១:១៧]

ដូច្នេះ នៅពេលដែលយើងខ្ញុំធ្វើការសួរដេញដោលឆ្លងសាក្សីរូបនេះ យើងដឹងហើយថា យើងខ្ញុំនឹងសួរដេញដោលទៅលើសាក្សីរូបនេះ ឆ្លងតាមអ្វីដែល-- ផ្អែកទៅតាមអ្វីដែលសហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណីបានសាកសួរ ហើយនិងបន្ថែមទៅលើចំណុចមួយចំនួន ដែលខ្ញុំរកឃើញនៅក្នុងចម្លើយ ដើម្បីសួរដេញដោលទៅលើសាក្សីរូបនេះបន្ថែមទៀត។

អ្វីដែលសហព្រះរាជអាជ្ញាបានស្នើសុំ គឺវាមិនអាចឲ្យផ្តល់លទ្ធភាពទៅដល់មេធាវីការពារក្តី ទៅលើអ្វីដែលពួកគាត់ចង់ព្យាយាមធ្វើនេះទេ។ ប្រសិនបើភស្តុតាងផ្តល់ចម្លើយដោយសាក្សីតាមអ្វីដែលគាត់

បានយល់ និងបទពិសោធន៍របស់គាត់ ឬក៏ផ្ដល់តាមរយៈសំណុំរឿងដែលគាត់បានពិនិត្យមើលនោះ យើងឯកភាពថានៅក្នុងពេលណាមួយ កំណត់ហេតុនៃការស្ដាប់ចម្លើយគួរតែដាក់បញ្ចូលបន្ថែម។ ក៏ប៉ុន្តែយើងត្រូវតែបង្ហាញផងដែរ ហេតុអ្វីបានជាកំណត់ហេតុស្ដាប់ចម្លើយទាំងអស់នោះ មិនបង្ហាញជូនសាក្សីរូបនេះ នៅពេលដែលគាត់មកផ្ដល់ចម្លើយសក្ខីកម្ម និងដេញ-- ត្រូវបានដេញដោល។

[១០:២២:៣៣]

វាធ្វើ-- យើងដឹងហើយថា ប្រាកដជាមានការលើកឡើងថា ដោយសារពេលវេលា យើងមិនអាចដេញដោលគ្រប់ទាំងអស់ទៅលើកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីរូបនេះ នោះឡើយ។ ដូច្នេះហើយទើបយើងខ្ញុំស្នើសុំដាក់បញ្ចូលកំណត់ហេតុស្ដាប់ចម្លើយទាំងអស់នេះ។ ក៏ប៉ុន្តែប្រសិនបើមិនដូច្នេះ ដូចដែលខ្ញុំបានលើកឡើងនោះទេ ដូចដែលអ្វីដែលសហព្រះរាជអាជ្ញាលើកឡើងនោះទេ សហព្រះរាជអាជ្ញាគាត់បានទុកចោលកំណត់ហេតុស្ដាប់ចម្លើយមួយចំនួន ហើយសង្ឃឹមថា កំណត់ហេតុនោះនឹងដាក់ចូលអង្គជំនុំជម្រះដោយស្វ័យប្រវត្តិ ហើយអាចឱ្យពួកគាត់ផ្ដល់ យកមកធ្វើជាមូលដ្ឋាន។

[១០:២៣:១២]

ដូច្នេះចំណុចនេះ វាជាគុណវិបត្តិសម្រាប់យើងខ្ញុំ។ សហព្រះរាជអាជ្ញា គាត់ចង់បង្ហាញដាក់បញ្ចូលរឿងក្ដីទាំងអស់នេះ។ គាត់ចង់យកវិធីទាំងពីរនេះតែម្ដង។ អង្គជំនុំជម្រះត្រូវតែជម្រាបជូនដំណឹងទៅដល់ភាគី ថាតើឯកសារទាំងឡាយដែលយកមកដាក់បញ្ចូល គឺយកផ្នែកទាំងអស់ ឬក៏យ៉ាងម៉េច? ឬក៏ផ្នែកនៃសំណុំរឿងដែលបានដាក់បញ្ចូល គឺជាកម្មវត្ថុនៃការសុំអនុញ្ញាត និងជាកម្មវត្ថុក្នុងការស្នើសុំបញ្ជាក់ឱ្យបានច្បាស់លាស់ថាតើហេតុអ្វីឯកសារទាំងអស់នោះ ឬក៏កំណត់ហេតុចម្លើយ ស្ដាប់ចម្លើយទាំងអស់នោះ មិនត្រូវបានយកមកបង្ហាញសាក្សីសម្រាប់ដេញដោលឱ្យបានរួចជាស្រេច?

សូមអរគុណត្រង់ចំណុចទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្ដីលោកខៀវ សំផន!

[១០:២៤:១១]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមគាំទ្រចំពោះសំណើដែលឱ្យអង្គជំនុំជម្រះសម្រេចទៅលើនីតិវិធីនៃការកំណត់អំពីចម្លើយរបស់សាក្សីនេះ។ យើងដូចអង្គជំនុំជម្រះបានជ្រាបហើយថា

សាក្សីជាទូទៅគឺមានចម្លើយច្រើន គឺលើសពីមួយ ហើយដូចជាក់ស្តែង ដូចសាក្សីលោក ឌុច នេះមានចម្លើយដល់ទៅ៦០ជាង។ ដូច្នេះ បើសិនជាការមិនបានបង្ហាញឲ្យជាក់លាក់នៅក្នុងសវនាការនេះទេ ហើយយើងចេះតែទទួលយកចម្លើយទាំងអស់នោះមកពិចារណា គឺឃើញថាវាមានភាពស្មុគស្មាញច្រើន វាទាំងចម្លើយខ្លះវាមានភាពផ្ទុយគ្នានោះផងដែរ។ ហើយខ្ញុំជឿថា កាលពីម្សិលមិញ លោកប្រធានបានរំឭកអំពីវិធាន៨៧(៣) ដែលបង្ហាញពីភាពអាចទទួលយកបាន ដែលអង្គជំនុំជម្រះនឹងលើកយកភស្តុតាងទាំងឡាយយកមកពិចារណានោះ ដែលធ្វើជាមូលដ្ឋានថា ទាល់តែមានការសួរដេញដោល ឬយ៉ាងហោចណាស់ក៏សង្ខេបទៅលើខ្លឹមសារនៃភស្តុតាងទាំងអស់នោះ ឬឯកសារទាំងនោះ ដើម្បីអាចឲ្យក្រុមប្រឹក្សាជំនុំជម្រះធ្វើការសម្រេច អាចធ្វើជាភស្តុតាងបាន។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ហើយសូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១០:២៥:៥៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំសូមសារភាពថា ខ្ញុំនៅតែភ្ញាក់ផ្អើលនូវការវិវត្តន៍នៃការពិភាក្សាគ្នារបស់យើងដដែល នៅក្នុង-- ជាពិសេសគឺថាការស៊ើបអង្កេតនៅដំណាក់កាលស៊ើបអង្កេតនេះជាដើម។ ខ្ញុំហាក់ដូចជាយល់ឃើញថា អង្គជំនុំជម្រះបានបញ្ជាក់ហើយថា កំណត់ហេតុស្តាប់ចម្លើយ ដែលធ្វើដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដំណាក់កាលស៊ើបអង្កេតនោះ ត្រូវចាត់ទុកថា ត្រូវបានបង្ហាញនៅក្នុងអង្គជំនុំជម្រះរួចហើយ នៅពេលដែលភាគីទាំងអស់គ្នានោះបានស្តាប់សាក្សី ហើយប៉ុន្តែ នែ៎! កំណត់ហេតុស្តាប់ចម្លើយរបស់លោក កាំង ហ្កេកអ៊ាវ នេះគឺថា បាន-- គាត់បានមកទីនេះហើយ។ អ៊ីចឹងថាតើខាងភាគីទាំងអស់គ្នានេះយល់ឃើញយ៉ាងម៉េច? យើងប្រើចម្លើយរបស់គាត់ ឬក៏មិនប្រើ? ប្រើដោយផ្នែក ឬមិនដោយផ្នែក? ទាំង ភាគីទាំងអស់គ្នា ដូចគ្នាទាំងអស់ ក៏ប៉ុន្តែផ្ទុយទៅវិញ ខ្ញុំគិតថា វាជាការសំខាន់ណាស់ដែលអង្គជំនុំជម្រះត្រូវបញ្ជាក់ថាមាន ត្រូវតែមានការបែងចែកច្បាស់លាស់រវាងកំណត់ហេតុស្តាប់ចម្លើយ ហើយនិងសេចក្តីប្រកាសផ្សេងៗទៀតជាលាយលក្ខណ៍អក្សរ ដែលបុគ្គលណាម្នាក់បានធ្វើឡើង គឺថារាល់សេចក្តីប្រកាសដែលពុំមានតម្លៃជាច្បាប់ដូចកំណត់ហេតុស្តាប់ចម្លើយ ពីព្រោះថាកំណត់ហេតុស្តាប់ចម្លើយនេះជាភស្តុតាងរបស់សំណុំរឿង។ ហើយអង្គជំនុំជម្រះបានលើកលើងច្រើនដងហើយ អ៊ីចឹងហើយបានជាខ្ញុំមានការភ្ញាក់ផ្អើល។ ហើយ

ទាក់ទងទៅនឹងតម្លៃជាភស្តុតាងនេះ អានេះជាអង្គជំនុំជម្រះអ្នកសម្រេចនោះទេ ហើយយើងមិនបាច់ពិភាក្សាគ្នានោះទេ។ យើងទាំងអស់គ្នាអាស្រ័យតាមអង្គជំនុំជម្រះ។ ក៏ប៉ុន្តែ ទោះបីយ៉ាងណា ខ្ញុំនៅតែគិតថាកំណត់ហេតុស្តាប់ ចម្លើយនេះ គឺថាយើងត្រូវតែរំឭកសាជាថ្មីទៀតថា ត្រូវរំឭកអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះម្តងទៀត។

[១០:២៨:០៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីណ្ស៊ៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាមានពីរចំណុច។ ថាតើនីតិវិធីអ្វីដែលត្រូវដាក់ឯកសារនៅចំពោះអង្គជំនុំជម្រះនោះ។ ដូចយើងខ្ញុំបាន-- តាមអនុស្សរណៈគឺយើងថា សន្មតថា ឯកសារទាំងនេះបានដាក់នៅមុខអង្គជំនុំជម្រះហើយ។ ប្រសិនណាមិនច្បាស់ទេ យើងខ្ញុំសុំការបញ្ជាក់ពីអង្គជំនុំជម្រះ។ មួយទៀត គឺថាតើការជំទាស់ទៅនឹងចម្លើយសារភាពទាំងអស់ហ្នឹង។ ទីមួយគឺចង់សុំការបញ្ជាក់ថាតើនីតិវិធីយ៉ាងម៉េច ដែលត្រូវចាត់ចែងនេះ? ហើយទីពីរថាចម្លើយរបស់សាក្សីពីមុនៗនេះ គឺចាត់ទុកថាដាក់មុខចំពោះអង្គជំនុំជម្រះទេ? គឺឯកសារ E172/5។

[១០:២៩:១៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣១:២១]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដោយមានបញ្ហាចោទឡើងដោយភាគី ពាក់ព័ន្ធនឹងឯកសារកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលបានធ្វើនៅក្នុងដំណាក់កាលមុនៗ គឺចំពោះមុខចៅក្រមស៊ើបអង្កេត ហើយក៏ដល់ពេលវេលាសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកកន្លះម៉ោង ដោយចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ ហើយសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យអញ្ជើញ កាំង ហ្គេកអ៊ាវ ហៅ ឌុច ហ្នឹងទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សីហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការវិញនៅម៉ោងដប់មួយ។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមអរគុណ។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ដោយសារបញ្ហាសុខភាព ជាពិសេសបញ្ហាឈឺចង្កេះ ឆ្អឹងខ្នង ឈឺជើង លោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការសម្រាប់ថ្ងៃនេះពេញតែម្តង។ ក៏ប៉ុន្តែសុំសិទ្ធិចូលរួមដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាពិចារណា និងសម្រេច សូមអរគុណ។

[១០:៣២:៤៤]

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ពីបន្ទប់មួយខាងក្រោមបន្ទប់សវនាការនេះ ក្នុងរយៈពេលពេញមួយថ្ងៃចាប់ពីពេលនេះទៅ រហូតដល់ចប់សវនាការសម្រាប់ថ្ងៃនេះ។ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់យូរបាន។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈពេលមេធាវីរបស់គាត់ ក្នុងការលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់ពេញមួយថ្ងៃនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី អៀង សារី ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយចុះហត្ថលេខា ឬក៏ផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី ហើយនិងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ តាមដានកិច្ចដំណើរការសវនាការពីចម្ងាយពេញមួយថ្ងៃរសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោម ដែលរៀបចំទុកជាមុននូវឧបករណ៍សោតទស្សន៍សម្រាប់គាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយចុះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

ក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៤ នាទី ដល់ម៉ោង ១១:១៦ នាទី)*

[១១:១៦:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ហើយមុននឹងផ្តល់វេទិកាទៅដល់ចៅក្រមនៃអង្គជំនុំជម្រះ ដែលអាចសួរតាំងសំណួរខ្លះចំពោះសាក្សីរូបនេះ មុននឹងប្រគល់វេទិកាជូនទៅដល់មេធាវីការពារក្តី។ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីថា សំណើសុំដែលភាគីបានលើកឡើងអម្បាញ់មិញមុនពេលអង្គជំនុំជម្រះសម្រាក ដោយចរិតលក្ខណៈនៃបញ្ហាមានការលំបាកស្មុគស្មាញ ហើយអង្គជំនុំជម្រះមិនទាន់អាចសម្រេចបញ្ហានេះនៅពេលនេះបានទេ។ អង្គជំនុំជម្រះទុកពេលនេះដើម្បីរៀបចំពិភាក្សាពិចារណា និងរៀបចំឲ្យបានល្អ ហើយនិងប្រកាសនៅរសៀលនេះ នៅពេលដែលចាប់ផ្តើមដំបូងមុនពេលប្រគល់វេទិកាទៅសួរដេញដោលចំពោះសាក្សី។

[១១:១៧:២៧]

ជាបន្តអង្គជំនុំជម្រះ សូមសួរទៅចៅក្រម អស់លោក លោកស្រីតើមានសំណួរអ្វីចង់សួរទៅសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែរឬទេ? ប្រសិនបើមានសូមអញ្ជើញបាទ!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ លោកបានផ្តល់សក្ខីកម្មជាច្រើនលើកច្រើនសារួចមកហើយ ហើយលោកបានផ្តល់នូវព័ត៌មានជាច្រើនជូនអង្គជំនុំជម្រះ ក៏ប៉ុន្តែខ្ញុំមានសំណួរមួយចំនួនដែលត្រូវចោទសួរលោក ដើម្បីព្យាយាមទទួលបាននូវការបំភ្លឺនៅចំណុចមួយចំនួន។ ជាដំបូង ខ្ញុំសូមត្រឡប់ទៅរយៈ

ពេលដែលលោកនៅមន្ទីរម-១៣ វិញ លោកបានបញ្ជាក់ថា គេបានបង្រៀនលោកឲ្យដឹងថាមានខ្មាំងបីប្រភេទ គឺលោកបាននិយាយកាលពីសវនាការថ្ងៃទី២០ ខែមីនាថា មួយប្រភេទគឺថាយើងត្រូវអូសទាញមកឲ្យធ្វើជាកម្លាំងបដិវត្តន៍ ហើយបន្ទាប់មកទៀតលោកបាននិយាយថា មានប្រភេទទីពីរដែលនៅ ប៉ាលហាល ហើយដូច្នេះយើងត្រូវតែអព្យាក្រឹតកម្លាំងហ្នឹង។

[១១:១៨:៥២]

ហើយលោកក៏បានបញ្ជាក់តទៅទៀតថា ប្រភេទទីពីរហ្នឹងគឺជាប្រភេទដែលពួកមានភាពស្ទាក់ស្ទើរ ហើយជាចុងក្រោយគឺត្រូវឯកាខ្មាំងដែលឃោរឃៅ ហើយនិងបន្ទាប់មកគឺវាយកម្ទេច នេះគឺជាខ្មាំងប្រភេទទីបី។ ហើយនៅថ្ងៃដដែលនោះ លោកក៏បានបញ្ជាក់ផងដែរថា ការបែងចែកជាប្រភេទនេះ គឺជាគ្រាន់តែមានជាទ្រឹស្តីតែប៉ុណ្ណោះ។ ក៏ប៉ុន្តែនៅក្នុងការអនុវត្តលោកមិនដឹងទេថា តើទ្រឹស្តីនោះត្រូវបានអនុវត្ត ឬក៏អត់នោះ។ ហើយលោកបានបញ្ជាក់ថា នៅឆ្នាំ៧១ បក្សអប់រំយើងឲ្យបែងចែកឲ្យបានច្បាស់លាស់ព្រំដែនវណ្ណៈ រវាងខ្មាំងនិងយើង។ យើងត្រូវតែបែងចែកឲ្យបានច្បាស់លាស់បំផុត គឺយើងប្រៀបធៀបដូចទៅនឹងសមរភូមិនៅវៀតណាមខាងត្បូង គឺយើងស្ថិតនៅក្នុងតំបន់រំដោះ ហើយខ្មាំងស្ថិតនៅក្រៅតំបន់រំដោះ។ គេបានប្រាប់យើងថា ស្អីដែលជាខ្មាំងនោះយើងកុំធ្វើ ពុករលួយស្អីៗយើងកុំធ្វើ។ ការពុករលួយគឺជាអំពើរបស់ខ្មាំង ហើយយើងត្រូវតែចៀសវាងក្នុងការធ្វើរបៀបនេះ។

សំណួរដែលខ្ញុំចង់សួរលោកនោះ ថាតើជាការ-- តាមការពិតនោះ តើអាចឬទេក្នុងការផ្សះផ្សានយោបាយមួយ ដែលថា ម្ខាងព្យាយាមធ្វើឲ្យខ្មាំងទន់ចុះចូល អូសទាញខ្មាំង ហើយម្ខាងទៀតគឺយើង--គោលនយោបាយនោះ គឺព្យាយាមបង្កើតនូវការបែងចែកឲ្យបានដាច់ស្រឡះព្រំដែនគ្នារវាងខ្មាំង ហើយនិងអ្នកដែលស្ថិតនៅក្នុងបដិវត្តន៍? តើវាមានភាពបញ្ច្រាសគ្នា ឬក៏មានភាពផ្ទុយគ្នាទេ ចំពោះនយោបាយដែលអនុវត្តនេះ? ថាតើជាគោលនយោបាយដែលយើងអាចនិយាយថាជាការបើកចំហ ឬក៏ជាគោលនយោបាយក្នុងការដកចេញនូវបុគ្គលមួយចំនួន បដិសេធចោលនូវបុគ្គលមួយចំនួន ហើយយកបុគ្គលមួយចំនួន?

[១១:២១:២៩]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ចំពោះបញ្ហាឲ្យបែកចែកខ្មាំងជាបីប្រភេទ។ នេះជាមាគ៌ានយោបាយ ជាយុទ្ធវិធី ដែលរៀបចំឡើងនៅក្នុងឯកសារសំខាន់ ដែលអនុម័តនៅក្នុងឆ្នាំ១៩៦០ នៃពេលកំណើតបក្ស។ នៅពេលនោះការរៀនសូត្រដែលខ្ញុំបានរៀន គឺរៀននៅឆ្នាំ១៩៦៧ អំពី

មាគ៌ានយោបាយ យុទ្ធវិធីនេះ។

មកដល់ឆ្នាំ១៩៧១ ខ្ញុំទទួលភារកិច្ច ប្រធានមន្ទីរ១៣។ គោលគំនិតនៃការកម្ទេចខ្មាំងពេលនោះ ឲ្យតែចូលតំបន់រំដោះ គេចាត់ទុកជាគិញដែលត្រូវតែកម្ទេច។ នៅពេលហ្នឹងហើយ ដែលខ្ញុំមានការរារែក ទុកមនុស្សមួយចំនួនដែលខ្ញុំសន្មតថាមិនមែនជាគិញសម្រាប់បង្កបង្កើនផល។ នៅពេលនោះហើយ ដែលក្នុងឆ្នាំមួយពាន់-- នៅពេលនុ៎ងហើយដែលខ្ញុំជួបប្រទះឧបសគ្គមួយ គឺអ្នកជាប់ឃុំឃាំងនោះ គេវ៉ៃគុករត់។ នៅពេលនុ៎ងហើយ ដែលខាងលើណែនាំថា អ្នកណាដែលគេបញ្ជូនទៅឲ្យមិត្ត គឺសុទ្ធជាខ្មាំងដែលត្រូវតែវ៉ៃស្ងួរចម្លើយ។ នៅក្នុងឆ្នាំ១៩៧៣ នេះហើយដែលវគ្គសិក្សាបានបញ្ជាក់ថា ខ្មែរប្លែកអំពីវៀតណាម។ វៀតណាម គេអនុវត្តនយោបាយប្រទាក់ប្រទាញជាមួយខ្មាំងនៅព្រៃនគរ នៅភាគខាងត្បូង។ ឯចំណែកយើងៗចែកឲ្យដាច់ ឲ្យមានព្រំដែនវណ្ណៈច្បាស់លាស់ រវាងខ្មាំងនិងយើង។ ខ្មាំងត្រូវតែកម្ទេច។

[១១:២៤:៥៧]

សរុបមក សភាពការណ៍វាបញ្ជាក់នៅក្រោយ១៧ មេសា ១៩៧៥។ រាជវង្សានុវង្ស បើតាមខ្ញុំដឹង គឺកម្ទេច ឲ្យតែជួប។ អត់មានបែងចែកទេ។ សូមបញ្ជាក់ថា រាជវង្សានុវង្សដែលចេញទៅតំបន់រំដោះមានពីរនាក់ក្នុងឆ្នាំ១៩៧២ ចុង១៩៧២ ឬ ៧៣។ ទីមួយគឺ អ្នកអង្គម្ចាស់ នរោត្តម ភូរីស្សារា ហើយនិងប្រពន្ធ។ ទីពីរ ស៊ីសុវត្ថិ ផាច ទៅដំបន់រំដោះដូចគ្នា។ ហើយបុគ្គលទីពីរឈ្មោះ ស៊ីសុវត្ថិ ផាច ក៏ទៅតំបន់រំដោះជាមួយ ភូរីស្សារា ដែរ។ ស្រាប់តែដល់ថ្ងៃ២៧ មេសា សូមទោស ២៧ កញ្ញា ១៩៧៧ ស្រាប់តែប៉ុល ពត និយាយថា៖ "ដូច ភូរីស្សារា ហើយនិងអ្នកម្នាងភ្លោះស្អីគេនោះ ស្អី? រាជវង្សានុវង្សស្នេហាជាតិឬអី? ហើយដល់ពេលហ្នឹងហើយបានយើងខ្ញុំផ្ទាល់ខ្លួនដឹងថា អ៎ ភូរីស្សារា ទោះបីជាចេញចូលទៅក្នុងតំបន់រំដោះក៏ដោយតាំងពី៧២ ចុង៧២ ឬដើម៧៣ ក៏ដោយ ក៏ត្រូវគេកម្ទេចដែរ។

[១១:២៦:១៤]

សរុបមកដោយសារបញ្ហានេះដោយសារភស្តុតាងនេះមួយដែលយើងខ្ញុំជឿថា ដែលយើងខ្ញុំជឿថា រាជវង្សានុវង្សក៏គេកម្ទេចដែរ មិនបែងចែកទេ។ សក្តិភូមិម្ចាស់ដីគេរកឃើញ គេកម្ទេច។ ដោយឡែកតាមអង្គភាពមួយៗ ឧទាហរណ៍ អនុសេនាធំអីរបស់ខ្មាំង គេអាចបែងចែកជាបីមែន។ ដូច្នេះ សរុបមកការបែងចែកខ្មាំងជាបីនេះមានលក្ខណៈជាទ្រឹស្តីច្រើនជាង។

**ស៖** សូមការបញ្ជាក់មួយ។លោកនិយាយអំពីរាជវង្សានុវង្សដែលស្ថិតនៅក្នុងតំបន់រំដោះ ហើយខ្ញុំគិតថាវាកើតឡើងនៅមុនឆ្នាំ៧៥ ខ្ញុំយល់មិនសូវច្បាស់ទេអ្វីដែលលោកបានពន្យល់នោះ គឺថារាជវង្សា

នុវង្សទាំងអស់នេះគឺត្រូវតែកម្ទេចចោល? ហើយខ្ញុំមិនដឹងថាពួកគាត់ រាជវង្សានុវង្សនោះត្រូវបានកម្ទេចភ្លាមតែម្តងនៅពេលដែលពួកគាត់ចូលទៅដល់តំបន់រំដោះ ឬក៏ជាហេតុការណ៍ដែលកើតឡើងនៅពេលក្រោយចូលទៅក្នុង-- ចូលទៅតំបន់រំដោះ តើលោកអាចបញ្ជាក់ពីចំណុចនេះបានទេ?

[១១:២៩:២១]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ភូរីស្សារាហើយនិងប្រពន្ធ ហើយនិង ស៊ីសុវត្ថិផាច ទៅតំបន់រំដោះចាប់តាំងពីចុងឆ្នាំ១៩៧២ ឬដើមឆ្នាំ១៩៧៣។ ប្រហែលជានៅក្នុងឆ្នាំ១៩៧៣ ខាងលើឲ្យ វន វ៉េត បញ្ជូនទៅ។ ដូច្នេះគាត់ទៅនៅតំបន់រំដោះក្នុងឃុំពាម ស្រុកកំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំង បានយូរដែរ។ ដូច្នេះ គាត់ទៅនោះបានយូរដែរ ទម្រាំបញ្ជូនទៅ។ នៅពេលដែលបញ្ជូនទៅហ្នឹងខ្ញុំដឹងដំណឹងថា វន វ៉េត ស្រែក៖ “ជយោព្រះរាជវង្សានុវង្សស្នេហាជាតិ!”។ សូមបញ្ជាក់ថា មិនមែនសុន សេន ទេ វន វ៉េត។ ដំណឹងអំពីរឿង ភូរីស្សារា ហ្នឹង ខ្ញុំបាត់ ក៏ប៉ុន្តែមិនមានដំណឹងណាថា ភូរីស្សារាស្លាប់ ឆ្ងាយពេក មុន១៧មេសាទេ។ ដូច្នេះ ភូរីស្សារា ទៅនៅតំបន់រំដោះយូរណាស់ ប្រហែលជាមុន១៧មេសាបន្តិច ទើបគេកម្ទេច។

[១១:៣១:៥១]

**ស៖** អ្វីដែលលោកបានជម្រាបជូននោះ គឺថាយើងមានយុទ្ធសាស្ត្រមួយដែលសំដៅអូសទាញរាជ្យវង្ស-- អូសទាញបុគ្គលមួយចំនួនដែលមានតួនាទីសំខាន់ ឬក៏ចំពោះ-- ឲ្យចូលទៅក្នុងបដិវត្តន៍។ ចំពោះមនុស្សធម្មតាវិញ ឧទាហរណ៍ ដូចជានៅអមលាំង ចំពោះលោកខ្លួនផ្ទាល់ ថាតើនៅពេលដែលប្រជាជនមកពីរំដោះ ហើយនាំទៅអមលាំង តើជាការធម្មតាទេ នៅពេលដែលថាមកពីតំបន់រំដោះខណ:ដែលយើងស្ថិតនៅក្នុងតំបន់ដែលកាន់កាប់ដោយទ័ពអាមេរិក-- ទ័ពសាធារណរដ្ឋ (សូមទោស)។ តើយើងចាត់ទុកថា គាត់ជាគិញដែរឬទេ? តើនេះជាគោលនយោបាយទូទៅដែរទេ? ខ្ញុំសំដៅទៅលើមនុស្សធម្មតាទេ។ តើនៅពេលដែលគាត់ចេញពីតំបន់រំដោះមកនោះ គេចាត់ទុកថាគាត់ជាគិញដែរឬទេ?

[១១:៣២:៥៣]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចំពោះប្រជាជនសាមញ្ញវិញ ខ្ញុំសូមបញ្ជាក់រឿងដែលកើតឡើងនៅអមលាំង។ ក្នុងឆ្នាំ១៩៧៣ ៗនេះ វាមានគ្រោះអាសន្នមួយ គ្រាប់បែក ប៥២ វាទម្លាក់។ នៅពេលនោះ មានក្មេងម្នាក់ត្រូវគេបញ្ជូនពីតំបន់ខ្មាំង គឺពីឧដុង្គទៅដល់អមលាំង។ គេចាប់បាន គេឲ្យមកស-២១ សួរ។ ដល់ពេល-- (សូមទោស) គេបញ្ជូនមក ម-១៣ សួរចម្លើយ។ នៅពេលម-១៣

សួរចម្លើយ ក្មេងនោះ វាឆ្លើយដាក់មនុស្សបួនប្រាំនាក់នៅអមលាំង។ នៅពេលនុ៎ង ដោយសារក្មេងហ្នឹង វាអាយុ១២ឆ្នាំមិនទាន់ពេញវ័យ គេក៏មិនចាប់អ្នកប៉ុន្មាននាក់នុ៎ងយកមកទេ គេគ្រាន់តែតាមដាន។ ដោយឡែកក្មេងនុ៎ងគេឱ្យកម្ទេច។

[១១:៣៥:២២]

នៅពេលនុ៎ងដែរ បន្ទាប់មកបន្តិចទៀត មានក្មេងម្នាក់ទៅពីតំបន់ខ្មាំងទៅអមលាំង ស្រុកកំណើតវានៅអមលាំង។ គេចាប់។ ក្មេងហ្នឹងអាយុប្រហែលជា-- បើតាមខ្ញុំចាំដូចជាប្រាំបីដណ្តប់ទៅម្ល៉េ ចន្លោះហ្នឹង។ រៀននៅថ្នាក់ទីបី ជិតប្រឡងឌីប្លូមហើយ។ ឌីប្លូម មិនមែន*បាក់កាឡូរេអា* ទេ។ ដល់ពេលចាប់ទៅសួរចម្លើយក្មេងហ្នឹង។ ក្មេងហ្នឹងឆ្លើយដាក់ គេចាប់។ គេចាប់យកមកឱ្យ ម-១៣ សួរចម្លើយ។ បន្ទាប់មកមានបុរសវ័យចំណាស់ម្នាក់ វ័យកណ្តាលម្នាក់អាយុប្រហែល៤០ប្លាយ ពង្រត់ប្រពន្ធគេមកឧដុង្គ។

**ស៖** ចៅក្រម យើងមិនចង់ដឹងអំពីលម្អិត អំពីអ្នកដែលទៅអមលាំងទាំងអស់នោះទេ។ ខ្ញុំគ្រាន់តែចង់ដឹងជាលក្ខណៈទូទៅ ថាតើលោកឯកភាពទេ ក្នុងការនិយាយថា គោលនយោបាយក្នុងការបង្រួបបង្រួម ឬក៏អូសទាញខ្មាំងនោះ គឺជាគោលនយោបាយបើកចំហ ហើយមិនអនុវត្តចំពោះមនុស្សសាមញ្ញទេ។ តើលោកឯកភាពទេចំពោះចំណុចនេះ?

[១១:៣៨:១០]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នយោបាយបញ្ចុះបញ្ចូលខ្មាំងឱ្យត្រឡប់មករកត្រឹមត្រូវវិញ មិនអនុវត្តចំពោះប្រជាជនសាមញ្ញក៏ដោយ។

**ស៖** ខ្ញុំយល់អត់សូវច្បាស់ទេ ថាតើគោលនយោបាយបង្រួបបង្រួមនេះអនុវត្តចំពោះប្រជាជនសាមញ្ញនោះ បើសិនជាអនុវត្តហេតុអីបានជាប្រជាជនដែលឆ្លងកាត់ព្រំដែនរវាងតំបន់ខ្មាំង ហើយនិងតំបន់រំដោះ ត្រូវបានចាត់ទុកថាជាគិញទៅវិញនោះ។ តើហេតុអីបានជាអ៊ីចឹងទៅវិញ? តើវាស្របទៅនឹងគោលនយោបាយបើកចំហនេះដែរឬទេ?

**ឆ៖** អរគុណ។ ពីឆ្នាំ១៩៧១មក ដែលបក្សកុម្មុយនីស្តកម្ពុជាមានតំបន់រំដោះ គ្មាននយោបាយបើកទ្វារចំហរវាងតំបន់រំដោះ និងតំបន់ខ្មាំងទេ។

[១១:៤០:០០]

**ស៖** ដូច្នេះគឺលោកបានពន្យល់អំពីមាគ៌ាជាយុទ្ធសាស្ត្រដែលបានកំណត់នៅក្នុងឆ្នាំ៦០ ហើយនិងទ្រឹស្តីដែលមាននៅក្នុងឆ្នាំ៦០។ តើជាក់ស្តែងនោះនៅឆ្នាំ៧០ ឬក៏៧១ ចាប់ពីពេលមានតំបន់រំដោះ តើមិន

មានការអនុវត្តទៀតទេ តើមែនទេ? អ្វីដែលលោកចង់និយាយនោះ។

**ឆ៖** អរគុណ។ តាមការពិនិត្យទោះបីពេលនេះក៏ដោយ ខ្ញុំនៅតែឃើញថា ការបែងចែកខ្លាំងជាបីប្រភេទគ្រាន់តែជាទ្រឹស្តីប៉ុណ្ណោះ។

**សៈ** ខ្ញុំចង់អាននូវសម្រង់ឯកសារមួយ ឯកសារនេះបានដាក់ទៅក្នុងសំណុំរឿងរួចហើយ។ មានលេខកូដ E3/189 នេះគឺជាសម្រង់នៃសេចក្តីថ្លែងការណ៍ដែលអនុម័តនៅក្នុងសមាជជាតិរបស់រាជរដ្ឋាភិបាលរួបរួមជាតិ ដែលប្រព្រឹត្តនៅថ្ងៃ២៤-២៥ ខែកុម្ភៈ ឆ្នាំ៧៥ ក្រោមអធិបតីភាពលោក ខៀវ សំផន។

[១១:៤១:៤០]

នៅក្នុងទំព័រទី៣ នៃឯកសារនោះបាននិយាយថា៖ “នៅក្នុងប្រទេសរាជរដ្ឋាភិបាលនិងរណសិរ្សរួបរួមជាតិ តាងនាមឲ្យប្រជាជន និងប្រជាជាតិកម្ពុជាកាន់កាប់ជោគវាសនារបស់ជាតិ។ រណសិរ្សបង្រួបបង្រួមជាតិ និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាប្រកាន់ខ្ជាប់នូវគោលនយោបាយបង្រួបបង្រួមជាតិ និងប្រជាជនទាំងមូល ទូលំទូលាយ មិនគិតពីវណ្ណៈសង្គម និន្នាការនយោបាយ ជំនឿសាសនា ឬអតីតកាលរបស់ខ្លួនឡើយ។ លើកលែងតែពួកក្បត់ប្រាំពីរនាក់ គឺពួកមហាក្បត់ទាំងប្រាំពីរ”។

លោក ឌុច តើលោកមានដឹង អំពីការអនុវត្តនៃគោលនយោបាយរបស់រណសិរ្សដើម្បីបង្រួបបង្រួមជាតិនោះដែរឬទេ? ហើយនិងគោលនយោបាយនោះទទួលយកមនុស្សទាំងអស់ បង្រួបបង្រួមមនុស្សទាំងអស់ដោយមិនមានការបែងចែកអំពីវណ្ណៈសង្គម និន្នាការនយោបាយ ឬក៏ជំនឿសាសនាអ្វីនោះទេ។ តើគោលនយោបាយនេះ លោកធ្លាប់ឃើញដែរឬទេ ហើយតាមវាមានន័យដូចគ្នាទៅនឹងមាគ៌ាជាយុទ្ធសាស្ត្រ និងមាគ៌ាទ្រឹស្តីដែរឬទេ?

[១១:៤៣:០៥]

**ឆ៖** អរគុណ។ ខ្ញុំសូមគោរពប្រធាន ហើយនិងសុំបញ្ជាក់លោកចៅក្រមថា មួយជាទ្រឹស្តីគេប្រកាសជាចំហអ៊ីចឹង។ គ្មានប្រកាន់វណ្ណៈ គ្មានប្រកាន់និន្នាការនយោបាយ។ គ្មានៗប្រកាន់អតីតកាលអីទេ។ ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង វាមានចលនាមួយ គឺចលនាជម្លៀសប្រជាជន ហើយចលនាមួយទៀត ក្នុងចលនាជម្លៀសហ្នឹង គេមានចលនាកម្ទេចដោយសម្ងាត់។

**សៈ** លោក ឌុច នៅពេលនេះខ្ញុំមិនចង់និយាយអំពីជម្លៀសប្រជាជននោះទេ ឬក៏ជម្លៀសចេញពីទីក្រុងផ្សេងៗ ឬក៏ជម្លៀសចេញពីក្រុងភ្នំពេញនោះទេ ខ្ញុំចង់ដឹងផ្ទាល់ថាតើលោកបានឃើញអីខ្លះនៅ

អមលាំង ហើយនិងនៅជុំវិញអមលាំង។ តើលោកមានឃើញពីការអនុវត្តនូវគោលនយោបាយបង្រួបបង្រួមជាតិដែរឬទេ? ខ្ញុំអាចផ្តល់ឧទាហរណ៍ជាក់លាក់មួយ ព្រោះថានៅក្នុងសេចក្តីថ្លែងការណ៍នោះមានឃ្លាផ្សេងទៀត។

[១១:៤៥:១៥]

ឧទាហរណ៍មានការនិយាយនៅក្នុងឯកសារនោះថា នៅទំព័រ៤ "ចំពោះជនរួមជាតិទាំងអស់ វណ្ណៈ និងស្រទាប់សង្គមទាំងអស់ មន្ត្រីរាជការគ្រប់ផ្នែក មេទាហាន និងពលទាហាន ភ្នាក់ងារនគរបាលគ្រប់ជាន់ថ្នាក់ដែលបានបោះបង់ចោលខ្មាំងដើម្បីមកចូលក្នុងតំបន់រំដោះនោះ រណសិរ្សរួបរួមជាតិគ្រប់ជាន់ថ្នាក់មានគោលនយោបាយក្នុងការផ្តល់ជំនួយ និងការឧបត្ថម្ភគាំទ្រដល់ពួកគេទាំងអស់នោះ។ ពួកយើងនឹងផ្តល់មធ្យោបាយធ្វើ-- មធ្យោបាយផលិតកម្ម និងស្បៀងដើម្បីឲ្យគាត់បានរស់នៅថ្លៃថ្នូរដោយមិនចាំបាច់ប្រើប្រាស់ប្រាក់រៀលរបស់ខ្មាំងនោះទេ។ ជនរួមជាតិគ្រប់ស្រទាប់វណ្ណៈទាំងអស់ដែលរស់នៅទីក្រុងភ្នំពេញ ហើយនិងស្ថិតនៅក្នុងទីរួមស្រុកដែលស្ថិតនៅក្រោមការក្តោបក្តាប់របស់ខ្មាំង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ មេទាទាហាន មន្ត្រីនគរបាលទាំងអស់ ដែលត្រៀមខ្លួនក្នុងការចាកចេញជួរខ្មាំង ហើយនិងត្រៀមខ្លួនចូលរណសិរ្សរួបរួមជាតិនេះ មិនចាំបាច់ព្រួយអំពីជីវភាពរស់នៅនោះទេ ហើយនិងការងារនោះទេ។ យើងនឹងធានាទាំងស្រុងចំពោះចំណុចទាំងអស់នេះ"។

ខ្ញុំសូមសួរសំណួរឡើងវិញ។ តើលោកមានធ្លាប់ឃើញការអនុវត្តគោលនយោបាយមួយដែលមានការជួយ និងឧបត្ថម្ភទៅដល់បុគ្គលទាំងអស់នេះដែរឬទេ?

[១១:៤៧:០២]

**ធ៖** អរគុណ។ ខ្ញុំសូមនិយាយមួយម៉ាត់ ថាគ្មានទេ។

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត លោកបាននិយាយអំពីអ្នកដែលត្រូវបានជម្លៀស ហើយយើងបានក៏សួរសំណួរពីចំណុចនេះដែរ ហើយលោកបាននិយាយអំពីអ្វីដែលបានកើតឡើងនៅឧដុង្គ។ ឧដុង្គ គឺនៅឆ្នាំ៧៤ គឺនៅក្នុងសវនាការថ្ងៃទី២០ មីនា លោកបាននិយាយថាដូចតទៅនេះ គេសួរសំណួរលោកថា "តាមអ្វីដែលលោកដឹង តើប្រជាជនដែលគេជម្លៀសហ្នឹងមានជម្រើសក្នុងការមិនចាកចេញពីភូមិ ឬពីកសិដ្ឋានរបស់ខ្លួនដែរឬទេ?" លោកបានឆ្លើយថា "ផ្សារឧដុង្គគ្មានកសិដ្ឋានទេ ប៉ុន្តែប្រជាជនទាំងអស់ មិនអាចបដិសេធនៅក្រាញ់នៅហ្នឹងបានទេ ត្រូវតែទៅ"។

[១១:៤៨:០៦]

សំណួរបន្តទៅទៀត "តើលោកដឹងបញ្ហានេះដោយរបៀបណាដែរអំពីអ្នកដែលជម្លៀសនេះ?" លោកបានឆ្លើយថា "ខ្ញុំបានឃើញពួកគេ ខ្ញុំបាន-- សូមទោស! ខ្ញុំបានឃើញឡានដែលបម្រុងទុកសម្រាប់អ្នកដែលត្រូវបានជម្លៀស ហើយគឺមាន សុន សេន ជាអ្នកបញ្ជា" ហើយលោកបាននិយាយផងដែរថា "មនុស្សម្នាក់គឺ KW-30 ស្ថិតនៅក្នុងចំណោមមនុស្សដែលត្រូវបានជម្លៀសនេះ"។ លោកបានបញ្ជាក់ថា "នេះគឺជាព័ត៌មានដែលលោកបានឃើញផ្ទាល់"។

តើលោកមានបានឃើញដោយផ្ទាល់ភ្នែកនូវឡានដែលត្រូវបានរៀបចំសម្រាប់ជម្លៀសប្រជាជនចេញពីឧដុង្គដែរឬទេ?

[១១:៤៨:៥៩]

**ឆ៖** អរគុណ។ បើសិនជានិយាយថា ឃើញកាំម៉ុងផ្ទាល់ ខ្ញុំអត់ឃើញទេ។ ក៏ប៉ុន្តែអ្នកដែលប្រតិបត្តិការជម្លៀសហ្នឹង គឺមនុស្សនៅក្នុងភូមិភាគពិសេស។ ដូច្នេះ ពួកនេះហើយដែលផ្តល់ព័ត៌មានឱ្យខ្ញុំ។ នេះមួយ។ ទីពីរ មេខ្ញុំបញ្ជា ថាមិត្តបញ្ជូនមនុស្សទៅមួយចំនួន ទៅជាមួយនឹងពួកគេ ពួកឧដុង្គ។ ដូច្នេះ មិនមែនមានតែ KW-30 ទេ មានអ្នកផ្សេងទៀត ក៏ប៉ុន្តែខ្ញុំលើកតែ KW-30 ព្រោះយើងទាំងអស់គ្នាស្គាល់ KW-30 ច្បាស់។

**ស៖** អ្វីដែលលោកបាននិយាយអម្បាញ់មិញនេះ តើលោកអាចបញ្ជាក់ឱ្យបានច្បាស់ទេថា មានផែនការ មានការរៀបចំជារចនាសម្ព័ន្ធត្រឹមត្រូវដើម្បីបង្ខំប្រជាជនឱ្យគេចចេញពីតំបន់ឧដុង្គក្រោយពីមានការប្រយុទ្ធគ្នានោះ?

[១១:៥០:៥៣]

**ឆ៖** អរគុណ។ គឺកងទ័ពដែលវ៉ៃឧដុង្គហ្នឹង ជាអ្នកអនុវត្តបញ្ជា។

**ស៖** លោកបានបន្សល់បន្តមកទៀតថា មនុស្សភាគច្រើនត្រូវបានជម្លៀសទៅកាន់ខេត្តពោធិ៍សាត់ តើត្រឹមត្រូវដែរឬទេ? តើនៅពេលជម្លៀសនោះ ដោយបង្ខំ តើមានការបោសម្អាត ឬក៏មានការសម្លាប់មនុស្សដែរឬទេ?

**ឆ៖** អរគុណ។ ការជម្លៀសលើកនេះពិតជាទៅពោធិ៍សាត់មែន ក៏ប៉ុន្តែក្នុងចលនាជម្លៀសលើកនេះ គេយកទៅកម្ទេចប៉ុន្មាន? អីប៉ុន្មាន? ខ្ញុំមិនដឹងទេ។ ក៏ប៉ុន្តែសក្ខីកម្ម KW-30 នៅទីនេះបញ្ជាក់ថា មនុស្សដែលចេញពីម-១៣ ទាំងប៉ុន្មាននៅរស់ មួយចំនួនធំ។

[១១:៥២:៣២]

**ស៖** ខ្ញុំចង់និយាយអំពីចំណុចមួយផ្សេងទៀត។ កាលពីសេចក្ដីប្រកាសលើកមុននោះ លោកក៏បាននិយាយអំពីការជម្លៀសពីកំពង់ធំ លោកបានបញ្ជាក់ថាលោកបានជជែកពីការជម្លៀសនេះជាមួយនឹងបងថ្លៃមួយ ហើយខ្ញុំនឹងអានទូវអ្វីដែលលោកបាននិយាយ៖ "ជម្លៀសប្រជាជនចេញពីកំពង់ធំនោះ ខ្ញុំបានព័ត៌មានពីប្អូនថ្លៃខ្ញុំ ដែលធ្វើការនៅទីនោះឈ្មោះ កៅលី ថុងហួត។ វាប្រាប់ខ្ញុំពីការជម្លៀសនៅកំពង់ធំចេញទៅជនបទ។ ហើយវាបាននិយាយថា ការជម្លៀសនោះ ត្រូវបានរៀបចំ អ្នកដែលគេឲ្យជិះឡានហ្នឹងគឺ គេយកទៅកម្ទេច ហើយអ្នកដែលចេញទៅដោយដើរនោះ គឺនៅរស់ គឺមនុស្សទាំងអស់ហ្នឹងគេទុកឲ្យរស់"។ តើលោកអាចបញ្ជាក់ពីអាចំណុចនេះបានទេ? តើលោកអាចបាននិយាយឲ្យហួសពីហ្នឹងអំពីការរៀបចំជម្លៀសប្រជាជនចេញពីកំពង់ធំបានដែរទេ? ហើយការជម្លៀសនោះកើតឡើងនៅពេលណាដែរ?

[១១:៥៣:៤៩]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ជម្លៀសពីក្រុងកំពង់ធំក្រោយ១៧ មេសា។

**ស៖** តើមានវិធានការរៀបចំអ្វីខ្លះសម្រាប់ការជម្លៀសប្រជាជនចេញពីកំពង់ធំនេះ?

**ឆ៖** ខ្ញុំមិនដឹងច្បាស់ទេ គ្រាន់តែសុំបញ្ជាក់ជូនតុលាការថា អាប្អូនថ្លៃខ្ញុំនេះ ធ្វើនគរបាលខេត្តកំពង់ធំហ្នឹងដែរ។

**ស៖** តើគេជានគបាលខាងបដិវត្តន៍ ឬក៏ជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** វាជានគរបាលរបស់បក្សកុម្មុយនីស្តកម្ពុជា។ វាជាសមាជិកបក្ស។

**ស៖** ហេតុអ្វីបានជាអ្នកទាំងអស់ហ្នឹងត្រូវបានជម្លៀស ហើយតើជម្លៀសទៅកាន់តំបន់ណាដែរ?

**ឆ៖** អរគុណ។ ខ្ញុំអត់បានបញ្ជាក់សួរទេ។ សូមចូលទៅបញ្ហាជាក់ស្ដែងមួយ។ នៅក្នុង-- នៅក្នុងពេលដែលជម្លៀសហ្នឹងនិយាយពីគ្រូម្នាក់ គ្រូបឋមសិក្សាម្នាក់។ ស្រុកកំណើតនៅស្ទោង គាត់-- គេឲ្យគាត់ដើរ គាត់មិនព្រមដើរ គាត់តវ៉ាសុំជិះឡាន។ ដល់ពេលគាត់ត្រូវ-- គាត់ជិះឡានអីចឹង គេកម្ទេច។

[១១:៥៦:៣៩]

**ស៖** ឥឡូវនេះចូលទៅដល់អ្វីដែលលោកអាចមើលឃើញ គឺឃើញមនុស្សដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥។ តើខ្លួនលោកផ្ទាល់នៅអមលាំងនោះ នៅក្នុងតំបន់អមលាំងនោះ លោកមានបានឃើញមនុស្សដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញហើយទៅដល់ជនបទដែរឬទេ?

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា នៅអមលាំងដំបូងក្រោយពី១៧ មេសា ប្រហែលជាបីថ្ងៃឃើញមនុស្សរែកកញ្ជើទៅឲ្យរពុយ។ ខ្ញុំគិតស្មានថា នេះគឺជាមនុស្សដែលស្ម័គ្រចិត្តទៅរស់នៅក្នុងស្រុកកំណើតវិញ។ ក៏ប៉ុន្តែមួយសន្ទុះក្រោយមកឮដំណឹងមកថា គេមានបង្កើតការិយាល័យមួយនៅវត្តកន្សែងសំ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ នៅពេលហ្នឹងហើយ ខ្ញុំបានទទួលដំណឹងថា នៅកន្លែងហ្នឹងគេសម្រាប់ចែកមនុស្ស មួយចំនួនណាដែលត្រូវយកទៅកម្ទេច មួយចំនួនណាដែលត្រូវទុកបញ្ចូលទៅក្នុងសហករណ៍។ ផ្ទះនៅក្បែរវត្តកន្សែងសំ ជាភស្តុតាង។

[១១:៥៩:០១]

**ស៖** លោកបាននិយាយថា នៅពេលដែលប្រជាជនទៅដល់អមលាំង គេបានសួរអំពីមុខរបបរបស់ពួកគេ អំពីអាជីពរបស់ពួកគេ ឬក៏ប្រវត្តិរូបរបស់ពួកគេ។ ហើយបន្ទាប់មកពួកគេបានបែងចែកជាក្រុមផ្សេងៗគ្នា។ នេះជាអ្វីដលលោកបាននិយាយ។ ហើយលោកបានបញ្ជាក់ថា អ្នកខ្លះត្រូវបានបញ្ជូនទៅកន្លែងនេះទៅ អ្នកខ្លះទៅកន្លែងផ្សេងទៀតទៅ។ តើពួកគាត់ទាំងអស់នេះត្រូវបាននាំទៅកាន់មន្ទីរណាមួយដែរឬទេ? ហើយនៅ-- មន្ទីរនោះជាអ្នកសម្រេចថា ត្រូវកម្ទេច ឬក៏យ៉ាងណា? តើពិតជាអ៊ីចឹងមែនទេ?

**ឆ៖** ការិយាល័យនៅវត្តកន្សែងសំហ្នឹងជាកន្លែងសម្រាប់បែងចែក មនុស្សដែលត្រូវយកកម្ទេច ហើយនិងមនុស្សដែលត្រូវយកបញ្ចូលទៅក្នុងសហករណ៍។

[១២:០០:១៦]

**ស៖** នៅពេលណាដែលលោកចាប់ផ្តើមឮថា ប្រជាជន ១៧មេសា ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន។ តើនៅពេលដែលលោកបានឮអំពីបញ្ហានេះ? តើមានសុន្ទរកថា ឬក៏មានវគ្គបណ្តុះបណ្តាល តើហេតុការណ៍នេះកើតឡើងយ៉ាងម៉េចដែរ?

**ឆ៖** អរគុណ។ ដំណឹងហ្នឹង ដូចខ្ញុំដឹងពីខាងអមលាំងមកមុន។ ហើយបានក្រោយមក មានឯកសារបញ្ជាក់ នៅពេលរៀនសូត្រវគ្គ ថ្ងៃ២៥ មិថុនា ១៩៧៥។

**ស៖** តើលោកមក-- មកដល់ភ្នំពេញហើយ ឬក៏លោកទទួលព័ត៌មានពេលក្រោយ ពេលដែលលោកមកដល់ភ្នំពេញ? តើមានការរៀបចំជាមុនទេថា នៅពេលដែលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទៅនោះ ពួកគេត្រូវដាក់ឲ្យស្ថិតនៅក្រោយការត្រួតត្រារបស់ប្រជាជនចាស់នោះ?

**ឆ៖** អរគុណ។ បើតាមខ្ញុំចាំ ខ្ញុំមកភ្នំពេញច្រើនលើក។ ដំបូង គឺមករៀនវគ្គ ដល់ក្រោយមក ខ្ញុំ

ត្រឡប់ទៅវិញ។ ប្រហែលជាខែ០៧ ខ្ញុំត្រឡប់ទៅវិញ។ ដល់ពេលហ្នឹងហើយ ដែលខ្ញុំដឹងរឿងថា ប្រជាជនថ្មី ស្ថិតនៅក្រោយការគ្រប់គ្រងរបស់ប្រជាជនចាស់។

[១២:០២:១៣]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំសាក្សីទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅរសៀលនេះ នៅម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី ផេសមិន!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំ សូមស្នើសុំតាមដានដំណើរការនីតិវីធី នៅបន្ទប់បំពាក់ប្រព័ន្ធសោតទស្សន៍នៅខាងក្រោម។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ ពីបន្ទប់ខាងក្រោមបន្ទប់សវនាការនេះ សម្រាប់រយៈពេលរសៀលនៃកិច្ចដំណើរការសវនាការ។ ដោយលះបង់សិទ្ធិមិនចូលរួមនៅក្នុងការតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ ដែលបានរៀបចំជាស្រេចសម្រាប់រូបគាត់ នៅក្នុងរយៈពេលដំណើរការសវនាការរសៀលនេះ។

[១២:០៣:៥៤]

ដោយគាត់លះបង់សិទ្ធិមិនចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ តែក្រុមមេធាវីការពារក្តីលោក នួន ជា ត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់

ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា ផង។

បង្គាប់ឲ្យមន្ត្រីសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់កិច្ចដំណើរការសវនាការពេញមួយរសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូប ទៅកាន់បន្ទប់ខាងក្រោម បន្ទប់រង់ចាំ ហើយដោយឡែក គឺនៅរសៀលនេះ បង្គាប់ឲ្យនាំលោក ខៀវ សំផន មកកាន់បន្ទប់សវនាការវិញនៅ-- ឲ្យបានមុនម៉ោងមួយសាមសិបនាទី។ ហើយដោយឡែក លោក នួន ជា គឺទុកឲ្យគាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ដែលរៀបចំជាស្រេចសម្រាប់ពួកគាត់។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣៧ នាទី)*

[១៣:៣៧:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ហើយកាលពីព្រឹកមិញ អង្គជំនុំជម្រះបានជម្រាបជូនដល់ភាគីថា ខ្លួននឹងប្រកាសនូវសេចក្តីសម្រេច លើសំណើសុំរបស់ភាគី ពាក់ព័ន្ធទៅនឹងឯកសារមួយចំនួន ជាពិសេសគឺកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅដំណាក់កាលចៅក្រមស៊ើបអង្កេត ហើយនិងប្រតិចារឹកនៅក្នុងសំណុំរឿង០០១ តែឥឡូវនេះ អង្គជំនុំជម្រះក៏មានការយឺតយ៉ាវ មិនទាន់បានរៀបចំបានត្រឹមត្រូវនៅឡើយ។ អង្គជំនុំជម្រះនឹងប្រកាសនូវសេចក្តីសម្រេចនោះ នៅក្រោយពេលសម្រាកខាងមុខនេះ។

ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញលោកចៅក្រម!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

យើងនឹងចូលទៅដល់ប្រធានបទមួយទៀត។ ខ្ញុំចង់បង្ហាញជូនសាក្សី នូវឯកសារមួយ ឯកសារនោះធ្លាប់បាននិយាយរួចហើយ គឺឯកសារលេខ IS14.3 ទំព័រជាក់លាក់នោះគឺទំព័រ ដែលមានលេខ ERN ជាភាសាខ្មែរ 00077896។ ខ្ញុំគិតថា អាចប្រគល់ឯកសារជាក្រដាសជូនសាក្សីមួយច្បាប់ផងដែរ។ ខ្ញុំគិតថា តើយើងអាចដាក់បង្ហាញឯកសារនេះនៅលើអេក្រង់បានដែរឬទេ?

[១៣:៤០:១៥]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី តើលោកស្គាល់អក្សរសរសេរដៃនេះទេ? តើលោកអាចបញ្ជាក់ជូនបានថា អ្នកណាជាអ្នកសរសេរឯកសារនេះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះ ជាកំណត់ដៃរបស់បង ម៉ម ណៃ បុគ្គលិកម្នាក់របស់ស-២១។

**ស៖** តើលោកអាចបញ្ជាក់បានទេថា តើកំណត់សរសេរនេះសំដៅលើអ្វីដែរ?

**ឆ៖** កំណត់ហេតុទាំងអស់នេះ គឺបង ម៉ម ណៃ គាត់សរសេរ។ ទៅរៀនជាមួយនឹងខាងលើក៏គាត់សរសេរ។ រៀនជាមួយនឹងខ្ញុំក៏គាត់សរសេរ គាត់ប្រជុំក៏គាត់សរសេរ ស្អីក៏គាត់សរសេរចុះនៅក្នុងនុំងហ្នឹងដែរ ឲ្យតែរឿងអីពាក់ព័ន្ធដល់គាត់។

[១៣:៤១:៥០]

**ស៖** តើលោកអាចអានកថាខណ្ឌដែលស្ថិតនៅខាងក្រោមខាងស្ដាំនៃឯកសារនេះបានដែរឬទេ?

**ឆ៖** អរគុណ។ ខ្ញុំសូមអានដូចតទៅ៖

"កម្មសិទ្ធិមនោសញ្ចេតនា: ជំពាក់ជំពិននឹងប្រពន្ធកូនប្ដីស្អីនេះក៏ ស្មុះការងារបម្រើប្រទេសជាតិដែរ-- ក៏ស្មុះការងារបម្រើប្រទេសជាតិដែរ។ បើស្រឡាញ់ត្រូវលះបង់មនោសញ្ចេតនានេះ។ បក្សយើងធ្វើគំរូបដិវត្តន៍សតិអារម្មណ៍ជាប់។ បងលេខ២ ចាប់ក្មួយគាត់ឈ្មោះ សាត"។

**ស៖** សូមអរគុណ។ ខ្ញុំគិតថាប្រហែលជាមានបញ្ហាក្នុងការបកប្រែ។ ខ្ញុំនឹងអានឯកសារនេះជាភាសាបារាំងតែម្ដង ដែលឃ្លានេះមានន័យថា "មនោសញ្ចេតនារបស់កសិករ ជំពាក់ប្រពន្ធកូនប្ដីនេះ

ក៏ស្មះការងារបម្រើប្រទេសជាតិដែរ។ បើស្រឡាញ់ត្រូវលះបង់មនោសញ្ចេតនានេះ។ បក្សយើងធ្វើគំរូបដិវត្តន៍សង្គមនិយមជាប់។ បងលេខ២ ចាប់ក្មួយគាត់ឈ្មោះ សាត”។ នេះមិនមែនជាពាក្យថ្មីនោះទេ គឺពាក្យនេះបង្ហាញអំពីទំនាក់ទំនងរវាងបក្ស និងសមាជិកបក្ស ក៏ដូចជាទំនាក់ទំនងរវាងបក្ខជន ហើយនិងក្រុមគ្រួសាររបស់គាត់។ នៅពេលផ្តល់សក្ខីកម្មលោកបានបញ្ជាក់ថា មានចម្រៀងមួយដែលយើងច្រៀងនៅសម័យកម្ពុជាប្រជាធិបតេយ្យ ហើយដែលយើងនិយាយថា។ អ្វី១-- មនុស្សម្នាក់ៗជាកម្មសិទ្ធិរបស់អង្គការតើលោកមាននៅចាំចម្រៀងមួយបទនេះទេ?

[១៣:៤៥:១៧]

**ឆ៖** អរគុណ។ ខ្ញុំនៅចាំចម្រៀងនេះ។

**ស៖** គឺនៅថ្ងៃទី២៨ មីនា អ៎! សូមទោស ២០ មីនា លោកបាននិយាយថា “ខ្ញុំសង្កេតឃើញថាកូនៗរបស់ថ្នាក់លើហៅឳពុកម្តាយរបស់ខ្លួនថាអ៊ំ ពូ ឬក៏មីង។ ក្រោយមកទៀតនៅឆ្នាំ៧៥ គឺគេលេងបង្រៀនឲ្យកូនៗដឹងគុណចំពោះឳពុកម្តាយហើយ ហើយមនោគមន៍វិជ្ជានេះត្រូវបានដាក់ទៅក្នុងចម្រៀងមួយបទ ហើយនៅក្នុងចម្រៀងនោះបាននិយាយថា “ឳពុកម្តាយជាអ្នកបង្កើតយើង ក៏ប៉ុន្តែអង្គការគឺជាអ្នកគ្រប់គ្រងយើង។ ដូច្នេះយើងទាំងអស់គ្នាគឺជាកម្មសិទ្ធិរបស់អង្គការ”។ តើនេះគឺជាអ្វីដែលលោកបាននិយាយមែនដែរឬទេ?

[១៣:៤៦:០៥]

**ឆ៖** អរគុណ។ ការបកប្រែនេះឃ្លាតន័យដើមបន្តិច ក៏ប៉ុន្តែនៅរក្សាបានជាមូលដ្ឋាន។

**ស៖** តើជាទូទៅគេអាចនិយាយថា ទំនាក់ទំនងគ្រួសារនោះគ្មានតម្លៃទេ ចំពោះសមាជិកបក្សកុម្មុយនីស្ត ហើយនៅពេលដែលយើងគិតថាការងារដែលគាត់ធ្វើនោះ ជាការងារបដិវត្តន៍នោះ?

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ឲ្យស្រួលស្តាប់។ ការដឹងគុណចំពោះមាតាបិតា គេៗមិនចាត់ទុកជាមានសារៈសំខាន់ទេ។ គេឲ្យមនុស្សយើងម្នាក់ៗដឹងគុណបក្ស បក្សជាធំ។

**ស៖** តើលោកបានចាំទេ ថាលោកធ្លាប់ចាប់ខ្លួន ហើយនិងបញ្ជាឲ្យមានការសួរចម្លើយ ហើយនិងសម្លាប់ប្អូនថ្លៃរបស់លោកនោះ?

**ឆ៖** អរគុណ។ ត្រូវហើយបញ្ហានេះ។

**ស៖** នៅក្នុងសម្រង់ដែលលោកអាននោះ ឃ្លាចុងក្រោយបានបញ្ជាក់ថា “បងលេខ២ ចាប់ក្មួយគាត់ឈ្មោះ សាត” តើលោកចាំទេថា ក្មួយប្រុសរបស់ នួន ជា នោះត្រូវបានចាប់ខ្លួន ហើយតើបុគ្គលនេះ

មានត្រូវបានឃុំខ្លួននៅមន្ទីរស-២១ដែរឬទេ?

**ឆ៖** អរគុណ។ សាត នេះតាមពិតជាក្មួយប្រសាររបស់ នួន ជា។ ឯចំណែកនៅពេលនោះបក្សសម្រេចចាប់ខ្លួនបួននាក់។ ក្មួយស្រីបង្កើតរបស់ នួន ជា ពីរនាក់ ហើយនិងក្មួយប្រសាពីរនាក់។ ក្មួយស្រីទាំងពីរនាក់នេះ ម្នាក់ឈ្មោះ ឡាច វ៉ារី ម្នាក់ទៀតឈ្មោះ ឡាច ដារ៉ា។

[១៣:៥០:០៣]

**ស៖** តើក្មួយទាំងនេះធ្វើការនៅក្រសួងណាមួយដែរឬទេ? តើគាត់ធ្វើអីដែរ?

**ឆ៖** អរគុណ។ ក្មួយស្រីបង្កើតរបស់ នួន ជា ទាំងពីររូបជាដុកទ័រ ទៅរៀននៅស្រុកចិន។

**ស៖** តើគាត់ធ្វើការនៅក្រសួងសុខាភិបាលឬ? ហើយក្រោមបញ្ជារបស់អ្នកណាដែរ?

**ឆ៖** ទាំងពីរនាក់ធ្វើការនៅពេទ្យ១៧ មេសា ដែលបច្ចុប្បន្នប្រែឈ្មោះមកជាពេទ្យ "មិត្តភាពខ្មែរ-សូវៀត"។

**ស៖** តើអ្នកណាជាអ្នកបញ្ជាឲ្យមានការចាប់ខ្លួនពួកគាត់ទាំងពីរនាក់នេះ?

**ឆ៖** អរគុណ។ ជាគោលការណ៍ការសម្រេចចាប់ខ្លួនគឺពីរនាក់ ប៉ុល ពត និង នួន ជា ហ្នឹងតែម្តង។

[១៣:៥១:៤៥]

**ស៖** តើលោកបានដឹងអំពីចម្លើយសារភាពរបស់អ្នកទាំងនេះទេ? ហើយអ្នកណាជាអ្នករាយការណ៍ អំពីចម្លើយសារភាពនេះជូនលោក?

**ឆ៖** អរគុណ។ ចម្លើយរបស់នារីទាំងពីររូបនេះ ខ្ញុំផ្ញើទៅខាងលើ។ បើសិនជាមុនថ្ងៃ១៥ សីហា ១៩៧៧ ខ្ញុំផ្ញើទៅតាមរយៈ សុន សេន បើសិនជាក្រោយថ្ងៃ១៥ សីហា ១៩៧៧ គឺខ្ញុំផ្ញើទៅតាមរយៈបងនួន។

**ស៖** យើងមានឯកសារមួយទៀត គឺឯកសារលេខ D366/7.1.87 (ស៊ីក)។ នេះគឺជាសេចក្តីសារភាពដែលធ្វើដោយ ឡាច វ៉ារី ហៅ ណាន ហើយក្នុងឯកសារនោះមានបាននិយាយថា មុនពេលចាប់ខ្លួន អ្នកទទួលខុសត្រូវផ្នែកព្យាបាលនៃក្រសួងការបរទេស។ តើនេះជាក្មួយស្រីរបស់ នួន ជា ដែរឬទេ?

**ឆ៖** អរគុណ។ ច្បាស់លាស់ណាស់ គឺជាក្មួយរបស់ បងនួន។

**ស៖** តើលោកធ្លាប់មានបានទទួលសមាជិកផ្សេងទៀត នៃគ្រួសារជិតស្និទ្ធរបស់ជនជាប់ចោទ

នៅមន្ទីរស-២១ ដែរឬទេ? តើនៅមន្ទីរស-២១ លោកធ្លាប់ទទួលអ្នកទោសដែលជាសមាជិកក្រុមគ្រួសាររបស់លោក អៀង សារី, ខៀវ សំផន, ឬក៏ នួន ជា ក្រៅពីកម្មាភិបាលដែលយើងបាននិយាយអម្បាញ់មិញនេះ? តើមានលោកធ្លាប់មានបានទទួលទេ?

**ឆ៖** អរគុណ។ បើនិយាយអំពីសមាជិកអចិន្ត្រៃយ៍នៅមានម្នាក់ទៀត ស្លាប់អស់ទាំងពូជ គឺ វន វ៉េត។

[១៣:៥៥:១៩]

**ស៖** ខ្ញុំចង់និយាយអំពីសេចក្ដីសារភាពរបស់ ឡាច វ៉ារី ខ្ញុំកត់សម្គាល់ឃើញនៅ-- នៅទំព័រទីមួយគឺចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ៧៨។ យោងទៅតាមកាលបរិច្ឆេទនេះ តើជាកាលបរិច្ឆេទដែលលោករាយការណ៍ទៅ សុន សេន ឬក៏ នួន ជា ផ្ទាល់តែម្ដង?

**ឆ៖** អរគុណ។ កាលបរិច្ឆេទនេះគឺរយៈកាលដែល បងនួន គ្រប់គ្រង ស-២១ ដោយផ្ទាល់។

**ស៖** តើលោកមានចាំទេថា លោកបានជជែកបញ្ហា-- ពិភាក្សាពីបញ្ហានេះជាមួយនឹង បងធំលេខពីរ?

[១៣:៥៦:២៥]

**ឆ៖** អរគុណ។ ខ្ញុំគ្មានបានពិភាក្សាអីជាមួយនឹង បងនួន ទេ ពីបញ្ហានេះ។

**ស៖** ខ្ញុំចង់និយាយអំពីទំនាក់ទំនងរវាងលោក និង នួន ជា ដែលជាថ្នាក់លើរបស់លោកពាក់ព័ន្ធទៅនឹងខ្លឹមសារនៃចម្លើយសារភាព។ លោកបានបញ្ជាក់ថា នៅពេលខ្លះគឺគាត់បានស្នើសុំឲ្យលោកដកឈ្មោះមនុស្សចេញពីចម្លើយសារភាព។ តើលោកអាចបញ្ជាក់បានទេថា តើការដាក់-- បញ្ហាឲ្យដកឈ្មោះនេះមានកើតឡើងញឹកញាប់មកឬទេ? ហើយមានបញ្ជាក់មូលហេតុទេ? ថាហេតុអីបានមានការស្នើឲ្យដកពាក្យ ដកឈ្មោះមនុស្សមួយចំនួនចេញពីចម្លើយសារភាពនោះ?

[១៣:៥៧:២៨]

**ឆ៖** អរគុណ។ នៅក្នុងសភាពការណ៍ខ្លះ ដែលក្នុងអង្គភាពមួយមានចាប់មនុស្សមកច្រើនហើយសភាពការណ៍នៅក្នុងអង្គភាពនោះខាងលើក្ដាប់បានគួរសមហើយ ខាងលើឲ្យខ្ញុំប្រមូលឯកសារប៉ុន្មានបួនប្រាំទៅ សរុបមើល។ ដល់ប្រមូលឯកសារបានហើយ ឲ្យៗផ្ទៀងមើលអ្នកណាឆ្លើយដាក់អ្នកណាខ្លះ? ហើយឈ្មោះណាត្រូវគេឆ្លើយដាក់ប៉ុន្មាននាក់?

ដូច្នេះករណីនេះមិនច្រើនពេកទេ អង្គាល់ពីសម័យសវនាការសំណុំរឿងលេខ០០១ មានបង្ហាញខ្ញុំ

ម្តង។ ហើយប៉ុន្មានថ្ងៃមុននេះមានបង្ហាញខ្ញុំម្តងទៀត ប៉ុន្តែអត់មានចាប់អ្នកណាទេ។ នេះរបៀបហ្នឹងមានដូចតិចណាស់។ ឯចំណែកជាទូទៅ គឺខ្ញុំឲ្យឯកសារច្បាប់ដើមទាំងដុលទៅខាងលើជាអ្នកជ្រើសរើសទេ។

[១៣:៥៩:២៧]

**ស៖** ពាក់ព័ន្ធទៅនឹងឯកសារដែលលោកបាននិយាយដល់នេះគឺវា-- គឺបានលើកឡើងសួរលោក ហើយលោកបាននិយាយក្នុងសវនាការថ្ងៃទី២០ ខែមីនា ថា "វាយូរពេកភ្លេចអស់ហើយ ក៏ប៉ុន្តែឯកសារមួយអម្បាញ់ហ្នឹង វាច្បាស់ណាស់។ គាត់ណែនាំឲ្យដកឈ្មោះនេះចេញ បើមាន។ ហ្នឹងច្បាស់ហើយមាន ឯកសារនៅហ្នឹង។ មានអ្នកខ្លះឆ្លើយដាក់ប្អូនថ្លៃខ្លួនឯង ហើយនៅពេលមួយនោះ គេឆ្លើយដាក់ ពឿន។ ពឿន ហ្នឹង កូនប្រសាររបស់អៀង សារី ជាមិត្តភក្តិខ្ញុំ។ ដល់ពេលគាត់ឃើញ ខ្ញុំភ័យ គាត់ថា យី! ដូច្នេះ ខ្ញុំត្រឡប់មកផ្ទះវិញ ឲ្យគេដកឈ្មោះ ពឿន ចេញ។ មកដល់ក្រោយទៀត មានម្នាក់ឆ្លើយដាក់ ខៀវ សំផន។ ខ្ញុំទៅរាយការណ៍ជូន នួន ជា។ រឿងទាំងអស់នេះ ខ្ញុំអត់លាក់ទេ រាយការណ៍ជូនការិយាល័យសហព្រះរាជអាជ្ញា-- (សូមទោស) សហចៅក្រមស៊ើបអង្កេតអស់ហើយ"។ តើលោកអាចបញ្ជាក់ពីចំណុចនេះបានទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បញ្ហាដែលយើងខ្ញុំរាយការណ៍ជូនអង្គជំនុំជម្រះវាទៅបញ្ហាមួយផ្សេង។ ឯចំណែកកំណត់នៃសេចក្តីរាយការណ៍របស់ខ្ញុំនៅថ្ងៃ២៧ ខែមីនា ដែលលោកចៅក្រមអាននេះ វាជាបញ្ហាមួយទៅផ្សេង។ ដូច្នេះ ខ្ញុំកំណត់ចុងក្រោយដែលលោកចៅក្រមអាន ខ្ញុំទទួលស្គាល់ថា ពិតជាចេញពីសម្តីខ្ញុំ ហើយពិតជាស្របទៅតាមការពិត។

**ស៖** តើមានវិធាន ឬក៏មានគោលការណ៍អ្វីមួយ ដែលថានៅពេលដែលអ្នកណាម្នាក់ត្រូវបានឆ្លើយដាក់បីដង នៅក្នុងចម្លើយសារភាពនោះ គឺថាអ្នកនុំង ត្រូវគេចាប់ខ្លួន។ តើមានវិធាន ដែលថាមានការឆ្លើយដាក់បីដងនោះ តើមានដែរឬទេ? តើជាការពិតនោះ មាន ឬក៏មិនមាន?

[១៤:០២:០០]

**ឆ៖** អរគុណ។ គ្មានក្រឹត្យក្រមបែបនេះទេ។

**ស៖** ឧទាហរណ៍ នៅពេលដែលលោករាយការណ៍ទៅ នួន ជា អំពីចម្លើយសារភាពដែលឆ្លើយដាក់ ខៀវ សំផន។ តើគាត់មានប្រតិកម្មយ៉ាងម៉េចដែរ នៅពេលនោះ?

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ឡើងវិញ បញ្ហាអំពីប្រតិកម្មបងនួន ចំពោះខ្ញុំ។ គាត់មាន

ប្រសាសន៍ថា ម៉ាស្រុកខ្មែរទាំងអស់ លើកលែងតែខ្ញុំ ហើយនិងបងប៉ុល។ មិត្តឯង បានតែឲ្យទៅធ្វើទូត។ ដល់ឃើញខ្ញុំមានអារម្មណ៍មួយប្រឆាំងតប ព្រោះតែកាលណាបែបនេះមក ខ្ញុំមានសតិអារម្មណ៍មួយប្រឆាំង គេសង្កេតបាន ថាខ្ញុំពេបជ្រាយ។ គាត់ថា ន៎ែ កុំថាធ្វើទូតហ្នឹង វាអន់ណាស់ ពីសង្គមចាស់ សុទ្ធតែស្វកលុយ នេះ ខ្ញុំសូមកែបន្តិច។ ខ្ញុំសូមបញ្ជាក់ថា សេចក្តីដែលខ្ញុំអធិប្បាយលើកមុន នៅត្រង់ដែលថា ទៅធ្វើទូត កុំថាអន់ អាហ្នឹង ខ្ញុំនិយាយមិនអស់ទេ។ ដែលពិត គាត់មានប្រសាសន៍ថា "មិត្តកុំស្មានថាទៅធ្វើទូតអន់! ពីសង្គមចាស់ ទាល់តែស្វកលុយគេ បាន១ទៅធ្វើទូត"។ នេះគាត់មានប្រសាសន៍អ៊ីចឹង។ នេះខ្ញុំសូមកែ មករកអារឿងដែលខ្ញុំនឹកឃើញឡើងវិញ។

[១៤:០៤:៣១]

**ស៖** តើលោកចង់មានន័យថា នៅពេលដែលលោកនិយាយប្រាប់ នួន ជា ថាមានការឆ្លើយដាក់ខៀវ សំផន នៅក្នុងចម្លើយសារភាពនោះ គឺគាត់ចង់អប់អរសាទរថាលោកជាអ្នកការទូតដ៏ល្អ ឬក៏យ៉ាងម៉េច? ឬក៏ផ្ទុយទៅវិញ គឺថាជាការ-- ជាសម្តីដែលធ្វើឲ្យលោកខ្លាច ពីព្រោះថាអ្នកទូតជាច្រើនត្រូវបានឃុំខ្លួននៅបឹងត្របែក ឬក៏កន្លែងផ្សេងទៀត។

**ឆ៖** អរគុណ។ នេះមិនមែនជាការលើកទឹកចិត្តនឹងការងារដែលខ្ញុំបានធ្វើល្អទេ។ នេះជាការព្រមាន។ ព្រោះកាលណាគេដកយកយើងពីការងារមួយដែលមានកម្លាំងក្តាប់ ទៅដាក់ធ្វើជាបុគ្គលសម្រាប់ទៅធ្វើទូត គឺគេតាមដាន ដើម្បីចាប់ហើយ។

**ស៖** ប្រសិនបើខ្ញុំសង្ខេបទៅ តើលោកយល់ទេថា ការឆ្លើយដាក់ខៀវ សំផន នៅក្នុងចម្លើយសារភាពនោះ អាចជាគ្រោះថ្នាក់សម្រាប់ខ្លួនលោកផ្ទាល់នោះ?

**ឆ៖** អរគុណ។ គឺពិតជាអ៊ីចឹងមែន។

**ស៖** សូមអរគុណ។ ខ្ញុំនឹងចូលទៅដល់ប្រធានបទមួយទៀត។ ខ្ញុំចង់ត្រឡប់ក្រោយមកវិញបន្តិច គឺនៅមន្ទីរម-១៣ លោកបាននិយាយអំពីទាហានលន់ នល់ ដែលត្រូវបានចាប់ខ្លួននៅវត្តមួយ គឺវត្តអង្គព្រលឹង ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅមន្ទីរម-១៣។ តើជាទាហានដែលត្រូវបានចាប់ខ្លួននៅក្នុងក្របខ័ណ្ឌនៃសមរភូមិ ឬក៏ជាទាហានដែលចុះចាញ់? តើជាទាហានដោយបែបណាដែរ ទាហាន លន់ នល់ នុ៎ង?

[១៤:០៦:៥៥]

**ឆ៖** អរគុណ។ ដំបូងសូមបញ្ជាក់ថា វត្តនេះមិនមែនវត្តអង្គព្រលឹងទេ គឺវត្តអង្គតាឡឹក។

ឯចំណែកទាហានអស់នេះ វាទាស់គ្នាជាមួយនឹងមេវា។ វាបាញ់គ្នាហើយ វារត់ចូល-- មួយផ្នែកហ្នឹង វារត់ចូលមកតំបន់រំដោះ។ ម្ល៉ោះហើយ វន វ៉េត បំបែកយកប្រពន្ធទៅដាក់នៅខាងថ្មយោង ហើយឲ្យប្ដីមកនៅជាមួយនឹងខ្ញុំ។ ដល់ក្រោយមកនុ៎ង ប្រពន្ធរត់ទៅតំបន់ខ្មាំងវិញ។ ឯចំណែកខាងប្ដីវានៅនេះ ខ្ញុំឲ្យគេតាមដាន ដល់តាមដាន ខ្ញុំឲ្យគេរាយការណ៍បណ្ដើរៗទៅ ដល់ក្រោយមក វន វ៉េត គាត់សម្រេចឲ្យចាប់។

**ស៖** តើទាហានទាំងអស់នេះជាទាហានរត់ចោលជួរ ហើយដែលចុះចូល ឬក៏យ៉ាង-- ដែលចុះចូលនៅក្នុងតំបន់រំដោះឬក៏យ៉ាងម៉េច? ឬក៏គេចពីទាហានសាធារណរដ្ឋចូលមកតំបន់រំដោះ? តើអ៊ីចឹងមែនទេ?

**ឆ៖** ត្រូវ! ក៏ប៉ុន្តែមុននឹងមកហ្នឹង វាទាស់គ្នាសិន វាបាញ់គ្នាសិន។

**ស៖** លោកក៏បាននិយាយផងដែរ អំពីអ្នកទោសដែលត្រូវបាននាំទៅមន្ទីរម-១៣ ដោយ តាម៉ុក បន្ទាប់ពីមានការទម្លាក់គ្រាប់បែកនៅភូមិភាគនិរតី។ តើអ្នកណាខ្លះជាអ្នកដែលត្រូវបាន តាម៉ុក បញ្ជូនទៅមន្ទីរម-១៣ នុ៎ង?

[១៤:០៩:២០]

**ឆ៖** អរគុណ។ បុគ្គលនេះជាកូនចៅចិន ជាកូនចិន ឈ្មោះវា ឈ គីមប៉ាង-- សូមទោសៗ ឈ គាងហេងៗ។ គាត់ឲ្យគេតាមដានបុគ្គលនេះយូរហើយ។ គាត់ក្ដាប់បានថា បុគ្គលនេះជាក្មួយរបស់ៗ ឈ ស៊ីមប៉ាង មេប៉ូលិស មេគិញរបស់ លន់ នល់។ ដល់ពេលទម្លាក់គ្រាប់បែកអ៊ីចឹង គាត់ឲ្យគេចាប់ព្រោះគេសង្កេតឃើញបុគ្គលនេះ ជិះទៅ-- ពីព្រោះគាត់ឲ្យគេសង្កេតតាមដានឃើញបុគ្គលនេះ មុននឹងទម្លាក់គ្រាប់បែកជិះទៅ-- ជិះម៉ូតូទៅផ្សារសំរោង បីថ្ងៃមុនទម្លាក់គ្រាប់បែក វាជិះម៉ូតូទៅផ្សារសំរោង។

[១៤:១០:៥៨]

**ស៖** អ៊ីចឹងគាត់ត្រូវបានចាប់ខ្លួន ដោយគេសង្ស័យថា គាត់បានផ្ដល់ព័ត៌មានសម្រាប់ការទម្លាក់គ្រាប់បែក។ តើអ៊ីចឹងមែនទេ?

**ឆ៖** អរគុណ។ ត្រឹមត្រូវ។

**ស៖** លោកបាននិយាយអំពី ខៀវ សំផន ក្នុងអំឡុងចន្លោះឆ្នាំ៧០ និង៧៥ ហើយលោកបានបញ្ជាក់ថា គាត់ដឹកនាំមន្ទីរមជ្ឈិម។ លោកបានពន្យល់ជាច្រើនរួចមកហើយ ប៉ុន្តែដើម្បីឲ្យបានយល់ច្បាស់នោះ។ តើលោកអាចបញ្ជាក់ជូនបានទេ ថាមន្ទីរមជ្ឈិមមួយណា ដែលលោកសំដៅដល់នោះ?

**ឆ៖** អរគុណ។ តាមព័ត៌មានដែលពួកបញ្ញាជនទទួលបាន គឺដំបូងពីឆ្នាំ៧១ ដល់៧៥ បង ខៀវ សំផន នៅជាប់ជាមួយនឹងបង ប៉ុល ពត ទទួលភារៈខាង-- និយាយឲ្យចំមួយម៉ាត់ ដែលភាសាឥឡូវ លេខាធិការដ្ឋានរបស់បង ប៉ុល ពត របស់មជ្ឈិមបក្ស។ គាត់កាន់កាប់ការិយាល័យលេខាធិការដ្ឋាន របស់ ប៉ុល ពត។ ដល់ក្រោយឆ្នាំ១៩៧៥ ទើបបាន១ ខ្ញុំឃើញគាត់មានអង្គភាពកាន់ ភស្តុតាងដូចខ្ញុំនិយាយអ៊ីចឹង ដូចខ្ញុំបាន-- មានអង្គភាពកាន់ មិនមែនតែមួយទេ បែបគឺច្រើន ប៉ុន្តែដែលខ្ញុំដឹងច្បាស់គឺ១ ចាក់អង្រែ រោងចក្រអគ្គិសនីចាក់អង្រែលើ មានឈ្មោះ រោងចក្រអគ្គិសនីចាក់អង្រែលើ។

[១៤:១៣:២៨]

**ស៖** នៅពេលដែលលោកនិយាយថា ខៀវ សំផន ជាលេខារបស់ ប៉ុល ពត នោះ តើលោកចង់មានន័យថា គាត់ជាលេខារបស់គណៈមជ្ឈិម ឬក៏ជារឿងពីរផ្សេងគ្នា?

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់បញ្ហានេះម្តងទៀត។ គាត់កាន់កាប់ការិយាល័យលេខាធិការដ្ឋាន របស់ ប៉ុល ពត។ ដូច្នេះ ឯកសារទាំងប៉ុន្មានរបស់មជ្ឈិមនៅលើដៃគាត់ គាត់ដឹង គាត់ឮ គាត់ជួយចាំ។

**ស៖** នៅពេលដែលលោកនិយាយថា គាត់ជាអ្នកទទួលខុសត្រូវខាងឯកសារ តើមានន័យថា គាត់ជាអ្នកទទួលសារទាំងអស់ដែលផ្ញើជូន ប៉ុល ពត ឬក៏យ៉ាងម៉េច?

**ឆ៖** រឿងរ៉ាវសំខាន់ៗ ប៉ុល ពត ឲ្យគាត់ដឹង ឲ្យគាត់ទុកដាក់ ឲ្យគាត់ជួយចាំ នេះប្រធានមន្ទីរ ជំនាន់នុ៎ងមានន័យអ៊ីចឹង។

**ស៖** មន្ទីរនេះ តើជាមន្ទីរ៨៧០ ហ្នឹងមែនទេ?

[១៤:១៥:០០]

**ឆ៖** មុនឆ្នាំ១៩៧៥ មិនដឹងជាឈ្មោះអីទេ ប៉ុន្តែក្រោយ១៧ មេសា ១៩៧៥ ពិតជាមានឈ្មោះ ៨៧០។

**ស៖** ដូច្នេះតើ ខៀវ សំផន ជាលេខា ឬក៏ជាប្រធានមន្ទីរ៨៧០?

**ឆ៖** អរគុណ។ ខៀវ សំផន បើតាមខ្ញុំដឹង មិនមែនជាស្មៀនផ្ទាល់ទេ។ គឺជាអ្នកដឹងខុស ដឹងត្រូវ នៅលើឯកសារទាំងមូល នៅលើសេចក្តីសម្រេចទាំងមូលរបស់ ប៉ុល ពត។ បញ្ហានីមួយៗអាចមាន ស្មៀនផ្សេងទៀតគេធ្វើ។

[១៤:១៦:២៥]

**ស៖** តើមានន័យថា មានមនុស្សណាម្នាក់ជាប្រធាននៃមន្ទីរ៨៧០ ដែលមិនមែនជា ខៀវ សំផន

ទេ ហើយខៀវ សំផន អាចចូលទៅមើលព័ត៌មានបានទាំងអស់ដែលផ្ញើទៅមន្ទីរ៨៧០ តើមានន័យថា អ៊ីចឹងមែនទេ?

**ឆ៖** អរគុណ។ អ្នកដែលទទួលខុសត្រូវពីលើហ្នឹងមានតែពីរនាក់ទេ គឺប៉ុល ពត និង នួន ជា។ ឯចំណែកឯកសារទាំងអស់ស្ថិតការយល់ដឹងទាំងអស់ គឺនៅលើដៃ ខៀវ សំផន។

**ស៖** ពាក់ព័ន្ធទៅនឹងមន្ទីរ៨៧០នេះ តើលោកអាចបញ្ជាក់ជូនបានទេថា តើអ្នកណាខ្លះដែលជាសមាជិកមន្ទីរ៨៧០ ហើយដែលត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរស-២១នោះ តើមានប៉ុន្មាននាក់? ហើយបានបញ្ចប់-- ចាប់ផ្តើមនៅពេលណា ហើយក៏បញ្ចប់ទៅវិញនៅពេលណា?

[១៤:១៧:៣៩]

**ឆ៖** អរគុណ។ ក្រោយ១៧ មេសា ១៩៧៥ អ្នកដែលជា ដែលមានឈ្មោះនៅជាប់ជាប្រធានមន្ទីរ៨៧០ គឺទីមួយ យ៉ែម បងយ៉ែម ហៅឈ្មោះដើម ស៊ឹម សុន។ ហើយទីពីរ ឌឿន ឈ្មោះដើម សឿ វ៉ាស៊ី។ ហើយកំណត់ហេតុហ្នឹង មិត្តទូច ឈ្មោះដើម ភោគ ឆាយ។ ភោគ ឆាយ ហៅ ទូច។ បងយ៉ែម គេឲ្យទៅធ្វើទូតនៅកូរ៉េ។ សឿ វ៉ាស៊ី ហៅ ឌឿន គេឲ្យចេញតាមសំណូមពរទៅពាណិជ្ជកម្ម ដល់ក្រោយមកគេចាប់។ ហើយចំណែក ភោគ ឆាយ ហៅ ណាង ដែលជាអ្នកកំណត់ហេតុហ្នឹង ក្រោយមកក៏គេចាប់ដែរ។ ដូច្នេះអ្នកចាប់ពីរនាក់ គឺ សឿ វ៉ាស៊ី ហៅ ឌឿន និង ភោគ ឆាយ ហៅ ណាង។

[១៤:១៩:៤៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរដែលត្រូវសួរសាក្សីរូបនេះហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។ អស់លោក លោកស្រីចៅក្រមមានសំណួរអីចង់សួរដល់សាក្សីរូបនេះដែរទេ?

**សួរដោយប្រធានអង្គជំនុំ៖**

លោក កាំង ហ្កេកអ៊ាវ យើងមានសំណួរខ្លះចង់សួរទៅលោក ដោយសារមានបញ្ហាហាក់ដូចជាមិនច្បាស់លាស់នៅឡើយ។

**ស៖** សំណួរសួថា តើរចនាសម្ព័ន្ធនៃអង្គការរដ្ឋជុំវិញនាយករដ្ឋមន្ត្រីកាលពីសម័យកម្ពុជាប្រជា-ធិបតេយ្យ តើគេរៀបចំនូវអង្គការរដ្ឋយ៉ាងដូចម្តេច? ហើយមានអង្គការរដ្ឋអ្វីខ្លះទៅ? ដោយមិនចាំបាច់

រៀបរាប់អំពីរដ្ឋសភា ឬក៏តុលាការទេ ពីព្រោះលោកបានឆ្លើយរួចហើយ។

[១៤:២១:០១]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អង្គការរដ្ឋដែលដើរតួនាទីសំខាន់បំផុត គឺរដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី-- នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី។ នាយករដ្ឋមន្ត្រីគឺ ប៉ុល ពត។ ឧបនាយកទីមួយ គឺលោកគ្រូ អៀង សារី ហៅ វ៉ាន់។ ឧបនាយករដ្ឋមន្ត្រីទីពីរ គឺ វន វ៉េត ហៅ វន ហើយនិងឧបនាយករដ្ឋមន្ត្រីទីបី គឺ សុន សេន។ ឧបនាយរដ្ឋមន្ត្រីទីមួយ ទទួលបន្ទុកការងារបរទេស ទាំងរវាងបក្សនិងបក្ស ទាំងរវាងរដ្ឋ និងរដ្ឋ។ ឯចំណែកសេដ្ឋកិច្ចនៅលើដៃ វន វ៉េត។ ឯចំណែកខាង សុន សេន ទទួលបន្ទុកសេនាធិការផង ដែលហៅថា គេហៅថា ក្រសួងការពារជាតិនោះ ហើយនិងនគរបាលផង។

[១៤:២១:៥៦]

ក្រៅពីនោះមានរដ្ឋមន្ត្រីផ្សេងទៀត ដូចជារដ្ឋមន្ត្រីខាងឃោសនាអប់រំ អ្នកបង យុន យ៉ាត។ រដ្ឋមន្ត្រីខាងសង្គមកិច្ចអ្នកបង ធីរិទ្ធ ក្រៅពីនោះចាត់តាំងជាគណៈកម្មាធិការក្រសួង លើកលែងតែពាណិជ្ជកម្មរដ្ឋមួយដំបូងចាត់តាំងជានាយករដ្ឋមន្ត្រី-- អឺ! ជារដ្ឋមន្ត្រី។ រដ្ឋមន្ត្រីពាណិជ្ជកម្ម គឺ កុយ ធួន ក៏ប៉ុន្តែដល់ក្រោយមកឈប់ចាត់តាំងជារដ្ឋមន្ត្រី ចាត់តាំងជាគណៈកម្មាធិការពាណិជ្ជកម្ម។ ដូច្នេះមានគណៈកម្មាធិការច្រើនផ្សេងទៀត ដូចជាគណៈកម្មាធិការថាមពល គណៈកម្មាធិការពាណិជ្ជកម្ម គណៈកម្មាធិការកសិកម្ម គណៈកម្មាធិការឧស្សាហកម្ម គណៈកម្មាធិការដឹកជញ្ជូនជើងទឹក គណៈកម្មាធិការដឹកជញ្ជូនជើងគោក គណៈកម្មាធិការកំពង់ផែកំពង់សោម ហើយនិងគណៈកម្មាធិការរទេះភ្លើងមួយទៀត នេះខ្ញុំរាប់អាចខ្វះ។

[១៤:២៣:០៥]

ដូច្នេះ ក្បាលម៉ាស៊ីនគឺនៅលើនាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រីទាំងបី។

**ស៖** បើមិនច្រឡំទេ យើងអាចយល់-- យើងយល់អ៊ីចេះថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺបណ្តាអង្គការរដ្ឋជុំវិញនាយករដ្ឋមន្ត្រី គឺចែកចេញជាពីរប្រភេទ។ បានន័យថា មួយចំនួនកំណត់ថាជាក្រសួង ដូចជាក្រសួងឃោសនាការ ក្រសួងអប់រំ ក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេស ក្រសួងការពារជាតិជាដើម។ ហើយក្រៅពីនេះមានបង្កើតជាគណៈកម្មាធិការកម្រិតមន្ទីរ។ មន្ទីរផ្សេងទៀត

ដែលមន្ទីរហ្នឹងមិនមែនជារដ្ឋមន្ត្រីទេ គឺចាត់តាំងត្រឹមកម្រិតជាគណៈកម្មាធិការគ្រប់គ្រងមន្ទីរជំនាញមួយចំនួនដែលលោកបានរៀបរាប់អម្បាញ់មិញនេះ។ អ៊ីចឹងពិតមែនទេ?

[១៤:២៤:០២]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ត្រឹមត្រូវ។ ការវិភាគបែបនេះ ត្រឹមត្រូវ។

**ស៖** បាទ អរគុណ។ ហើយមួយទៀតតាមបទពិសោធន៍ក្នុងការដែលលោកបំពេញមុខងារជាប្រធានមន្ទីរស-២១ ទាំងបទពិសោធន៍ក្នុងការធ្វើការងារ ទាំងការសង្កេតរបស់លោក តើលោកធ្លាប់បានទទួលការបញ្ជូនមនុស្សពីបណ្ដាក្រសួង ឬក៏ពីមន្ទីរដែលគ្រប់គ្រងដោយគណៈកម្មាធិការអម្បាញ់មិញនេះដែលយើងកំណត់ថា ជាស្ថាប័ននៅជុំវិញនាយករដ្ឋមន្ត្រីមកដល់មន្ទីរស-២១ ដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន មានពេលខ្លះក្រសួង ឬក៏គណៈកម្មាធិការគេបញ្ជូនមក ក៏ប៉ុន្តែសេចក្ដីសម្រេចនៅពីលើ ខាងលើឲ្យព័ត៌មានមកខ្ញុំមុនហើយស្រេច។ ហើយឲ្យរង់ចាំទទួលខាងបុគ្គលិក ខាងអង្គភាពដើមរបស់គេៗបញ្ជូនមក នេះមានជាហូរហែ។

**ស៖** តាមធម្មតាដែលលោកប្រើពាក្យថា "គណៈកម្មាធិការមន្ទីរជំនាញ មន្ទីរលក្ខណៈ-- មានចរិតលក្ខណៈដោយឡែកអម្បាញ់មិញនេះ ដូចជាកំពង់ផែកំពង់សោម ដូចជាថាមពល ដូចជាពាណិជ្ជកម្មរដ្ឋ ដូចជាកសិកម្មរដ្ឋ" ជាដែរដើម។ ពាក្យថា "គណៈកម្មាធិការ" ហ្នឹងរួមមានសមាសភាពយ៉ាងម៉េចដែរទៅ? វាដូចគ្នានឹងគណៈកម្មាធិការគ្រប់គ្រងមន្ទីរស-២១ ឬក៏គណៈកម្មាធិការគ្រប់គ្រងថ្នាក់ស្រុក ឬថ្នាក់តំបន់អ៊ីចឹងដែរឬទេ? ឬក៏មានលក្ខណៈពិសេសដោយឡែករបស់វា?

[១៤:២៦:០០]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន គណៈកម្មាធិការ បើនិយាយក្នុងផ្ទៃបក្សគណៈកម្មាធិការស្រុក ស្មើនឹងគណៈកម្មាធិការមន្ទីរស-២១។ ឯចំណែកគណៈកម្មាធិការក្រសួងខ្លះដូចជាក្រសួងសង្គមកិច្ច ក្រសួងឃោសនាអប់រំមានសិទ្ធិប៉ុនគណៈកម្មាធិការតំបន់ ហើយក៏ប៉ុនកងពល។ វាមានលក្ខណៈវាអ៊ីចឹងដែរ។ ដោយឡែកប្លែកគ្នាតែឯកទេស។ ពាក្យថាក្រសួងម្យ៉ាងវាគ្របដណ្ដប់ទូទាំងប្រទេស។ ឧទាហរណ៍ដូចក្រសួងថាមពល វាគ្របដណ្ដប់ទូទាំងប្រទេស។ វិសាលភាពនៃការងារវាគ្របដណ្ដប់ទូទាំងប្រទេស។ ឯចំណែកគណៈកម្មាធិការមន្ទីរអត់គ្របដណ្ដប់ទូទាំងប្រទេសទេ ផ្នែកការងារមួយនៅហ្នឹង។

[១៤:២៧:៥៧]

**ស៖** ចុះសមាសភាពគណៈកម្មាធិការមន្ទីរ ដែលលោកបានលើកឡើងអំមិញនេះមានសមាសភាពអ្នកណាខ្លះទៅ?

**ឆ៖** មានបក្សជនម្នាក់ជាលេខា ហើយម្នាក់ទៀតជាអនុលេខា ក្រៅពីនោះមានសមាជិកបក្សផ្សេងទៀតច្រើន ពីប្រាំបួននាក់ឡើង។

[១៤:២៧:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

មន្ត្រីរដ្ឋបាលតុលាការបញ្ចាំងឯកសារលេខ E/12 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ហើយដាក់តែយកតែទំព័រទីមួយបានហើយ គឺលេខជាភាសាខ្មែរ ERN 00003136 លេខ ERN ជាភាសាអង់គ្លេស 00182809 ហើយ ERN ជាភាសាបារាំង 00224363។

ហើយនិងយកឯកសារនេះទៅជូនគាត់ដើម្បីពិនិត្យ! ដោយឯកសារនេះមានផ្តាប់ដេញដោលរួចហើយកន្លងមក យើងសួរសំណួរតែខ្លះមួយចំនួនប៉ុណ្ណោះ ពាក់ព័ន្ធនឹងបញ្ហានេះ។

[១៤:២៨:៣៧]

**សួរដោយប្រធានអង្គជំនុំ៖**

សូមសាក្សីពិនិត្យលើចំណុចដែល *ហៃឡៃត៍* គឺត្រង់ចំណុចដើមដំបូង គឺ "សំណូមពរនៃសិទ្ធិសម្រេចកម្មេចក្នុងជួរ និងក្រៅជួរ" សំណូមពរត្រង់ចំណុចទីពីរ ហើយនិងកថាខណ្ឌទីពីរ ហើយចំណុចទីពីរ គឺ "ជុំវិញមន្ទីរមជ្ឈិមត្រូវគណៈមន្ទីរមជ្ឈិមសម្រេច"។ ដោយបញ្ហាដែលលោកលើកឡើងអម្បាញ់មិញនេះ គឺរវាងគណៈក្រសួង គ្រប់គ្រងក្រសួង ហើយនិងគណៈគ្រប់គ្រងមន្ទីរជុំវិញនាយករដ្ឋមន្ត្រី ឬក៏ជារដ្ឋាភិបាលនោះ គឺរួមមានពីរប្រភេទដែលខ្ញុំបានសួរលោក ហើយលោកសាក្សីបានបញ្ជាក់ហើយថាជាការយល់ហ្នឹងត្រឹមត្រូវ។

**ស៖** សំណួរសួរថា ប្រសិនបើគ្រប់មនុស្សកម្មាភិបាលបុគ្គលិកនៃមន្ទីរជុំវិញមជ្ឈិមដែលមានបញ្ហា ហើយត្រូវបានចាប់ខ្លួនបញ្ជូនមកឃុំឃាំងសួរចម្លើយ ហើយនិងកម្ទេចនៅស-២១ ដែលលោកសាក្សីបានបង្ហាញត្រួសៗអំមិញនេះ ថាតើអ្នកណាជាអ្នកមានសិទ្ធិសម្រេចឲ្យកម្ទេចដូច្នេះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ជុំវិញមន្ទីរមជ្ឈិមត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។ កថាខណ្ឌត្រង់នេះ បានន័យថាត្រូវ ខៀវ សំផន ជាអ្នកសម្រេច។ នេះគោលការណ៍ដែល

កំណត់នៅក្នុងកថាខណ្ឌនេះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ខ្ញុំក៏អស់សំណួរហើយដែរ ហើយដល់ពេលសមល្មមនឹងសម្រាកដែរហើយ។

អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយចូលមកវិញ គឺនឹងចាប់ផ្ដើមសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្ដីលោក នួន ជា។

ហើយអនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សីទៅបន្ទប់សម្រាករបស់សាក្សី ហើយនិងឱ្យអញ្ជើញគាត់មកកាន់បន្ទប់សវនាការកន្លែងផ្ដល់សក្ខីកម្មនៅវេលាម៉ោងបីខ្វះដប់នាទី។

**ក្រឡាបញ្ជី៖**

ក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣១ នាទី ដល់ម៉ោង ១៤:៥៥ នាទី)*

[១៤:៥៤:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការសវនាការ ហើយវេទិកាជាបន្តនេះ អង្គជំនុំជម្រះនឹងប្រគល់ជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដែលនឹងអាចតាំងសំណួរដេញដោលចំពោះសាក្សីនេះមុនមេធាវីការពារក្ដីពីរក្រុមទៀត។ ហើយមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា អង្គជំនុំជម្រះប្រកាសនូវសេចក្ដីសម្រេចរបស់ខ្លួន លើសំណើសុំរបស់ភាគី ដែលបានលើកឡើងកាលពីព្រឹកមិញដូចតទៅនេះ៖

សេចក្ដីសម្រេចពាក់ព័ន្ធនឹងសេចក្ដីជំទាស់ទៅនឹងឯកសារ អង្គជំនុំជម្រះនឹងចេញនៅពេលសមស្របខាងមុខ។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមានបំណងឆ្លើយតបទៅនឹងសំណើសុំ កាលពីព្រឹកមិញនេះ ពាក់ព័ន្ធនឹងសាក្សីរូបនេះ។ អង្គជំនុំជម្រះសូមបញ្ជាក់ថា កំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយ កាំង ហ្កេកអ៊ាវ ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងអំឡុងពេលកិច្ចស៊ើបសួរក្នុងសំណុំរឿង០០២ ឬក្នុងអំឡុងពេលកិច្ចស៊ើបសួរក្នុងសំណុំរឿង០០១ និងដែលត្រូវបានដាក់

បញ្ចូលទៅក្នុងសំណុំរឿង០០២ ត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយមិនគិតថា តើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយទាំងនោះ ត្រូវបានលើកមកពិភាក្សានៅក្នុងសវនាការ។

[១៤:៥៧:២៦]

ឯកសារទាំងអស់នេះ ត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះទាំងស្រុង ហើយអាចជាមូលដ្ឋានសម្រាប់ការសួរសំណួរទៅកាន់សាក្សីរូបនេះ។ ទាក់ទិននឹងប្រតិចារឹកសំណុំរឿង០០១ ភាគីអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះ នូវផ្នែកពាក់ព័ន្ធនៃប្រតិចារឹក។ ប៉ុន្តែត្រូវបញ្ជាក់ឲ្យបានច្បាស់នូវផ្នែកទាំងឡាយ ដែលខ្លួនមានបំណងប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការសួរសំណួរ។

ជាចុងក្រោយ អង្គជំនុំជម្រះសូមបញ្ជាក់ម្តងទៀតនូវសេចក្តីសម្រេចរបស់ខ្លួន ក្នុងកថាខណ្ឌ៤នៃអនុស្សរណៈរបស់ខ្លួន ឯកសារលេខ E172/5 ដែលបានកំណត់ថា ឯកសារទាំងអស់ដែលភ្ជាប់មកជាមួយកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសារក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់សក្ខីកម្មមកទល់នឹងពេលបច្ចុប្បន្ន និងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងឡាយដែលត្រូវបានបង្ហាញអត្តសញ្ញាណនៅក្នុងអនុស្សរណៈ E172 សម្រាប់សវនាការនៅពេលបន្ទាប់ នឹងត្រូវចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ជាមួយនឹងសក្ខីកម្មរបស់បុគ្គលនោះ លើកលែងតែមានការជំទាស់ពីភាគីក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្ម។

[១៤:៥៨:៥៣]

បាទ នេះជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឆ្លើយតបទៅនឹងការស្នើសុំរបស់ភាគីកាលពីព្រឹកមិញ។ ជាបន្តនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រសិនបើមានសំណួរ។ សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិនៈ**

សូមអរគុណលោកប្រធាន យើងខ្ញុំប្រាកដជាមាន។ មុនពេលខ្ញុំចាប់ផ្តើមសួរសំណួរកូនក្តីរបស់ខ្ញុំគាត់លើកឡើងថា គាត់ចង់ធ្វើអត្ថាធិប្បាយ ឬក៏ឆ្លើយតបដោយខ្លីៗទៅលើសក្ខីកម្មដែលបានផ្តល់ជូនដោយសាក្សីរូបនេះ។ ដូច្នេះ លោក នួន ជា សូមថា សុំរយៈពេល៥នាទី នៅថ្ងៃស្អែក ដើម្បីធ្វើអត្ថាធិប្បាយ ជាពិសេសសុំនៅពេលព្រឹក។

ចំពោះយើងខ្ញុំ យើងខ្ញុំត្រូវការរយៈពេលពីរថ្ងៃដេញដោលទៅលើសាក្សីរូបនេះ ហើយយើងខ្ញុំសង្ឃឹមថា យើងខ្ញុំនឹងបានដេញដោល ចប់សព្វគ្រប់ទៅលើសាក្សីរូបនេះ។ ដូច្នេះតើលោកប្រធានអនុញ្ញាតទេ?

[១៥:០០:១៥]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោក ឌុច ខ្ញុំកត់សម្គាល់ឃើញកាលពីព្រឹកមិញ នៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីបានសួរសំណួរទៅកាន់លោក ហើយនៅពេលដែលសហព្រះរាជអាជ្ញាបានសួរសំណួរលោកកាលពីសប្ដាហ៍មុន ខ្ញុំបានឃើញថា លោកបានមើលទៅសហព្រះរាជអាជ្ញា ក្នុងពេលដែលលោកស្ដាប់សំណួរ និងឆ្លើយសំណួរ។ ក៏ប៉ុន្តែនៅព្រឹកមិញនេះ ខ្ញុំមើលទៅ លោកមិនបានមើលមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាល់តែសោះ តើលោកមានហេតុផលអ្វីបានជាមិនមើលមុខ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ អាកប្បកិរិយានិយាយជាមួយគ្នា ហើយមើលមុខគ្នា។ ខ្ញុំយល់ថាជាអាកប្បកិរិយាមួយដែលពួកអឺរ៉ុបយល់ថា ជាការនិយាយត្រង់ទៅត្រង់មកអស់ពីពោះ។ អ៊ីចឹងហើយ បានៗជាមួយសហព្រះរាជអាជ្ញា ខ្ញុំមើលមុខគាត់ គាត់មើលមុខខ្ញុំ។ នេះជាបញ្ហាសំខាន់។ ដោយឡែក មានការកែតម្រូវ យើងខ្ញុំអត់ឆ្លើយឆ្លងជាមួយនឹងព្រះរាជអាជ្ញា ឬដើមបណ្ដឹងរដ្ឋប្បវេណីទេ។ យើងខ្ញុំរាយការណ៍ជូនប្រធានអង្គប្រជុំ។ ដូច្នេះហើយ បានខ្ញុំមើលមុខប្រធានអង្គប្រជុំ។

**ស៖** សូមអរគុណ។ ខ្ញុំសូមឲ្យលោកមើលខ្ញុំដែរ នៅពេលដែលខ្ញុំសួរសំណួរ។ ទោះបីជា ខ្ញុំដឹងនិងឯកភាពជាមួយលោក ថានៅទីនេះ យើងមកដើម្បីឆ្លើយជូនអង្គជំនុំជម្រះក៏ដោយ។

[១៥:០២:៤៤]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន តើខ្ញុំអាចសួរបន្តទៀត បានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ឌុច អនុវត្តតាមការណែនាំរបស់ប្រធានអង្គជំនុំ។ ដោយកាលពីសប្ដាហ៍មុន អង្គជំនុំជម្រះបាន

កត់សម្គាល់ឃើញថា ឌុច បានបែរមុខនិយាយទៅកាន់ភាគីម្ខាងនៃការតាំងសំណួរ ដែលការអនុវត្តនៅកម្ពុជាមិនអាចធ្វើដូច្នេះទេ ពីព្រោះសក្ខីកម្មដែលសាក្សីផ្តល់ឱ្យគឺនិយាយឱ្យអង្គជំនុំជម្រះស្តាប់ ដើម្បីយកចិត្តទុកដាក់ស្តាប់នូវការផ្តល់សក្ខីកម្មរបស់អ្នកដែលត្រូវផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។ លើកលែងតែតាមធ្លាប់ថា វាធ្វើដូច្នេះ វារឹងខ្លួន ដូចថាវាឆ្គងពេក ចៀសមិនរួចក្នុងការមើល ពីព្រោះមនុស្សខ្លះវាមានទម្លាប់។ ទម្លាប់ថា និយាយត្រូវតែមើលមុខគ្នាអ៊ីចឹង បានខួរក្បាលហ្នឹងវាដើរ ហើយអាចជ្រះស្រឡះ ហើយនិយាយឆ្លើយឆ្លងទៅវាក្បោះក្បាយអីអ៊ីចឹង។ តែប្រសិនបើស្ថានភាពនេះ មិនចាំបាច់ទេ គឺលោកអង្គុយរបៀបនេះ ហើយសំខាន់គឺមើលមកអង្គជំនុំជម្រះ ក្នុងន័យថា និយាយព័ត៌មាន ផ្តល់ព័ត៌មានហ្នឹងគឺសំខាន់ មកឱ្យអង្គជំនុំជម្រះបានដឹងអំពីព័ត៌មានដែលសាក្សីផ្តល់សក្ខីកម្ម។

នេះជាការណែនាំរបស់អង្គជំនុំជម្រះ។

[១៥:០៤:១៩]

**លោក ម៉ែខល ផេសមិន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** នៅថ្ងៃ០២ ខែមេសា គឺម្សិលមិញនេះឯង។ សំណួរចុងក្រោយ សហព្រះរាជអាជ្ញាបានសួរទៅកាន់លោក។ សំណួរនោះ គឺថាតើលោកនិយាយតែការពិតដែរឬទេ ក្នុងតុលាការនេះ នៅពេលដែលលោកមកផ្តល់ចម្លើយក្នុងនាមជាសាក្សី? ខ្ញុំស្តាប់ចម្លើយ ការឆ្លើយរបស់លោក ហើយចម្លើយរបស់លោកដែលឆ្លើយនោះ ហាក់ដូចជាមានលក្ខណៈស្រពេចស្រពិល។ ដូច្នេះ ខ្ញុំសូមអានឱ្យលោកស្តាប់ឡើងវិញ ហើយឱ្យលោកជួយបញ្ជាក់បំភ្លឺឡើងវិញ។ ខ្ញុំសូមដកស្រង់សម្តីលោក៖

"លោកប្រធាន ខ្ញុំ អ្វីដែលខ្ញុំនិយាយកាលពីថ្ងៃនោះ គឺខ្ញុំប្រកាន់យកសម្តីទាំងអស់នោះ សូម្បីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតក៏ដោយ សូម្បីនៅក្នុងសំណុំរឿង០០១ ក៏សុទ្ធតែជាការពិត"។ អ៊ីចឹងតើលោកចង់បានន័យយ៉ាងម៉េចដែរ នៅពេលដែលលោកនិយាយចំណុចទាំងអស់នេះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ការដកស្រង់សម្តីរបស់ខ្ញុំយកមកនិយាយនេះមិនទាន់គ្រប់នៅឡើយទេ នៅខ្វះពីរម៉ាត់ទៀត។ ទីមួយ ពេលខ្លះខ្ញុំនិយាយជាគោលការណ៍ ខ្លី ដូចជាខ្ញុំបានរាយការណ៍ជូនចៅ ក្រមឡាវែន៍។ ពេលខ្លះខ្ញុំនិយាយជាក់ស្តែងវាចូលក្នុងរឿងលម្អិត។ ក៏ប៉ុន្តែទាំងអស់គ្នា-- ទាំងអស់នេះសុទ្ធតែឈរនៅលើការពិត ដែលខ្ញុំបានឃើញ បានដឹង បានឮ និងបានធ្វើ។ នេះខ្ញុំ

សូមបញ្ចប់ប៉ុណ្ណឹង។

[១៥:០៦:២០]

**ស៖** លោកបាន-- ត្រូវបានសហចៅក្រមស៊ើបអង្កេតសួរយ៉ាងច្រើននៅក្នុងសំណុំរឿង០០១ និង ០០២ ដូច្នេះ តើលោកតែងតែជម្រាបការពិតទៅដល់សហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** អរគុណ។ ខ្ញុំពិតជាជម្រាបការពិតទៅជូនសហចៅក្រមស៊ើបអង្កេត។

**ស៖** លោកក៏បាននិយាយផ្ដល់ចម្លើយជូនសហ-- ជូនព្រះរាជអាជ្ញា និងចៅក្រមនៅតុលាការយោធា។ ដូច្នេះ អ្វីដែលលោកនិយាយនៅតុលាការយោធា និងនិយាយប្រាប់អយ្យការនៅទីនោះនោះ តើជាការពិតដែរឬទេ?

**ឆ៖** អរគុណ។ ទាំងអស់នោះ គឺសុទ្ធតែជាការពិត។

**ស៖** នៅក្នុងសំណុំរឿង០០១ តើលោកបាននិយាយតែការពិតដែរឬទេ?

**ឆ៖** អរគុណ។ នៅក្នុងសំណុំរឿង០០១ ខ្ញុំនិយាយតែការពិត។

**ស៖** ចុះនៅក្នុងឆ្នាំ១៩៩៩ លោកនិយាយជាមួយនឹង គ្រីស្តូហ្វ័រ ប៉េស្ទ័ តើលោកប្រាប់គាត់តែការពិតដែរទេ?

**ឆ៖** អរគុណ។ ខ្ញុំនិយាយជាមួយនឹង គ្រីស្តូហ្វ័រ ប៉េស្ទ័ ក៏ខ្ញុំនិយាយតែការពិត។

**ស៖** លោកនិយាយជាមួយនឹង នីក ដងឡុប ជាអ្នកកាសែតក្នុងឆ្នាំនោះផងដែរ រួមជាមួយនឹង លោក នេត ថាយ័រ។ តើលោកប្រាប់អ្នកទាំងពីរនោះតែការពិតដែរឬទេ?

[១៥:០៨:៤៥]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ពីរនាក់នេះយកពាក្យខ្ញុំមួយម៉ាត់ពីរម៉ាត់ទៅបំភ្លៃច្រើនណាស់។ អ្នកកាសែតពីររូបនេះ អត់យកជាការបានទេ។ ខ្ញុំបដិសេធពាក្យអត្ថាធិប្បាយរបស់អាពីរនាក់នេះ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងត្រឡប់មកចំណុចនេះឡើងវិញ។ តើលោកមានបានដឹង និងស្គាល់អំពីពាក្យដែលថា និយាយការពិត ខាងផ្នែកសេដ្ឋកិច្ចដែរទេ ដើម្បីជាការសន្សំសំចៃដែរទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់យល់សំណួរនេះទេ។ សូមសួរឲ្យច្បាស់លាស់បន្តិច។

**ស៖** ខ្ញុំនឹងសួរសំណួរឡើងវិញ។ នៅពេលដែលចៅក្រម ព្រះរាជអាជ្ញា និង គ្រីស្តូហ្វ័រ ប៉េស្ទ័

សួរលោក តើលោកធ្លាប់ ឬក៏មិនធ្លាប់ប្រាប់អំពីអង្គហេតុដែលពាក់ព័ន្ធទាំងឡាយទៅដល់ពួកគេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អ្នកដែលមានសមត្ថកិច្ចសួរខ្ញុំពិតប្រាកដ តំណាងឲ្យតុលាការ តំណាងឲ្យជាតិប្រជាជនកម្ពុជា គឺសហចៅក្រមស៊ើបអង្កេត។ ដូច្នេះ សូមនិយាយត្រឹមតែប៉ុណ្ណឹងបានហើយ ក្រៅពីនោះ ខ្ញុំនៅតែធានាថា ខ្ញុំនិយាយការពិត ប៉ុន្តែពួកនេះមិនមានសមត្ថកិច្ចមកលើខ្ញុំទេ។ សូមលោកមេធាវីកុំយកមកពួកអស់ហ្នឹងមកសួរខ្ញុំទៀត។ នេះខ្ញុំសូមលើកសំណូមពរចំពោះតុលាការប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកធ្វើសម្បថផ្តល់ចម្លើយនៅក្នុងតុលាការនេះ លោកបានលើកឡើងថា លោកនិយាយតែការពិត គឺការពិតទាំងអស់ គ្មានអ្វីក្រៅតែពីការពិត។ ដូច្នេះហើយខ្ញុំសូមសួរលោក តើលោកតែងតែនិយាយតែការពិតទាំងស្រុងតែម្តង ឬក៏លោកជម្រាបការពិតតែពាក់កណ្តាលតែប៉ុណ្ណោះ?

[១៥:១១:២៧]

**ឆ៖** សំណួរនេះវាទៅឯណាណោះទៅវិញ ខ្ញុំសូមមិនដេញដោល ហើយមិនឆ្លើយអំពីការងារខាងទស្សនវិជ្ជា ឬខាងបរិម័តវិជ្ជានោះទេ។ សូមបញ្ជាក់ថា "បរិម័តវិជ្ជា" បារាំងហៅថា "ឡា មេតាហ្វីហ្សិក"។ ខ្ញុំមិនឆ្លើយទេ សំណួរនេះ ជាសំណួរទស្សនវិជ្ជា ឬក៏បរិម័តវិជ្ជាទៅហើយ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីរៀបចំការតាំងសំណួរដាក់លាក់ពាក់ព័ន្ធនឹងអង្គហេតុ ដែលអង្គជំនុំជម្រះបានកំណត់ធ្វើសវនាការ។ ហើយដោយឡែក សូមលោកមេធាវីពិនិត្យនៅលើសំណុំរឿង០០១ ផង ចំពោះកំណត់ហេតុមួយចំនួនទាំងកំណត់ហេតុដែលសួរដេញដោលសាក្សីរូបនេះនៅមុនពេលឃាត់ខ្លួន ដែលធ្វើឡើងដោយមន្ត្រីអង្គការសិទ្ធិមនុស្សប្រចាំកម្ពុជា គ្រីស្តូហ្វ័រ នៅខេត្តបាត់ដំបង។ អង្គជំនុំជម្រះ មិនយកមកដេញដោលទេ ដោយសារឯកសារនោះធ្វើឡើងខុសនីតិវិធី។ ហើយក៏ចៀសវាងនូវសំណួរច្រំដែលដែរគ្រាន់តែសំណួរជិតកន្លះម៉ោងទៅហើយហ្នឹងគ្រាន់តែពិត ឬមិនពិតហ្នឹង គឺនៅជ្រុំជើងនៅហ្នឹងឯង។ ដូចមិនទាន់សួរសំណួរចូលដល់សារធាតុនៃដីកាចោទប្រកាន់ទេ។

[១៥:១៣:២០]

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំនឹងត្រឡប់សួរទៅលើបញ្ហាទាំងអស់នេះឡើងវិញ។ ជាពិសេស ការជម្រាបតែការពិត សន្សំសំចៃទុកមួយចំនួន អត់ប្រាប់។ ហើយជាពិសេសលើបញ្ហានិយាយ

ជាមួយ គ្រីស្ទហ្វ័រ ប៉េស៊្វ។ ខ្ញុំគិតថាខ្ញុំមានសិទ្ធិសួរសំណួរទាំងអស់ដែលពាក់ព័ន្ធនឹងការសម្ភាស ដែលគាត់-- ដែលសាក្សីរូបនេះបានផ្តល់ជូនបុគ្គលទាំងអស់នោះ។ ខ្ញុំបានមើលសំណុំរឿង លោក ឌុច លោកពិតជាមានការចងចាំយ៉ាងប្រសើរ និងល្អណាស់។ តើលោកឯកភាពទៅលើចំណុចហ្នឹងដែរឬទេលោក?

[១៥:១៤:០៩]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ត្រង់ដែលខ្ញុំចងចាំល្អណាស់ ឬមិនល្អណាស់ អាស្រ័យនៅលើអារម្មណ៍របស់លោក ផេសមិន ទេ ចង់ថាខ្ញុំចងចាំល្អណាស់ក៏បានដែរ មិនល្អណាស់ក៏បានដែរ។ ខ្ញុំមិនអាចវាយតម្លៃខ្លួនឯងបានទេ។

**ស៖** លោកត្រូវបានគេលើកឡើង កាលបរិច្ឆេទច្រើនណាស់ ឧទាហរណ៍ថា ថ្ងៃ-- ខែសីហា ឆ្នាំ ១៩៧៧។ ដូច្នេះថា តើមានភ័ន្តច្រឡំខ្លះទៅលើថ្ងៃខែកាលបរិច្ឆេទនេះដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន កាលបរិច្ឆេទណាមិនដឹង អាចច្រឡំបន្តិចបន្តួច។ ក៏ប៉ុន្តែកាលបរិច្ឆេទមួយនេះអត់ច្រឡំទេ។

**ស៖** សូមអរគុណ។ លោក ឌុច នៅពេលដែលលោកនៅម-១៣ តើលោកខ្លួនឯងធ្លាប់ដែលធ្វើទារុណកម្មអ្នកទោសដែរឬទេ?

[១៥:១៥:៥៤]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមមិនឆ្លើយសំណួរនេះទេ។

**លោក ម៉ៃខល ផេសមិន៖**

ប្រសិនបើខ្ញុំឆ្លើយតប ខ្ញុំសូមបញ្ជាក់ថា ឌុច មកទីនេះក្នុងនាមជាសាក្សី។ ដូច្នេះគាត់មានកាតព្វកិច្ចត្រូវតែឆ្លើយ ហើយគាត់ត្រូវបានកាត់ទោស សម្រេចទោសដោយតុលាការកំពូលរួចហើយ។ ដូច្នេះថាតើគាត់មានសិទ្ធិនៅស្ងៀមមិនឆ្លើយតបឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

សាក្សីមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរឯណាដែលសួរដើម្បីបានចម្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង។ អង្គជំនុំជម្រះដូចបានប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់សាក្សីមុននឹងផ្តល់សក្ខីកម្មច្បាស់លាស់ហើយ។

[១៥:១៧:០៧]

**លោក ម៉ៃខល ផេសមិន៖**

ប្រសិនបើខ្ញុំសូមឆ្លើយតប។ ដរាបណាដែលគាត់មិនត្រូវបានសម្រេចពិរុទ្ធភាព ទើបគាត់ ប្រហែលជាអាចមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ នេះជាការសន្មតរបស់ខ្ញុំដូច្នេះ។

[១៥:១៧:២៣]

**ប្រធានអង្គជំនុំ៖**

នោះជារឿងរបស់លោក ប៉ុន្តែអង្គជំនុំបានសម្រេចរួចហើយ។

អង្គជំនុំជម្រះបានសម្រេចរួចហើយតាំងពីដំបូង គឺប្រាប់សិទ្ធិជនជាប់ចោទ អ៎! សិទ្ធិសាក្សីក្នុងការផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

អញ្ជើញលោក ផេសមិន ចង់ធ្វើអន្តរាគមន៍អីទៅ? អ៎! កាណាវាស?

[១៥:១៨:០៣]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំឯកភាពនឹងដឹងអំពីសេចក្ដីសម្រេច។ សហព្រះរាជអាជ្ញា គាត់តែងតែដកយុត្តិសាស្ត្រ អាយ.ស៊ី.ធី.អរ, អាយ.ស៊ី.ធី.វ៉ាយ។ យុត្តិសាស្ត្រទាំងអស់នោះបង្ហាញថា នៅពេលដែលជនជាប់ចោទត្រូវបានសម្រេចពិរុទ្ធភាព ហើយឆ្លងតុលាការកំពូលរួចហើយនោះ ជនជាប់ចោទត្រូវអាចបង្ខំឲ្យឆ្លើយបាន ប្រសិនបើបដិសេធមិនឆ្លើយ គឺអង្គជំនុំជម្រះអាចមានសិទ្ធិក្នុងការដាក់ទណ្ឌកម្ម។ លោក លោកស្រីចៅក្រម អាចមើលក្នុងរឿងក្ដី *យោគិក* ដែលក្នុងនោះគឺគាត់បានផ្ដល់ចម្លើយនៅតំបន់ *ស៊ីប្រឺនីហ្សា* លោកជនជាប់ចោទរូបនោះត្រូវបានតុលាការសម្រេចពិរុទ្ធភាព ហើយនៅពេលដែលសាក្សីជនជាប់ចោទរូបនោះ គឺគាត់បានលើកឡើងសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ គឺថាគេបានបញ្ជាក់ថានេះជាការប្រមាថតុលាការ ហើយគាត់ទទួលរងនូវទណ្ឌកម្ម។ ដោយសារតែនេះ សំណួរបានលើកឡើងថា តើគាត់នៅម-១៣ នេះមានធ្វើទារុណកម្មដោយខ្លួនផ្ទាល់ដែរឬទេ? យើងដឹងហើយថា វាអាចជាការដាក់បន្ទុកទៅលើរូបគាត់។ ក៏ប៉ុន្តែប្រសិនបើគាត់ជ្រើសរើសកុហកវិញ ហើយគាត់មិនឆ្លើយនោះ វាហាក់ដូចជាការប្រមាថតុលាការទៅវិញ។

ដូច្នេះ វាអាស្រ័យទៅលើគាត់។ គាត់ ថាតើគាត់គិតថាគាត់នឹងចង់ប្រមាថទៅដល់តុលាការ ឬក៏យ៉ាងម៉េច?

ដូច្នេះខ្ញុំសូមស្នើដល់អង្គជំនុំជម្រះធ្វើការពិចារណាឡើងវិញ ទៅលើសេចក្ដីសម្រេចនេះ។

[១៥:១៩:៤៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។ លោកមេធាវីអន្តរជាតិ អៀង សារី នោះលើកឡើងមិនត្រូវទេ។ ចំណុចមួយនោះ គឺមិនមែនការធ្វើទារុណកម្មនៅស-២១ នោះទេ គឺសួរអំពីការធ្វើទារុណកម្មនៅម-១៣ ហើយជនជាប់ចោទនេះត្រូវបានសម្រេចពិរុទ្ធភាពលើមន្ទីរស-២១ តែប៉ុណ្ណោះ។ សាក្សីរូបនេះលោក លោកស្រីចៅក្រម គាត់បានផ្ដល់ព័ត៌មានច្រើនណាស់ទាក់ទងទៅនឹងការចូលរួមក្នុងសកម្មភាពឧក្រិដ្ឋរបស់គាត់នៅក្នុង-សវនាការនេះ។ ដូច្នេះហើយពេលខ្លះទៅ វាសមស្របសម្រាប់ឲ្យគាត់ឆ្លើយតបទៅលើសំណួរ ក៏ប៉ុន្តែពាក់ព័ន្ធទៅនឹងសំណួរនេះគឺការធ្វើទារុណកម្មនៅមន្ទីរម-១៣ តែប៉ុណ្ណោះ។ ហេតុដូច្នេះ គឺវាអាច ក្នុងពេលអនាគតទៅវាអាចមានការចោទប្រកាន់ទៅលើគាត់ពីខាងសហព្រះរាជអាជ្ញា។

[១៥:២០:៥៣]

**លោក ម៉ៃខល ផេសមិន៖**

គឺចំណុចហ្នឹង គឺថាវាមានពាក់ព័ន្ធទៅនឹងពាក្យពីរម៉ាត់ចុងក្រោយនេះ។ ខ្ញុំគិតថា ឌុច ធ្វើការនៅម-១៣ រយៈពេលប្រហែលជាប្រាំបួនឆ្នាំឯណោះ ហើយមិនត្រូវបានសម្រេចពិរុទ្ធភាពនោះទេ។ យើងដឹងហើយថា យើងត្រូវមានការបែងចែកខុសគ្នារវាងស-២១ និងម-១៣ ជាពិសេសទៅលើអង្គហេតុនៅក្នុងសំណុំរឿង០០១ និងអង្គហេតុដទៃទៀតនៅតែមាន ហើយវាអាចពាក់ព័ន្ធទៅនឹងបទចោទនៅក្នុងសំណុំរឿង០០២ ដដែល។ សាក្សីរូបនេះ ត្រូវតែឆ្លើយទៅនឹងសំណួរដែលបានចោទសួរគាត់ ហើយខ្ញុំអាចទម្លាក់ប្រធានបទត្រង់សំណួរដែលខ្ញុំនេះទុកសិន ហើយខ្ញុំអាចចាប់ផ្ដើមសួរឡើងវិញនូវព្រឹកស្អែកត្រង់ចំណុចមួយនេះ។

[១៥:២១:៥៧]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ខ្ញុំនឹងបន្តសួរប្រធានបទអង្គហេតុមួយទៀត ហើយនិងខ្ញុំចាប់ផ្ដើមបន្តសួរលើម-១៣ នៅព្រឹកថ្ងៃស្អែក។ លោក ឌុច នៅក្នុងតុលាការនេះ លោកបានលើកឡើងដោយខ្លីៗនៅពេលដែលលោកនិយាយអំពីម-១៣។ ការទម្លាក់គ្រាប់បែកអាមេរិកាំង គឺក៏លោកបានលើកឡើងផងដែរ។ ថាតើលោក

នៅឯណានៅពេលដែលសហរដ្ឋអាមេរិកចាប់ផ្ដើមទម្លាក់គ្រប់បែកនៅក្នុងប្រទេសកម្ពុជា?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ដំបូងខ្ញុំសូមជូនជាការសង្កេត។ លោកផេសមិន លោកគិតលេខដកយ៉ាងម៉េចហ្នឹងឯង ពី៧១-៧៥ លោកនិយាយថា៩ឆ្នាំ។ លេខដក លោករៀនពីណាមកហ្នឹង? សូមលោកឆ្លើយខ្ញុំសិន!

[១៥:២៣:០៦]

**ប្រធានអង្គជំនុំ៖**

បានហើយ! សាក្សីមិនអាចសួរបញ្ច្រាសទៅអ្នកដែលតាំងសំណួរចំពោះលោកទេ។ ហើយលោកអាចឆ្លើយឬក៏លោកមិនឆ្លើយដោយសារមូលហេតុមិនដឹងថា ឆ្លើយយ៉ាងម៉េច? ពីព្រោះពេលវេលាហ្នឹងវាមិនសមស្របទៅនឹងអំឡុងពេលដែលលោកពាក់ព័ន្ធទៅនឹងការបំពេញភារកិច្ចណាមួយដែល ដូចជានៅម-១៣ ជាដើម។ អ៊ីចឹងលោកអាចមិនឆ្លើយទេ ពីព្រោះពេលវេលាហ្នឹងវាដល់ទៅប្រាំបួនឆ្នាំ ហើយលោកធ្វើការងារនោះតែពីរបីឆ្នាំ ឧទាហរណ៍អ៊ីចឹង។ វាមិនដឹងថាសួរក្នុងអំឡុងពេលណាមួយយើងមិនអាចឆ្លើយបានទេ។ តែលោកមិនអាចសួរតបទៅអ្នកដែលតាំងសំណួរទេ ពីព្រោះជាកាតព្វកិច្ចរបស់សាក្សី។

[១៥:២៤:០០]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ខ្ញុំគិតថា ប្រហែលជាចំណុចនេះមានការបកច្រឡំ ខ្ញុំចង់សួរថាតើនៅពេលណា? លោកនៅទីឯណាដែរ នៅពេលដែលអាមេរិកាំងចាប់ផ្ដើមទម្លាក់គ្រាប់បែកនៅក្នុងប្រទេសកម្ពុជានោះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ការអត្ថាធិប្បាយរបស់ខ្ញុំដូចច្បាស់ហើយ។ អាមេរិកាំងទម្លាក់គ្រប់បែកនៅកម្ពុជា ខ្ញុំនៅម-១៣។ ហើយមានមួយគ្រាប់ធ្លាក់ទៅលើមន្ទីរភូមិភាគនិរតី។

**ស៖** តើលោកមានធ្លាប់ឆ្លងកាត់ការទម្លាក់គ្រាប់បែកដោយអាមេរិកដែរឬទេ? លោកមានធ្លាប់ទទួលបទពិសោធន៍ដោយការទម្លាក់គ្រប់បែកអាមេរិកដែរឬទេ?

[១៥:២៥:១១]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សម័យនុំងយើងខ្ញុំជីកត្រង់សេនៅ ប៉ុនមិនមាន

ក្រាលពីលើទេ ជីកជារណ្ដៅ។ អ្នកទោសក៏នៅក្នុងត្រង់សេ ប្រធានស-- អ៎!ប្រធាន ម-១៣ ក៏នៅក្នុងត្រង់សេ ក៏នៅក្នុងរណ្ដៅនុ៎ង ដេកមើលតែទៅលើ។ ឃើញបេ៥២ ហោះមកចំ ជាគោលការណ៍ត្រូវគេចទៅទទឹងខ្លួន ទៅទទឹងអ៊ីចេះ ដើម្បីឲ្យផុត។ យើងខ្ញុំជឿជាថាគេចបានតែ១០០ម៉ែត្រចប់ហើយ។ ដូច្នេះយើងខ្ញុំឆ្លងកាត់របៀបហ្នឹង។ ឯចំណែកបេ៥២ ទម្លាក់ម្ដងៗខ្ទរក្បាល ហើយរណ្ដៅនៅសល់ទេ។ ទូទាំងប្រទេស រណ្ដៅនៅសល់ច្រើនដែរតើ តាមប្រជាជនកម្ពុជានិយាយ។

**ស៖** តើលោកអាចរៀបរាប់អំពីផលប៉ះពាល់កើតចេញពីការទម្លាក់គ្រាប់បែក ដែលលោកធ្លាប់ឆ្លងកាត់នៅពេលនោះដែរឬទេ?

[១៥:២៦:២៩]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ការខូចខាតនៅពេលដែលអាមេរិកាំងទម្លាក់គ្រាប់បែកលើមន្ទីរភូមិភាគនិរតីមានស្លាប់មនុស្ស។ ស្លាប់ប៉ុន្មាន? បក្សភូមិភាគអត់រាយការណ៍ទេ។ ទូទាំងប្រទេសមានស្លាប់មនុស្ស ស្លាប់ប៉ុន្មាន? ប៉ុល ពត ខំលាក់ ជាគោលការណ៍ដើម្បីកុំឲ្យប្រជាជនខ្លាចសង្គ្រាមសំបូរបែប។ ដូច្នេះ គ្មានស្ថិតិអីដែលផ្សាយឲ្យកូនចៅដឹងទេ បក្សកុម្មុនីស្តកម្ពុជាអំពីបញ្ហាទម្លាក់គ្រាប់បែកនេះ។

**ស៖** ឧទាហរណ៍ តើការទម្លាក់គ្រាប់បែកនេះមានបានធ្វើការបំផ្លិចបំផ្លាញទៅលើតំបន់ដែលជាកន្លែងផ្គត់ផ្គង់ស្បៀងអាហារដែរឬទេ?

**ឆ៖** អរគុណ។ ខ្ញុំក្ដាប់មិនបានទេ។

**ស៖** តើលោកមានបានដឹងទេ ចំនួនប្រជាជនដែលទទួលរងរបួស និងស្លាប់ដោយសារតែការទម្លាក់គ្រាប់បែនៅតំបន់របស់លោកនោះ?

**ឆ៖** ខ្ញុំសូមមិនឆ្លើយទេ។

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំគិតថាសាក្សីដូចជាមិនមានជម្រើសថាឆ្លើយ មិនឆ្លើយដូច្នេះទេ គាត់ត្រូវតែមានកាតព្វកិច្ចឆ្លើយទៅនឹងសំណួរ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយនឹងសំណួរទៅ បើលោកដឹងថាដឹងទៅ។ បើលោកអត់ដឹងថាអត់ដឹង។ បើលោកដឹងៗកម្រិតណា? គឺនិយាយតាមជាក់ស្ដែងដែលលោកមានបទពិសោធន៍ ឬក៏បានជួបប្រទះ។

00796622



[១៥:២៨:៤១]

**លោក កាំង ហ្គេកអ៊ាវ៖**

អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំគិតថាជាសំណួរនេះ ជាសំណួរច្រំដែល ព្រោះខ្ញុំបញ្ជាក់អំមិញពីមុនហើយ ថាបក្សភូមិភាគនិរតីលាក់ការណ៍សម្ងាត់ ស្លាប់ប៉ុន្មាន ស្អីប៉ុន្មាន? ក៏មិនៗនិយាយ មិនផ្សព្វផ្សាយឲ្យកូនចៅដឹង។ បក្សទូទាំងប្រទេសក៏លាក់ការណ៍សម្ងាត់។ ដូច្នេះ ខ្ញុំគិតថាសំណួរអំមិញនេះជាសំណួរច្រំដែល បានជាខ្ញុំមិនៗឆ្លើយ។ សូមលោកប្រធានអធ្យាស្រ័យ បើសិនជាខុស។

**ប្រធានអង្គជំនុំ៖**

អាចខុសគ្នារឿងបក្សផ្សេង រឿងបុគ្គល បានន័យថា បទពិសោធន៍លោកផ្ទាល់លោកអាចជួបនូវហេតុការណ៍ជាក់ស្តែងខ្លួនឯងថា តើមានបានជួបព្រឹត្តិការណ៍ហ្នឹងដែរឬទេ នូវការទម្លាក់គ្រាប់បែក? ហើយមានសម្លាប់មនុស្ស ឬក៏អត់ដែលជួបផ្ទាល់ទេ? ឬក៏ជួបដែរនូវការទម្លាក់ប៉ុន្តែអត់បានដឹងដូចថាស្លាប់ឬក៏ត្រូវរបួសអ្នកណាទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំភ្លាប់មិនបានទេ ឆ្ងាយពីខ្ញុំៗ។

[១៥:២៩:៥៤]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** នៅក្នុងតុលាការលោកបានលើកឡើងអំពីការទម្លាក់គ្រាប់បែក ដែលការទម្លាក់គ្រាប់បែកនេះគឺវានាំឲ្យមានការហូរចូល និងកើនឡើងអ្នកទោសនៅម-១៣។ តើលោកអាចពន្យល់ទៅលើចំណុចនេះបានដែរឬទេ?

**ឆ៖** អរគុណ។ ដោយសារព្រឹត្តិការណ៍ពីរ នេះទីមួយរឿងទម្លាក់គ្រាប់បែក។ ទីពីរ រឿងមនុស្សមកពីតំបន់ខ្មាំងចូលមកតំបន់រំដោះ គឺមនុស្សខាងបង្អែកអមលាំងនេះ។ ហើយមនុស្សតំបន់រំដោះចេញទៅតំបន់ខ្មាំង ហើយត្រឡប់មកវិញ។ ដោយសារព្រឹត្តិការណ៍នេះ តាម៉ុក សម្រេចឲ្យ ម-១៣ ចាប់ៗមនុស្សនៅក្នុងមូលដ្ឋានបង្អែកក្នុងរយៈកាលហ្នឹងអស់ប្រហែលជា៥០នាក់។ នេះជារឿងដែលខ្ញុំនៅចងចាំ។

[១៥:៣១:០៩]

**ស៖** តើលោកធ្លាប់បានធ្វើទារុណកម្មអ្នកទោសនៅ ស-២១ ដែរឬទេ?

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបថាបញ្ហានេះ វាមានរឿងច្រើន អ្នកទោសតែម្នាក់គត់ ដែលមេហាមមិនឲ្យធ្វើទារុណកម្ម នៅក្នុងពេលដែលខ្ញុំជាអនុប្រធាន។ ខ្ញុំឃើញ ឈិត អ៊ីវ វាប្រតិកម្មដាក់ ម៉ា ម៉េងឃាង ខ្ញុំទះកំផ្លៀង ឈិត អ៊ីវ មួយដៃពីរដៃ។ អានេះមែន។ បើមិនបង្ក្រាបអ៊ីចឹង ដូចជាច្រឡឹមដាក់ ម៉ា ម៉េងឃាង ហៅ ម៉ុន។ ពេលនុំខ្ញុំដើរជាមួយ ណាត។ នៅពេលដែល-- នៅពេលហ្នឹង ឈិត អ៊ីវ វាប្រតិកម្មដាក់ ម៉ា ម៉េងឃាង, ណាត គាត់ចង់រកវ៉ៃ ប៉ុន្តែខ្ញុំៗឃាត់ ណាត ព្រោះគាត់ប្រធាន កុំឲ្យវាអាក្រក់ភ្នែកមើលពេក ខ្ញុំសុខចិត្តទៅខ្លួនឯងជាអនុប្រធានទៅវ៉ៃ ប៉ុននុំង។

**ស៖** ក្រៅពីហេតុការណ៍ដែលលោកបានជម្រាបតុលាការ តើលោកធ្លាប់វាយអ្នកទោសផ្សេងទៀតទេ ឬក៏វាយដំអ្នកទោសណាម្នាក់ផ្សេងទៀតនៅស-២១ ដែរឬទេ?

**ឆ៖** អរគុណ។ គ្មានទេ។

**ស៖** មុននឹងខ្ញុំចូលទៅប្រធានបទមួយផ្សេងទៀត មុននេះតើលោកធ្លាប់អ្នកណាម្នាក់ដោយផ្ទាល់ដៃទេនៅ ស-២១ នោះ?

**ឆ៖** អរគុណ។ អត់ទេ។

**ស៖** នៅម-១៣ តើដូចម្ដេចដែរ?

**ឆ៖** អរគុណ។ ខ្ញុំសូមមិនឆ្លើយ ពីបញ្ហានៅ ម-១៣។

[១៥:៣៣:៥៥]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំគិតថា សាក្សីរូបនេះគប្បីឆ្លើយសំណួរនេះ ពីព្រោះថាបទឧក្រិដ្ឋនៅទីនោះមិនទំនងថានឹងមានការចោទប្រកាន់លើរូបគាត់ទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ បញ្ហានេះគឺថាបានសួររួចហើយ។ បញ្ហានុំងមិនទាក់ទងថាទំនង ឬមិនទំនងនោះទេ។ ដូច្នេះគឺថាអាចនឹងមានលទ្ធភាពពីការចោទប្រកាន់។ អ៊ីចឹងហើយវាមិនអាស្រ័យទៅលើភាពថា អាច ឬមិនអាច មិនគួរនោះទេ។ ដូច្នេះករណីនេះ អង្គជំនុំជម្រះបានសម្រេចរួចហើយបាទ។

[១៥:៣៤:៤១]

**លោក ម៉ៃខល ផេសមិន៖**

ឆ្លើយតបដោយសង្ខេបគឺថា បើនិយាយពីលទ្ធភាពវិញ ខ្ញុំគិតថា នឹងគ្មានការចោទប្រកាន់ទេ។ ដូច្នេះសាក្សីរូបនេះគប្បីតែឆ្លើយ។ បាទ គាត់មិនគប្បីប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះទេ។ ដូចដែលបញ្ជាក់ខាងដើម ខ្ញុំនឹងសួរចំណុចនេះឡើងវិញ ហើយឱ្យគាត់បានគិតយប់នេះឡើងវិញសិន។ ស្អែកខ្ញុំនឹងសួរគាត់។

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់តំណាងសហព្រះរាជអាជ្ញាមានប្រសិទ្ធភាព សាក្សីគឺមានសិទ្ធិបដិសេធក្នុងការឆ្លើយតបនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើន ដែលនាំឱ្យដាក់ពិរុទ្ធភាពខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួន។ មានន័យថា ដោយសារតែចម្លើយ ឬសេចក្តីអត្ថាធិប្បាយរបស់លោកនោះ នាំឱ្យលោកត្រូវទទួលរងការចោទប្រកាន់។ លើកលែងតែអង្គហេតុពាក់ព័ន្ធនឹងការ អង្គជំនុំជម្រះវិសាមញ្ញក្នុងការកម្ពុជាបានធ្វើការបកស្រាយ និងផ្តន្ទាទោសលោករួចហើយ។ បានន័យថា អង្គហេតុនេះ ក៏លោកនិយាយទៅ ក៏មានអត់មានបញ្ហាដែរ ពីព្រោះគោលការណ៍ មិនអាចអង្គហេតុមួយជំនុំជម្រះពីរដងទេ។ មិនអាចលើកបញ្ហានេះ ជម្រះឡើងវិញទេ។

[១៥:៣៥:៥០]

ចំណែកអង្គហេតុផ្សេងនេះ គឺអាស្រ័យលើលោក ប៉ុន្តែលោកមានសិទ្ធិ។ អ្វីដែលសិទ្ធិ អង្គជំនុំជម្រះបានជម្រាបជូនរួចហើយ តាំងពីថ្ងៃដំបូងនៃដំណើរការសវនាការ មុននឹងចាប់ផ្តើមសួរដេញដោលលោក។ ដោយសារមិនទាន់មានការបញ្ជាក់អំពីបញ្ហាពីរ រវាងអង្គហេតុដែលមិនទាន់ទទួលការវិនិច្ឆ័យហើយនិងអង្គហេតុដែលមានវិនិច្ឆ័យរួចហើយ ឥឡូវហ្នឹង ដើម្បីជាក់ច្បាស់ គឺថាចំពោះអង្គហេតុវិនិច្ឆ័យរួចហើយ គឺលោកអាចឆ្លើយ។ លោកមានកាតព្វកិច្ចត្រូវតែឆ្លើយតបនឹងសំណួរ ដូចយើងបានជម្រាបរួចហើយ ថាបញ្ហាវាមិនតម្រូវឱ្យលោកថាត្រូវតែឆ្លើយតបឱ្យបានលទ្ធផលនោះទេ។ ទោះបីជាអវិជ្ជាមានក៏ដោយ បើមិនដឹង វាចប់ត្រឹមមិនដឹងហើយ។ ហើយបើដឹងកម្រិតណា គឺបានឃើញ បានឮ បានដឹងមានបទពិសោធន៍កម្រិតណា គឺឆ្លើយតបទៅតាមកម្រិតនោះឯង។

[១៥:៣៦:៤០]

ដោយឡែក គឹម-១៣ គឺមិនអាចយកធាតុអត្តនោម័តិនៃការយល់ដឹងផ្ទាល់ខ្លួនរបស់មេធាវីរូបនេះយកមកធ្វើជាមូលដ្ឋាន សម្រាប់រឿងក្តីនេះ សន្មតថាមិនមានចោទប្រកាន់ ឬក៏បើកស៊ើបសួរនៅថ្ងៃ

អនាគតនោះទេ ពីព្រោះជាអំពើក៏មានលក្ខណៈចរិតធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានឹងរឿងក្ដីដែលកើតឡើងនៅក្នុងវគ្គក្រោយៗមកទៀតដែរ។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកបានចំណាយពេលច្រើន ក្នុងជីវិតរបស់លោកធ្វើការនៅក្នុងផ្នែកស៊ើបការណ៍ ហើយលោកបានសួរចម្លើយ ហើយបានធ្វើជាប្រធានសួរចម្លើយនូវពួកចារបុរស ដូចជាពួកគិញ។ តាមអ្វីដែលលោកចេះដឹងអំពីវិស័យនេះ ធ្វើការនៅក្នុងការវិស័យខាងស៊ើបការណ៍នេះ។ តើកម្រិត ឬក៏ទំហំនៃការជ្រៀតចូលរបស់ភ្នាក់ងារ សេ.អ៊ី.អា នៅកម្ពុជាប្រជាធិបតេយ្យនោះ វាកម្រិតខ្ពស់ប៉ុនណាតាមដែលលោកដឹង?

[១៥:៣៨:២០]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា បើយកឯកសារ ស-២១ ជាមូលដ្ឋាន ហើយបើយកតាមហ្នឹងយកតាមលោកទស្សនៈរបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីកំណត់សកម្មភាពរបស់ សេ.អ៊ី.អា គឺទូលំទូលាយណាស់។ ដូចដែលមានសរសេរនៅក្នុងអត្ថបទ មិត្តប៊ុន គាត់សរុបអ៊ីចឹង។ នេះ ខ្ញុំសូមបញ្ជាក់ឡើងវិញបើសិនជាឈរលើករណីពីរនេះ។ ទីមួយ លោកទស្សនៈរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់ សេ.អ.អា។ ហើយទីពីរ ឈរតាមការដែលយើងខ្ញុំស្រាវជ្រាវតាមការណែនាំរបស់គេនោះ វាឃើញការជ្រៀតជ្រែករបស់ សេ.អ៊ី.អា វាទូលំទូលាយណាស់។ ដូច្នេះ ខ្ញុំនិយាយក្នុងលក្ខណៈសម្បត្តិពីរនេះ ក្នុងលក្ខខណ្ឌពីរនេះ។

[១៥:៣៩:១៩]

**ស៖** លោក ឌុច សូមឲ្យលោកនិយាយឲ្យច្បាស់។ ខ្ញុំនិយាយពីបទពិសោធន៍ ចំណេះដឹងផ្ទាល់របស់ខ្លួន ដែលថាពីបញ្ហាការបង្កប់ខ្លួនរបស់ សេ.អ៊ី.អា ជាពិសេស ហើយលោកបានចូលរួមយ៉ាងទូលំទូលាយក្នុងការងារនេះ។ តើលោកអាចចង្អុលបង្ហាញទេ ដែលរកវែកមុខខ្សែរបស់ សេ.អ៊ី.អា ហ្នឹងឃើញប្រភេទណាខ្លះ នៅពេលដែលលោកធ្វើការឲ្យបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ក្នុងការដែលខ្ញុំធ្វើការឲ្យបក្សកុម្មុយនីស្តកម្ពុជា ក្នុងលោក

ទស្សនៈមួយដែលបក្សអប់រំជាប់អំពី សេ.អ៊ី.អា អំពីឧបាយកលរបស់ សេ.អ៊ី.អា ហើយបក្សណែនាំជាប់ យើងខ្ញុំបានរកឃើញ ហើយបក្សបានសម្រេចកម្ទេចអស់១២.២៧៣នាក់ ក្នុងនោះមាន សេ.អ៊ី.អា ជាសំខាន់ ភ្នាក់ងារយួនលេបទឹកដីជាសំខាន់បន្ទាប់ ហើយនិងចុងបញ្ចប់មាន កា.ហ្សេ.បេ។ ដូច្នេះ បើសិនជាយើងចង់ចែកថា តើកម្ទេចខាង សេ.អ៊ី.អា អស់ប៉ុន្មាន? បញ្ជីនៅហ្នឹងស្រាប់ យើងបូកទៅយើងឃើញ។

[១៥:៤០:៤៦]

**ស៖** ដើម្បីឱ្យប្រាកដថា ខ្ញុំមិនបានទទួលការបកប្រែត្រឹមត្រូវល្អទេ ប្រហែលជា១ ១០ ឬក៏១២ ភ្នាក់ងារ សេ.អ៊ី.អា មានតែប៉ុណ្ណឹងទេនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ តើដូច្នោះឬទេ?

**ឆ៖** ដែលខ្ញុំនិយាយនេះ-- អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ដែលខ្ញុំនិយាយនេះគឺយោង យោងទៅលើបញ្ជី ១២.២៧៣នាក់។ ក្នុងនោះមាន សេ.អ៊ី.អា ជាសំខាន់ ភ្នាក់ងារយួនលេបទឹកដីជាសំខាន់បន្ទាប់ ហើយនិង កា.ហ្សេ.បេ ជាបន្ទាប់មកទៀត។ បូកសរុបទៅវាប៉ុណ្ណឹងនាក់។ បើចង់ដឹងថាប៉ុន្មានៗ យើងបូកសរុបទៅ យើងឃើញហើយ សេ.អ៊ី.អា អស់ប៉ុន្មាន? កា.ហ្សេ.បេ អស់ប៉ុន្មាន? ភ្នាក់ងារយួនលេបទឹកដីអស់ប៉ុន្មាន? ដូច្នេះ មិនមែនពីរដណ្ដប់ បីដណ្ដប់លាន អ៎!នាក់នោះទេ។

**ស៖** តើទំហំ ឬក៏កម្រិតនៃការបង្កប់ខ្លួន ឬក៏ការជ្រៀតចូលរបស់ភ្នាក់ងារវៀតណាម ភ្នាក់ងារយួនហ្នឹងទំហំប៉ុនណាដែរតាមដែលលោកដឹងកាលសម័យនោះ?

**ឆ៖** ចំនួនដែលចាប់បានមក ហើយបានកម្ទេចរួចមកហើយ មាននៅក្នុងបញ្ជី។ ឯចំណែកទំហំដែលនៅសល់ អាហ្នឹងមិនដឹងប៉ុន្មាន។

[១៥:៤២:៤៤]

**ស៖** នៅពេលដែលលោកនិយាយថា យើងមិនដឹងពីចំនួនដែលនៅសល់នោះ តើលោក ចម្លើយរបស់គាត់-- ចម្លើយរបស់លោកនោះ លោកថានៅមាន១ខ្សែរបស់ភ្នាក់ងារយួន ប៉ុន្តែលោករកមិនទាន់ឃើញអស់។ តើមានន័យបែបនោះឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឥឡូវពិតជាមាននៅសល់ ព្រោះចម្លើយដែលទាក់ទងទាំងប៉ុន្មានដែលបក្សធ្លាប់តែសរុបឱ្យចាប់បញ្ជូនមកស-២១ ហ្នឹង មាននៅសល់ទៀត។ បង នួន ជា ហ្នឹងជាពិសេស។ សរុប-- មិនទាន់ចាប់អស់មនុស្សដែលមានស-២១ ឆ្លើយដាក់ផង មនុស្សអ្នកទោសនៅស-២១ ឆ្លើយដាក់ផង។ បើសិនជាគាត់ចាប់មក នៅសល់ច្រើនទៀត។

[១៥:៤៣:៤៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

ខ្ញុំសូមជំទាស់សំណួរបែបនេះ ដោយសារថា មេធាវីការពារទំនងជាបង្វែរព័ត៌មានការពិតអំពី សេ.អ៊ី.អា, កា.ហ្សេ.បេ ពីខ្លឹមសារនៃចម្លើយសារភាព ដែលនោះជាខ្លឹមសារនៃចម្លើយសារភាពដែលថា យកមកប្រើជាអង្គហេតុនៃរឿងក្តីនេះ មិនបានទេ។ ដូច្នេះ តុលាការគប្បីតែបញ្ឈប់គាត់ កុំឲ្យគាត់សួរសំណួរបែបនេះ។ បើសិនជាគាត់សួរសំណួរទាក់ទងទៅនឹងការយល់ដឹងរបស់គាត់ពី កា.ហ្សេ.បេ, សេ.អ៊ី.អា ដោយមិនយោងទៅរកចម្លើយសារភាព អាហ្នឹងគឺអាចធ្វើបាន។ ប៉ុន្តែសាក្សីបានយោងទៅហើយថាព័ត៌មាននេះ គឺវាចេញមកពីឯកសារ ចេញពីស-២១ ហើយមេធាវីការពារក៏ព្យាយាមបង្ហាញពីការពិតដែលទៅលើបញ្ហាដែលត្រូវបានទទួលបានដោយអំពើខុសច្បាប់ ដែលតុលាការមិនអនុញ្ញាតឲ្យយកមកប្រើទេ។ ដូច្នេះហើយ សហព្រះរាជអាជ្ញាប្រកាន់ជំហរនេះថា មិនឲ្យ-- មិនគប្បីមេធាវីសួរសំណួរនេះទេ។

[១៥:៤៥:១៥]

**លោក ម៉ៃខល ផេសមិន៖**

ដើម្បីឆ្លើយតប លោកប្រធាន លោក លោកស្រីចៅក្រម ហើយសហព្រះរាជអាជ្ញា ដូចជាយល់ច្រឡំអំពីចេតនារបស់ខ្ញុំក្នុងការតាំងសំណួរនេះ។ តាមពិត គឺខ្ញុំមិនព្យាយាមបង្ហាញភស្តុតាងអំពីខ្លឹមសាររបស់ចម្លើយសារភាពនោះទេ ជាពិសេសនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែជាពិសេសសាក្សីរូបនេះត្រូវជឿថា ចម្លើយសារភាពនោះ គឺមានការពិត។ ដូច្នេះហើយគាត់បានឆ្លើយរហូតមកដល់ពេលនេះ។ ហើយមិនមានការផ្តល់អ្វីច្រើនទេ ដែលថាគាត់រងពិរុទ្ធភាពហើយពីបញ្ហានោះនោះ។ ខ្ញុំរីករាយនឹងបន្តទៅប្រធានបទថ្មីមួយទៀត។

**ប្រធានអង្គជំនុំ៖**

ការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា គឺទុកជាបានការ ហើយសូមមេធាវីរៀបចំនូវការតាំងសំណួរឯណា ចៀសវាងនូវការផ្អែកលើខ្លឹមសារនៃកំណត់ហេតុទាំងឡាយដែលបានមកពីទារុណកម្មធ្វើជាមូលដ្ឋានក្នុងការសួរដេញដោលចំពោះសាក្សី។ ហើយដូចគ្នាហ្នឹងដែរ តំណាងសហព្រះរាជអាជ្ញា

ជាភាគីម្ខាងទៀតនៃការដេញដោលនេះ ដែលពីមុន តែងតែលើកឡើងជំទាស់ទៅនឹងសំណួរដែលសួរដោយភាគីម្ខាងទៀត ក្នុងករណីខ្លួនបានយល់ដឹង ហើយយល់ថា សំណួរនោះមិនត្រឹមត្រូវ។

អម្បាញ់មិញនេះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លុះត្រាតែសាក្សីឆ្លើយរួច បានខ្លួនធ្វើការជំទាស់ជាទូទៅទៅវិញ។

[១៤:៤៧:១២]

ក្នុងកិច្ចដំណើរការរយៈពេលកន្លងមកគឺ មានការជំទាស់ទៅវិញទៅមក រហូតដល់អង្គជំនុំជម្រះបានកំណត់នូវវិធានការមួយថា សាក្សីកុំអាលទាន់ឆ្លើយ រង់ចាំអង្គជំនុំជម្រះសម្រេចលើការជំទាស់របស់ភាគីទៅនឹងសំណួរដែលសួរនេះរួចសិន ថាត្រូវឲ្យសាក្សីឆ្លើយ ឬមិនបាច់ឆ្លើយតបទេ។ នេះជានីតិវិធីដែលយើងអនុវត្តកន្លងមក តាំងពីសំណុំរឿង០០១ រហូតដល់០០២ នេះ យើងធ្វើរបៀបនេះបានច្រើនហើយ។ ជាការពិតណាស់ ដោយឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ប៉ុន្តែអង្គជំនុំជម្រះក៏មានគ្នាច្រើននាក់ដែរទម្រាំនឹងការពិភាក្សាគ្នា អាចរយៈពេលវែង ហើយដោយសារបញ្ហាវាធំធេង។ អ៊ីចឹងការក្តាប់ ការគ្រប់គ្រង់នូវកិច្ចដំណើរការពិភាក្សា ដើម្បីឲ្យមូល ឲ្យចំនូវអង្គហេតុដែលកំណត់ឲ្យធ្វើការពិភាក្សាដេញដោល ក៏មិនមែនជាការងាយនោះឡើយ។

[១៤:៤៨:២៩]

ដូច្នេះ សូមភាគីនៃការជជែកពិភាក្សាដេញដោលនេះមានការចាប់អារម្មណ៍ ខ្លួនមានបំណងជំទាស់សូមឲ្យជំទាស់តវ៉ាបង្ហាញនូវបង្ហាញហេតុជាមុន មុនពេលអង្គ-- មុនពេលសាក្សីឆ្លើយ។ ដើម្បីអង្គជំនុំជម្រះសម្រេចថា គួរត្រូវឆ្លើយ ឬក៏មិនត្រូវឲ្យឆ្លើយ។

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ែខល ផេសមិន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** ឌុច តើលោកអាចរៀបរាប់ពីការងាររបស់លោកនៅស-២១ បានឬទេ នៅចន្លោះឆ្នាំ ១៩៧៥-១៩៧៦ ដែលមានសារប្រយោជន៍ ហើយក៏វាមានចំណុចសំខាន់ៗ ដើម្បីឲ្យកម្ពុជាប្រជាធិបតេយ្យអាចរស់រានបាននោះ? តើការងាររបស់លោកមានសារៈសំខាន់អ៊ីចឹងឬទេ?

[១៥:៤៩:៤៨]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន មុននឹងចាប់អធិប្បាយអំពីការងាររបស់ខ្ញុំនៅ ស-២១ ទៅតាមសំណួររបស់មេធាវី ផេសមិន ខ្ញុំសូមបញ្ជាក់ថា មេធាវី ផេសមិន លោកបាន អត្ថាធិប្បាយថា សារៈសំខាន់របស់ស-២១ ហ្នឹងនាំឲ្យកម្ពុជាប្រជាធិបតេយ្យរស់រានមានជីវិត។ បញ្ហា នេះធំណាស់ ខ្ញុំគិតថាការងាររបស់ខ្ញុំហ្នឹង មិនបានមួយតំណក់ទឹកក្នុងទឹកមួយសមុទ្រប៉ាស៊ីហ្វិកផង។ នេះខ្ញុំសូមកែតម្រូវប៉ុណ្ណេះ។ តាមសាច់ការដែលខ្ញុំបានធ្វើ។

[១៥:៥០:៣៥]

ហើយទីពីរ ខ្ញុំសូមបញ្ជាក់សាជាថ្មីម្តងទៀតថា ការងារនៅស-២១ ខ្ញុំធ្វើការក្រោមបញ្ជាផ្ទាល់ ស្ទើរតែជាប់ជាប្រចាំរបស់ សុន សេន។ ដំបូងគាត់ណែនាំឲ្យខ្ញុំទៅនាំអង្គភាពពីអមលាំងយកមកនៅ ភ្នំពេញ បន្ទាប់មកបានជុំហើយ គាត់ឲ្យខ្ញុំដើរប្រមូលឯកសារពីផ្ទះអ្នកធំៗ និងគ្រឹះស្ថានសាធារណៈរបស់ លន់ នល់។ ប្រហែលជាខែ១០ គាត់ចាប់ផ្តើមចូលឲ្យខ្ញុំទៅសួរចម្លើយជាមួយនឹងគេ ហើយនិងបង្រៀន គេសួរចម្លើយក្នុងឋានៈជាអនុប្រធាន។ នេះក្នុងឆ្នាំ១៩៧៥។ ហើយការងារអស់នេះមកចប់នៅពេល ដែលខ្ញុំឡើងធ្វើជាប្រធាន ខ្ញុំលែងបានទៅសួរហើយ ផ្ទាល់ហើយ។

ខ្ញុំអង្គុយមើលឯកសារជាមូលដ្ឋាន លើកលែងករណីម្នាក់គាត់ដែលខ្ញុំទៅសួរដោយផ្ទាល់ គឺ កុយ ធួន នេះតាមបញ្ជាមេដែលដាក់មក។ ហើយក្រៅពីនោះ ម្ល៉ូៗខ្ញុំគិតតែមើលសេចក្តីសារភាពរបស់ អ្នកទោសដើម្បីចារខ្លីៗ។ ចំណាររបស់ខ្ញុំនៅលើចម្លើយរបស់ស-២១ ជាភស្តុតាងស្រាប់ ជូនទៅខាងលើ ដើម្បីឲ្យខាងលើជួយ ស្រួលគិតស្រួលគូរ ស្រួលពិចារណា។

[១៥:៥២:០៩]

ក្នុងរយៈកាលនេះទៀត ជាមួយ សុន សេន ខ្ញុំធ្លាប់បានជម្រាបអង្គជំនុំជម្រះប៉ុន្មានលើករួចមក ហើយ។ ខ្ញុំជួប ទទួលការណែនាំស្ទើរតែរាល់ល្ងាច មួយថ្ងៃមួយម៉ោងតាមទូរស័ព្ទពិសេសរបស់ខ្ញុំជាមួយ នឹងគាត់។ ពីរបីថ្ងៃគាត់ឲ្យ ផន មកយកចម្លើយទៅម្តងតាមការដែលខ្ញុំរាយការណ៍ថា ចម្លើយបានច្រើន ហើយ ក៏ប៉ុន្តែ--

**ស៖** លោក ឌុច លោកបានសួរសំណួរ អ៊ំ! លោកបានឆ្លើយសំណួរខ្ញុំរួចហើយ ហើយ ដោយសារពេលវេលាខ្ញុំមានខ្លី។ សំណួរខ្ញុំគឺថា តើលោកយល់ថា ការងាររបស់លោកមានសារៈសំខាន់ ខ្លាំងដែរឬទេថា ដើម្បីឲ្យបក្សកុម្មុយនីស្តកម្ពុជាអាចរស់រានបាន។ ប៉ុន្តែចម្លើយរបស់លោកថា ការងារ

របស់លោកដូចជាតំណក់ទឹកតូចនៃសមុទ្រប៉ាស៊ីហ្វិក។ អាចគឺថា ខ្ញុំចង់សួរលោកបន្តទៅទៀត អំពីបញ្ហារឿងបាត់កង់។

បាទ អ៊ីចឹងខ្ញុំសួរឡើងវិញទៅលោកបាទ!

[១៥:៥៤:២៨]

**ប្រធានអង្គជំនុំ៖**

សំណួរនេះមិនពាក់ព័ន្ធនឹងអង្គហេតុដែលចោទប្រកាន់ទេ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំចង់បានឱកាសដើម្បីពន្យល់ពីមូលហេតុអ្វីដែលខ្ញុំចង់សួរសំណួរនេះ ប៉ុន្តែខ្ញុំនឹងសួរសំណួរនេះឡើងវិញបាទនៅពេលក្រោយ គឺនៅថ្ងៃស្អែក ហើយសង្ឃឹមថា ជាក់ស្តែង។ ហើយខ្ញុំនឹងពន្យល់ពីមូលហេតុមុននឹងសួរសំណួរបែបនេះបាទ។

**ប្រធានអង្គជំនុំ៖**

កុំភ្លេចថា អង្គជំនុំជម្រះក៏មានសិទ្ធិដែរ កាលណាសំណួរច្រំដែលអង្គជំនុំជម្រះមិនឲ្យសួរទេ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ឌុច តើមិត្តភក្តិរបស់លោក ស្រី ដែលសម្រេចចិត្តថាឈប់រៀនគណិតវិទ្យាជាមួយលោកតទៅទៀតហើយនោះ គាត់ឈ្មោះអី?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ សំណួរហ្នឹងមិនពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ទេ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំនឹងត្រឡប់មកសំណួរនេះឡើងវិញពីព្រោះថា ខ្ញុំយល់ថាមានការពាក់ព័ន្ធ ហើយខ្ញុំនឹងពន្យល់ពីមូលហេតុ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** តើលោកធ្លាប់មើលហេតុការណ៍ថា មានជនរងគ្រោះត្រូវបានគេធ្វើទារុណកម្មទេ?

[១៥:៥៦:៣៩]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នៅមន្ទីរស-២១ ខ្ញុំគ្មានពេលឯណាទៅមើល

គេសួរចម្លើយទេ។ ដូច្នេះខ្ញុំសូមបញ្ជាក់ថា ខ្ញុំគ្មានបានឃើញជនរងគ្រោះត្រូវគេធ្វើទារុណកម្មទេ លើកលែងតែករណីមួយដែលខ្ញុំចូលទៅ ហើយណែ-- ឲ្យគេសួរពីរបីម៉ាត់ ចំពោះជនជាតិអង់គ្លេសនុ៎ង គេសួរអត់មានទារុណកម្មទេ ដើម្បីខ្ញុំប៉ាន់ប្រមាណអំពីសមត្ថភាពបកប្រែភាសារបស់អ្នកបកប្រែរបស់ខ្ញុំ។ នេះខ្ញុំចូលទៅកន្លែងសួរតែប៉ុណ្ណឹង។

**ស៖** ដើម្បីឲ្យប្រាកដថា ដើម្បីខ្ញុំយល់ចម្លើយរបស់លោកច្បាស់នោះ នៅពេលដែលចូលទៅមើលការសួរចម្លើយនោះ គឺគេមិនបានធ្វើទារុណកម្មអ្នកទោសនោះទេ តើត្រូវឬទេ?

**ឆ៖** ពិត។

[១៥:៥៧:៥០]

**ស៖** លោកបានឆ្លើយផ្នែកមួយនៃសំណួររបស់ខ្ញុំៗមិនកម្រិតត្រឹមតែស-២១ ទេ? ចុះនៅម-១៣វិញ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមមិនឆ្លើយសំណួរនេះទេ។

**ស៖** តើលោកសប្បាយចិត្តនឹងការ-- នឹងអំពើទារុណកម្មដែរឬទេ?

**លោក វីល្លៀម ស្មីត៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក!

**លោក វីល្លៀម ស្មីត៖**

លោកចៅក្រម សាក្សីរូបនេះលោកបានបញ្ជាក់ហើយថា លោកមិនបានធ្វើទារុណកម្មនៅស-២១ទេ គាត់គ្រាន់តែបានទះកំផ្លៀង--។ បាទ នោះគឺថាមិនគប្បីសួរដាក់បន្ទោសមកសាក្សីអំពីអង្គហេតុនៅទីកន្លែងផ្សេងកាលបរិច្ឆេទផ្សេងទេ។ ខ្ញុំមិនដឹងថាតើគោលបំណងនៃការសួរសំណួររបស់មេធាវីនេះមានទិសដៅដូចម្តេចទេ? រហូតទាល់តែគាត់បានបញ្ជាក់ប្រាប់តុលាការពីមូលហេតុជាមុនសិន បើមិនដូច្នោះទេ គឺគាត់ហាក់ដូចជាបង្ខំសាក្សីឲ្យគាត់ឆ្លើយបញ្ច្រាស់នឹងឆន្ទៈរបស់គាត់។ បាទហើយមិនមានអ្វីដែលជាខ្លឹមសារទេ តាមដែលខ្ញុំឃើញគាត់សួរសំណួរប៉ុន្មានចុងក្រោយនេះ។

**លោក ម៉ែខល ផេសមិន៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំមកទីនេះដើម្បីបញ្ជាក់ពីភាពជឿជាក់បាននូវសាក្សីរូប

00796632



នេះ។ នេះគឺសំណួររបស់ខ្ញុំ គឺមានភាពពាក់ព័ន្ធមិនមែនដូចសម្ដីការអះអាងរបស់សហព្រះរាជអាជ្ញានោះទេ។ ហើយខ្ញុំក៏ចង់ដឹងដែរថា តើគាត់បានធ្វើដែរឬទេក្នុងភាពគាត់ជាប្រធាន ឬករណីយកិច្ចរបស់គាត់? ខ្ញុំមិនកម្រិតសំណួររបស់ខ្ញុំត្រឹមតែស-២១ ទេ មិនមែនជាសំណួរបិទនោះទេ។ ដូច្នេះសាក្សីគាត់មានសេរីភាពក្នុងការឆ្លើយ។ បាទ ជាពិសេសនៅម-១៣ នោះផងដែរ។

**លោក វីណ្ស៊ៀម ស្មីត៖**

គឺសំណួរផ្អែកលើអង្គហេតុដែលថា សាក្សីបានធ្វើទារុណកម្ម ហើយគាត់ឆ្លើយថា គាត់មិនបានធ្វើទារុណកម្មទេ គ្រាន់តែទះកំផ្លៀងជនរងគ្រោះម្នាក់ប៉ុណ្ណោះ។ ហើយបើសួរថា តើសាក្សីហ្នឹងសប្បាយចិត្តនឹងការធ្វើទារុណកម្មនៅស-២១? នេះគឺជាសំណួរដែលមានទិសដៅផ្សេង។ ដូច្នេះ សូមតុលាការពិចារណាចំណុចនេះ។

**ប្រធានអង្គជំនុំ៖**

ជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។

**លោក ម៉ៃខល ផេសមិន៖**

បាទ លោកប្រធាន ខ្ញុំមើលនាឡិកាដូចជាម៉ោងបួនហើយថា តើលោកប្រធានសម្រេចថាសម្រាកពេលនេះ ឬក៏ឲ្យខ្ញុំបន្តទៅទៀតបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ដែលបានរំឭកលើការសម្រាក។ ឥឡូវហ្នឹងដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹកទៅ។ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំសាក្សីទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយឲ្យនាំគាត់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។ ដូចគ្នាអនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

ក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*